**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួន

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លី ចន**

សាស្ត្រាចារ្យណែនាំ
លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ លី ចន គឺជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៤ ឆ្នាំសិក្សា ២០១០-២០១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- លោកឪពុក អ្នកម្ដាយ ដ៏មានគុណចំពោះកូន ដែលចិញ្ចឹមបីបាច់ ថែរក្សា ផ្ដត់ផ្គង់ ទូន្មាន ប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដោយក្ដីស្រឡាញ់តាំងពីកំណើតរហូតដល់កូនពេញវ័យ ដោយមិនគិតពីការនឿយហត់ លំបាកយ៉ាងនោះទេ ដើម្បីឲ្យកូនមានអនាគតភ្លឺស្វាង និងបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ។

-លោកឯកឧត្ដមសាកលវិទ្យាធិការសាកលវិទ្យាធិការរង ព្រមទាំងលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់រូបខ្ញុំ នូវគ្រប់មុខវិជ្ជាដ៏មានតម្លៃ បង្កប់ដោយខ្លឹមសារនៃអត្ថបទ ដែលធ្វើឲ្យខ្ញុំបាទទទួលបានចំនេះដឹងដ៏ខ្ពង់ខ្ពស់មានឧត្ដមភាព រហូតបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ ដើម្បីទុកជាទៀនសម្រាប់អុចបំភ្លឺផ្លូវនៃដំណើរជីវិតទៅថ្ងៃអនាគត។

- ជាពិសេស លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** បានចំណាយពេលយ៉ាងមមាញឹកដ៏មានតម្លៃ បង្ហាត់បង្រៀន ផ្ដល់ជាយោបល់ណែនាំ តម្រង់ទិស ដល់ខ្ញុំបាទទទួលបានការសរសេរសារណានេះពោពេញដោយអត្ថន័យ និងមានខ្លឹមសារល្អ។

- លោកគ្រូអ្នកគ្រូ ដែលបានធ្វើការបង្ហាត់បង្រៀនដល់ខ្ញុំបាទតាំងពីបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ រហូតដល់ខ្ញុំបានបញ្ចប់ការសិក្សាបរិញ្ញាបត្រប្រកបដោយជោគជ័យ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងបួងសួងដល់វត្ថុស័ក្ដសិទ្ធិទាំងពួងនៅលើលោកយើងនេះ ជួយតាមថែរក្សាជនរួមជាតិទាំងអស់ សមប្រកមជួបប្រទះដោយសេចក្ដីសុខ សេចក្ដីចំរើន ប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ *អាយុ វណ្ណៈ សុខៈ ពលៈ* កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំជានិស្សិតស្រាវជ្រាវលើប្រធានបទស្តីពី "ការឃុំខ្លួន" គឺជាសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី១៤ ឆ្នាំសិក្សា២០១០-២០១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសៀវភៅនេះស្រាវជ្រាវ ប្រមូលផ្តុំមកចងក្រងឡើងនូវខ្លឹមសារដ៏ស៊ីជម្រៅត្រូវបានទទួលមកពីការសិក្សាផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅក្នុងស្ថាប័នអនុវត្តច្បាប់ដែលកំពុងនៅជាធរមាន។ មិនត្រឹមតែប៉ុណ្ណោះ សៀវភៅនេះក៏ជាជំនួយស្មារតីដល់សិស្សនិស្សិតជំនាន់ក្រោយក្នុងការសិក្សា ឬពង្រឹងស្មារតីក្នុងការអនុវត្តច្បាប់នៅក្នុងស្ថាប័នតុលាការ មេធាវី អាជ្ញាសាលា និងមន្ត្រីអនុវត្តច្បាប់ផ្សេងៗ។ល។

ស្នាដៃនេះនឹងត្រូវបានចូលរួមចំណែកក្នុងការការពារសន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ អភិវឌ្ឍន៍សង្គមឲ្យមានការរីកចំរើនជឿនលឿនលើគ្រប់វិស័យ ដែលពុំឲ្យកើតមានអស្ថិរភាព នត្ថិភាពនៃបទល្មើស និងពង្រឹងនីតិរដ្ឋក្នុងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទៅអនាគត ដែលប្រជាពលរដ្ឋជាក្តីសង្ឃឹមនៃសសរស្តម្ភទ្រទ្រង់ប្រទេសជាតិ ទើបគេចាត់ទុកជាសង្គមមួយបានស្របតាមធាតុផ្សំបណ្តាបទដ្ឋាន ឬទំលាប់ គតិយុត្តនានានៃសង្គម ដែលចាំបាច់ត្រូវមានប្រជាជន ទឹកដី លទ្ធិប្រជាធិបតេយ្យ និងបទបញ្ញត្តិច្បាប់ជាលំដាប់។

ក្នុងការតាក់តែងឡើងមកនេះ អ្នកស្រាវជ្រាវនឹងធ្វើឲ្យស្នាដៃនេះរៀបរៀងទៅតាមបរិបទសង្គម ដែលទទួលស្គាល់ទៅលើការឃុំខ្លួន នៅពេលមានជនណាម្នាក់ធ្វើល្មើសច្បាប់ចែងទុកជាធរមាន គេហៅថា "មិនមានច្បាប់ចែង មិនមានបទល្មើស" ។ សម្រាប់ការឃុំខ្លួននេះ ត្រូវបានអនុវត្តនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលត្រូវបានគេរំលោភបំពានសិទ្ធិសេរីភាពក្នុងការរស់នៅប្រចាំថ្ងៃ នៅចំពោះមុខតុលាការ។

ខ្ញុំសូមសំណូមពរដល់ជនរួមជាតិទាំងអស់ ពិសេសស្ថាប័នតុលាការ ឬស្ថាប័នអនុវត្តច្បាប់នានាផ្តល់ការគាំទ្រ និងចូលរួមចំណែកយ៉ាងសកម្មស្មើៗគ្នានូវ "តួនាទី និងភារកិច្ចរបស់ខ្លួន" ប្រកបឲ្យមានចលនា លេចជាផ្លែផ្កានៃឧត្តមប្រយោជន៍ ក្នុងលំហូរសសៃឈាមនៃប្រព័ន្ធយុត្តិធម៌កម្ពុជា។

ក្នុងការជ្រើសរើសប្រធានបទដែលខ្ញុំបានសរសេរនេះ ពិតជាមានចំនុចខ្វះខាត និងកំហុសមួយចំនួនដែលជាស្នាដៃធ្វើលើកដំបូងរបស់ខ្ញុំ ហេតុនេះខ្ញុំមានចិត្តសោមនស្សរីករាយ សម្រាប់ប្រិយមិត្តអ្នកអាន សិក្សាស្រាវជ្រាវ សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ ក្នុងការរិះគន់ ក្នុងអត្ថន័យស្ថាបនាចំពោះប្រធានបទនេះ ខ្ញុំទន្ទឹងរង់ចាំបានគ្រប់ពេលវេលា។

ខ្ញុំសូមសំដែងទឹកចិត្តដ៏ស្មោះស្ម័គ្រនូវសេចក្តីគោរព និងជូនពរដល់ជនរួមជាតិទាំងអស់នៅគ្រប់ទិសទីដែលផ្តល់ជំនឿ និងគាំទ្រដល់ប្រធានបទនេះយ៉ាងធំធេង។ ដោយផ្អែកតាមការសន្និដ្ឋាននៃការគាំទ្របែបនេះ ខ្ញុំបានខិតខំស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនានា រួមទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងក្នុងស្ថាប័នអនុវត្តច្បាប់ណាមួយ ពិសេសស្ថាប័នតុលាការដែលជាស្ថាននីតិវិធីនៃបទល្មើស ដែលប្រមូលផ្តុំចងក្រម ធ្វើការបកស្រាយឡើងយ៉ាងលំអិតបំផុតលើប្រធានបទស្តីពី "ការឃុំខ្លួន"។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** .......... ០១

**ជំពូក១ ការឃុំខ្លួន**

**ក្នុងដំណាក់កាលថៅក្រមស៊ើបសួរ និងដំណាក់កាលថៅក្រមជំនុំជម្រះ**

**ផ្នែកទី១៖ នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងដំណាក់កាលថៅក្រមស៊ើបសួរ** .......... ០៤

**កថាខណ្ឌ ១. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន** .......... ០៥

១.១. ទប់ស្កាត់ ឬបង្ការបទល្មើស .......... ០៦

១.២. រក្សាការពារភស្តុតាង. .......... ០៧

១.៣. ធានានីតិវិធីបន្តនៃការឃុំខ្លួន .......... ០៨

**កថាខណ្ឌ ២. នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន** .......... ០៩

២.១. ការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន .......... ០៩

២.១.១. ការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន .......... ០៩

២.១.២. ការឃុំខ្លួនបណ្តោះអាសន្នដោយគំនិតផ្ទាល់ខ្លួនឯងបន្ទាប់ពីស្នើ យោបល់ពីព្រះរាជអាជ្ញា .......... ១១

២.១.៣. ការឃុំខ្លួនដោយការស្នើសុំរបស់ព្រះរាជអាជ្ញា .......... ១២

២.១.៤. ការឃុំខ្លួនក្នុងដំណាក់កាលថៅក្រមស៊ើបសួរ .......... ១៣

២.២. សៀវភៅឃុំខ្លួនបណ្តោះអាសន្ន .......... ១៥

២.២.១.កំណត់ហេតុស្តីពីបញ្ជីជនជាប់ឃុំខ្លួនបណ្តោះអាសន្ន .......... ១៦

២.២.២. ទំរង់ពិស្តារស្តីពីការឃុំខ្លួនបណ្តោះអាសន្ន .......... ១៦

២.៣. រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ .......... ១៧

២.៣.១. ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម .......... ១៧

២.៣.២. ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម .......... ១៨

២.៣.៣. ឧប្បទេវហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន .......... ១៩

២.៤. សិទ្ធិមានមេធាវីសង្គ្រោះផ្នែកច្បាប់បន្ទាប់ពីឃុំខ្លួន .......... ២២

២.៤.១. សិទ្ធិវិជ្ជាជីវៈរបស់មេធាវី .......... ២៣

២.៤.២. សិទ្ធិមានមេធាវីក្រោយការសម្រេចលើការឃុំខ្លួន .......... ២៤

២.៤.៣.សិទ្ធិមានមេធាវីចំពោះអនីតិជនលើការឃុំខ្លួន .......... ២៥

**ផ្នែកទី២៖ នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្នដោយចៅក្រមជំនុំជម្រះ** ...................... ២៦
**កថាខណ្ឌ១. ការសម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន** ............................... ២៦
១.១. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ........................................................ ២៦
១.២. នីតិវិមុនអង្គសេចក្ដី ........................................................................ ២៧
១.៣. នីតិវិធីក្នុងអង្គសេចក្ដី ...................................................................... ២៨
**កថាខណ្ឌ២. ការប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចឃុំខ្លួនបណ្ដោះអាសន្ន** ...... ៣០
២.១. ជនដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ ........................................................ ៣១
២.២. សិទ្ធិប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ................................................... ៣២
២.៣. អំណាចរបស់សាលាឧទ្ធរណ៍ ........................................................ ៣២
២.៤.ការឃុំខ្លួនជនជាប់ចោទក្នុងពេលជាប់បណ្ដឹងឧទ្ធរណ៍ ............................ ៣៣
**ជំពូក២ ការឃុំខ្លួនតាម**
**ក្នុងដំណាក់កាលនៃការអនុវត្តទោស**
**ផ្នែកទី១៖ សេចក្ដីសម្រេចលើការអនុវត្តទោស** .......................................................... ៣៥
**កថាខណ្ឌ១. ការអនុវត្តទោស** .................................................................... ៣៥
១.១. ពិរុទ្ធភាព និងសិទ្ធិរបស់ទណ្ឌិតក្នុងពន្ធនាគារ .................................. ៣៥
១.២. ការដាក់ជនជាប់ឃុំឲ្យត្រួតពិនិត្យដោយមន្ទីរឃុំឃាំង
ឬពន្ធនាគារ ........................................................................................ ៣៦
**កថាខណ្ឌ២.ការប្រកាសទោស** ...................................................................... ៣៧
២.១. ការប្រកាសមូលទោស ...................................................................... ៣៧
២.២. ការប្រកាសទោសជំនួស ...................................................................... ៣៨
២.៣. ការប្រកាសទោសបន្ថែម ...................................................................... ៣៨
**ផ្នែកទី២៖ ការអនុវត្តទោសក្នុងពន្ធនាគារ** ........................................................ ៣៩
**កថាខណ្ឌ១. ការគិតថិរវេលានៃការអនុវត្តទោស** ...................................... ៣៩
១.១ មរណភាពរបស់ជនជាប់ចោទ. ........................................................ ៣៩
១.២. អាជ្ញាយុកាលនៃទោស ...................................................................... ៣៩
១.៣. ការបន្ធូរបន្ថយទោស ...................................................................... ៤០
១.៤. ការលើកលែងទោស ............................................................................ ៤២
១.៥. ថិរវេលានៃការអនុវត្តទោសបង្ខំដល់រូបកាយ ...................................... ៤២

**កថាខណ្ឌ២. ឧបសគ្គនៃការអនុវត្តទោសឲ្យបានពេញលេញតាមសេចក្ដីសម្រេចតុលាការ**......................................................... ៤៣
២.១. ការអនុគ្រោះទោស ......................................................... ៤៣
២.២. ការលោះលាទោស ......................................................... ៤៤
២.៣. ការដោះលែងមានលក្ខខណ្ឌ ......................................................... ៤៥
២.៤. ការផ្អាកប្រកាសទោស......................................................... ៤៦
២.៥. ការព្យួរទោសសាកល្បង......................................................... ៤៧
២.៦. របបពាក់កណ្ដាលសេរីភាព......................................................... ៤៨
២.៧. ការបែងចែកទោសប្រភាគ......................................................... ៤៩
**សេចក្ដីសន្និដ្ឋាន**......................................................... ៥១
**អនុសាសន៍** ......................................................... ៥៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជាយើងជាប្រទេសនីតិរដ្ឋ ដែលយកច្បាប់ជាគោលជំហរក្នុងការដឹកនាំរដ្ឋ ដែលបង្កើតឡើងដោយអង្គការនីតិបញ្ញត្តិ ដែលយើងធ្វើការបែងចែកអំណាចទៅតាមបទដ្ឋានផ្សេងៗនៃសេចក្តីត្រូវការរបស់សង្គម ដាក់ជូនជនគ្រប់រូបត្រូវតែប្រតិបត្តិតាម។ ប្រទេសកម្ពុជាយើងយកច្បាប់រដ្ឋធម្មនុញ្ញជាច្បាប់កំពូល ឬច្បាប់គ្រឹះនៃលំហូរច្បាប់ដទៃផ្សេងៗទៀតដែលបង្កើតឡើងដើម្បីគ្រប់គ្រងនគរកម្ពុជា។ ក្នុងករណីមានជនណាម្នាក់មិនប្រតិបត្តិតាម ឬរំលោភបំពាន ច្បាប់ជាអ្នកដាក់ទណ្ឌកម្មទៅលើសកម្មភាពនៃកំហុសរបស់ជនល្មើសនោះ ដើម្បីបង្រ្កាប ឬបញ្ឈប់ការល្មើសតទៀតជាក់ស្តែងបទល្មើសមានជាហូរហែរ ហេតុនេះមានតែច្បាប់ព្រហ្មទណ្ឌមួយគតដែលមានប្រតិកម្មតាមផ្លូវតុលាការរបស់សង្គម ក្នុងការដាក់ទណ្ឌកម្មទៅលើបុគ្គលណាម្នាក់ដែលបង្កឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់របស់សង្គម បានន័យថាបទល្មើស គឺជាអំពើធ្វើសកម្មភាពក្នុងការបង្ហាញឆន្ទៈមានគ្រោះថ្នាក់ដល់សង្គម ហើយត្រូវបានផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ប្រសិនបើពុំមានច្បាប់ចែងទុកជាមុនអំពីអំពើណាមួយជាបទល្មើសទេនោះ អំពើនោះមិនចាត់ទុកជាបទល្មើសឡើយ ហើយច្បាប់ព្រហ្មទណ្ឌដែលចែងអំពីបទល្មើសនោះត្រូវនៅជាធរមាន ដោយយោងតាមនីត្យានុកូលភាព ដែលមានចែងក្នុងមាត្រា ៣នៃក្រមព្រហ្មទណ្ឌ គេចាត់ទុកបទល្មើសបានលុះត្រាមានធាតុផ្សំបីយ៉ាងគឺៈ

- ធាតុនីត្យានុកូលៈ ច្បាប់ចែងទុកអំពើណាមួយជាបទល្មើស។
- ធាតុសត្យានុម័តៈ ជាសកម្មភាព ឬអសកម្មភាពប្រព្រឹត្តដោយជនល្មើស។
- ធាតុអន្តោម័តៈ កំហុសចេតនា ឬអចេតនារបស់ជនល្មើស។

ជនដែលប្រព្រឹត្តបទល្មើសត្រូវបានគេឃុំខ្លួនតាមផ្លូវតុលាការដើម្បីងាយស្រួលក្នុងការអនុវត្តតាមនីតិវិធីច្បាប់ ក្នុងការរែកញែករកមុខអ្នកដែលប្រព្រឹត្តបទល្មើសឲ្យទទួលខុសត្រូវលើសកម្មភាពដែលខ្លួនបានធ្វើ ហើយតុលាការប្រមូលភស្តុតាង ដើម្បីធ្វើចោទប្រកាន់ ដាក់ទណ្ឌកម្មលើជននេះ។ ដោយយោងទៅតាមសេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមាត្រា ៩ ចែងថាគ្មានជនណាម្នាក់ត្រូវទទួលការចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តឡើយ បើតាមគោលការណ៍ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាមាត្រា៣៨ ចែងថាៈការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬឃុំខ្លួនរបស់ជនណាម្នាក់ អាចធ្វើទៅកើតលុះត្រាតែអនុវត្តតាមច្បាប់ត្រឹមត្រូវ។

ចំពោះបទល្មើសព្រហ្មទណ្ឌ នគរបាលយុត្តិធម៌មានពេលច្រើនបំផុតក្នុងការឃុំខ្លួនជនណាម្នាក់ដោយគ្មានសមត្ថកិច្ចតុលាការត្រឹមរយៈពេល ៤៨ម៉ោងតែប៉ុណ្ណោះ ដោយមិនគិតរាប់បញ្ចូលក្នុងចិរវេលានៃដឹកជញ្ជូនមកដល់តុលាការឡើយ។ បន្ទាប់ពីរយៈពេល ៤៨ម៉ោងនៃការឃុំខ្លួននេះ

ត្រូវពិនិត្យដោយចៅក្រម ប្រសិនបើជននោះត្រូវឃុំខ្លួនបន្ត ចៅក្រមត្រូវផ្តល់ការអនុញ្ញាតអំពីបញ្ហានេះ។ តាមទ្រឹស្តីនៃការបែងចែកអំណាចដាច់ពីគ្នា ការឃុំខ្លួនគឺជាតួនាទីរបស់អំណាចតុលាការ មិនមែនអំណាចនីតិប្រតិបត្តិនោះទេ ក្នុងការសម្រេចថា តើការឃុំខ្លួនជនជាប់ចោទស្របច្បាប់ដែរឬទេ?

នៅពេលជនជាប់ចោទត្រូវបានគេនាំមកបង្ហាញខ្លួននៅចំពោះមុខតុលាការលើកដំបូង ចៅក្រមស៊ើបសួរត្រូវសម្រេចដោយយោងតាមច្បាប់ថា តើត្រូវឃុំ ឬមិនត្រូវឃុំខ្លួនជនជាប់ចោទ ដើម្បីរង់ចាំសវនាការ។ ជាទូទៅចៅក្រមស៊ើបសួរជាអ្នកសម្រេចសេចក្តីនោះ បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា។ ការឃុំខ្លួនជាបណ្តោះអាសន្នមុនពេលសវនាការពេលខ្លះមានសារៈសំខាន់ ដើម្បីជំរុញឲ្យជនជាប់ចោទមកបង្ហាញមុននៅចំពោះមុខតុលាការ។ វាក៏ជាសកម្មភាពមួយការពារកុំឲ្យជនជាប់ចោទរំខានដល់ការស៊ើបសួរ ឬប្រព្រឹត្តបទល្មើសថ្មីៗទៀតមុនពេលសវនាការផងដែរ។ ប៉ុន្តែដោយសារការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ គឺជាការដកហូតយកនូវសេរីភាពរបស់ជនជាប់ចោទ ដូច្នេះវាមិនអាចឃុំខ្លួនបានទេ ដរាបណាមានហេតុផលល្អត្រឹមត្រូវ ដើម្បីកំណត់ថាត្រូវតែឃុំខ្លួនជនជាប់ចោទ។ ម្យ៉ាងទៀតជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ក្នុងការការពារខ្លួនស្របតាមច្បាប់ ឬបទដ្ឋានគតិយុត្តិ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និងឋានៈសង្គមអ្វីឡើយ។ ហេតុនេះនៅពេលជនណាម្នាក់ប្រព្រឹត្តបទល្មើស ច្បាប់ជាអ្នកមានប្រតិកម្មទៅលើជនល្មើសកុំឲ្យប្រព្រឹត្តតទៅទៀត ហើយឲ្យជននេះទទួលស្គាល់នូវកំហុសរបស់ខ្លួន ដោយសង្គមជាអ្នកអនុវត្តទោសទណ្ឌទៅតាមច្បាប់កំណត់ចែងទុកជាបទល្មើសនៅជាធរមាន ដើម្បីធ្វើការអប់រំ កែប្រែ ជនល្មើសឲ្យចូលមករស់នៅក្នុងសង្គមវិញ។

ចៅក្រមស៊ើបសួរអាចឃុំខ្លួនជនជាប់ចោទបាន តាមគំនិតខ្លួនឯងផ្ទាល់ បន្ទាប់ពីបានបញ្ជូនសំណុំរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ការឃុំខ្លួនរបស់ចៅក្រមស៊ើបសួរត្រូវមានបញ្ជាក់ពីសំអាងហេតុ គឺដើម្បីកុំឲ្យជនដែលប្រព្រឹត្តល្មើសច្បាប់រត់គេចខ្លួនពីការកោះហៅឲ្យចូលខ្លួនរបស់តុលាការ ដោយសារជនល្មើសមិនមានទីលំនៅច្បាស់លាស់ ខ្លាចជនល្មើសទៅប្រព្រឹត្តបទល្មើសថ្មីទៀត បំផ្លាញភស្តុតាង ត្រូវរ៉ូវគ្នាជាមួយសាក្សី ដោយបទល្មើសព្រហ្មទណ្ឌមានភាពស្មុកស្មាញពោពេញទៅដោយកំណាប់អាថិកំបាំង ហើយរំខានដល់ការស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ។ ហេតុការឃុំខ្លួនរបស់ជនជាប់ចោទមានរយៈពេលតែ៦ខែ បើហួសរយៈពេលនេះជនជាប់ឃុំត្រូវដោះលែងឲ្យមានសេរីភាពវិញ។

ចៅក្រមស៊ើបសួរអាចឃុំខ្លួនជនជាប់ចោទបានតែក្នុងករណី ព្រះរាជអាជ្ញាស្នើសុំឲ្យមានការឃុំខ្លួនតែប៉ុណ្ណោះ ហើយជនជាប់ចោទនៅក្នុងឃុំអាចដាក់ពាក្យទៅចៅក្រមដើម្បីសុំដោះលែងខ្លួននៅពេលណាក៏បាន។ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចចិត្តលើមូលដ្ឋានទាំងឡាយដែលមានចែង

ក្នុងច្បាប់ និងរាល់ភាគីដែលពាក់ព័ន្ធត្រូវមានឱកាសក្នុងការបញ្ចេញមតិយោបល់។ បន្ថែមពីនេះទៅទៀត ភាគីទាំងអស់អាចធ្វើការប្តឹងឧទ្ធរណ៍ អំពីសេចក្តីសម្រេចរបស់ចៅក្រមទៅសាលាឧទ្ធរណ៍បាន។

អាស្រ័យហេតុនេះការឃុំខ្លួន មានពីរផ្នែក ដែលផ្នែកទី១ និយាយពីការឃុំខ្លួនតាមវិធានការបណ្តោះអាសន្ន និងផ្នែកទី២ ការឃុំខ្លួនតាមវិធានការអនុវត្តទោស តើការឃុំខ្លួននេះមានអត្ថន័យយ៉ាងដូចម្តេច? ឥឡូវនេះសូមមើលការពន្យល់ដូចខាងក្រោម៖

# ជំពូក១ ការឃុំខ្លួន
# ក្នុងដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលចៅក្រមជំនុំជម្រះ

## ផ្នែកទី១៖ នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

យើងធ្លាប់សិក្សាកន្លងមកហើយថា អំណាចនៃការឃុំខ្លួន គឺជាអំណាចដែលសំខាន់បំផុតដែលមាននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងប្រទេសកម្ពុជា។ អំណាចនៃការឃុំខ្លួននោះជួយដល់តុលាការ ដើម្បីធានាឲ្យជនល្មើសមកបង្ហាញខ្លួនចំពោះមុខតុលាការ ហើយក៏បង្ការមិនឲ្យជនល្មើសមានការរំខាន ឬបង្ការអ្វីមួយដល់ដំណើរការស៊ើបសួរ ព្រមទាំងធានាស្វែងរកភស្តុតាង ឬពិរុទ្ធភាពជាប់ទាក់ទិននឹងអំពើល្មើស។ អំណាចនៃការឃុំខ្លួនត្រូវបានដកសិទ្ធិសេរីភាពរបស់ជនល្មើសជាបណ្ដោះអាសន្ន ដូចនេះការអនុវត្តការឃុំខ្លួន ត្រូវតែប្រតិបត្តិទៅតាមច្បាប់ឲ្យបានតឹងរឹង និងត្រឹមត្រូវ[1]។ ហេតុនេះព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋ ធម្មនុញ្ញនៃអង្គការសហប្រជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយណាទាក់ទងទៅនិងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ[2]។ ទន្ទឹមនឹងនេះដែរគ្មានជនណាម្នាក់ត្រូវបានគេឃាត់ខ្លួន ឃុំខ្លួន ឬនីរទេស ដោយរំលោភបំពានបានឡើយ បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ដោយគ្មានបុគ្គលណាម្នាក់ត្រូវបានគេចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្ត និងត្រូវបានគេដកហូតសេរីភាពរបស់ខ្លួនបានឡើយ លើកលែងតែមានករណីសមហេតុផល និងការអនុវត្តត្រឹមត្រូវតាមច្បាប់ ហើយជនណាដែលបានចាប់ខ្លួន ឬឃុំខ្លួន ត្រូវមានសិទ្ធិឲ្យគេប្រាប់ឲ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់អំពីការចោទប្រកាន់ នៅចំពោះមុខចៅក្រម ឬអាជ្ញាធរមានសមត្ថកិច្ចណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារក្នុងរយៈពេលដ៏ខ្លីបំផុតឲ្យសមស្រប ឬត្រូវដោះលែង មិនតែប៉ុណ្ណោះការឃុំខ្លួនមនុស្សម្នាក់ៗមិនមែនជារឿងងាយស្រួលនោះទេ គឺដើម្បីរង់ចាំជំនុំជម្រះ ដែលវាមិនមែនជាវិធានការទូទៅទេ ប៉ុន្តែការឲ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជនត្រូវចោទនៅក្នុងពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធីច្បាប់ ហើយត្រូវមានវត្តមានក្នុងការអនុវត្តសាលក្រម លើសពីនេះទៅទៀតជនរងគ្រោះ ឬជនត្រូវចោទដោយសារការឃាត់ខ្លួនឬឃុំខ្លួនដោយខុសច្បាប់ មានសិទ្ធិដាក់ពាក្យបណ្ដឹងទាមទារសំណង ដើម្បីឲ្យតុលាការសម្រេចដោយមិនពន្យាពេលអំពីនីត្យានុកូលនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំ[3]។ ក្នុងករណីដែលមានការចាប់ខ្លួន ឬឃុំខ្លួន ឬការដាក់ពន្ធនាគារត្រូវស្របតាមច្បាប់ និងត្រូវប្រើវិធានការចុងក្រោយសម្រាប់រយៈពេលខ្លី

---

[1] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ១៤ ឆ្នាំ២០០៦

[2] មាត្រា ៣១កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[3] មាត្រា៩ សេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ១៩៤៨

បំផុត[4]ដើម្បីធ្វើការចោទប្រកាន់ ឃាត់ខ្លួន ឬឃុំខ្លួនជនណាមួយ អាចធ្វើបានលុះត្រាតែអនុវត្តតាមច្បាប់ ដោយគ្មានការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ គឺអ្នកដៃដល់ ផ្សំគំនិតនិងអ្នករួមប្រព្រឹត្ត ត្រូវតែទទួលទោសតាមកំណត់ច្បាប់ ប៉ុន្តែការទទួលចម្លើយសារភាពដោយបងបទីយភាពផ្លូវចិត្ត ការបង្ខិតបង្ខំតាមផ្លូវកាយមិនចាត់ទុកជាភស្តុតាងនៃពិរុទ្ធ ភាពទេ ត្រូវកើតមានវិមតិសង្ស័យ ជាប្រយោជន៍ដល់ជនជាប់ចោទ ឬជនត្រូវចោទ យ៉ាងណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់ផ្តន្ទាទោសជាស្ថាពរ[5]។ ហេតុនេះជនដែលជាប់ចោទដោយបទឧក្រិដ្ឋ មានសិទ្ធិទាមទារឲ្យគេនាំខ្លួនទៅជួបចៅក្រម (ឬភ្នាក់ងារអំណាចតុលាការ) ភ្លាមដើម្បីសម្រេចវេលាជម្រះក្តី ឬកាត់ទោសតាមការកំណត់ដ៏សមគួរ ឬដើម្បីសម្រេចដោះលែងពីមន្ទីរឃុំឃាំងសិន។ គេពុំចាំបាច់ចាប់ខ្លួនជនជាប់ទោសដែលរង់ចាំថ្ងៃកាត់ទោសពោលគឺជនជាប់ចោទអាចសុំនៅក្រៅឃុំបានក្នុងករណីមានការធានារ៉ាប់រងប្រាកដថា ជននេះចូលខ្លួនទៅឲ្យចៅក្រមកាត់ទោសទៅតាមកាលបរិច្ឆេទដែលគេកំណត់ឲ្យដោយប្រធានតុលាការ។

ការឃុំខ្លួនជាវិធានការតឹងរឹងបំផុតក្នុងចំណោមនីតិវិធីព្រហ្មទណ្ឌ ពីព្រោះថា ជនដែលត្រូវបានឃុំខ្លួន ត្រូវបានកាត់ផ្តាច់ចេញពីសង្គមមនុស្សទូទៅក្នុងមួយរយៈពេលកំណត់ ដែលព្រមទាំងរារាំងនូវសិទ្ធិខ្លះៗជាប្រជាពលរដ្ឋ ដែលច្បាប់បានកំពុងការពារ។

ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានអនុវត្តសំរាប់ជាមធ្យោបាយចុងក្រោយ ក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌ ស្របតាមដំណើរការស៊ើបសួរនៃបទល្មើស ហើយនឹងដើម្បីការពារសណ្តាប់ធ្នាប់សង្គម និងការពារដល់ជនរងគ្រោះ មិនត្រូវអនុវត្តលើសពីរយៈពេលចាំបាច់ឡើយ គឺត្រូវទទួលការទុកដាក់ប្រកបដោយមនុស្សធម៌ និងគោរពភាពថ្លៃថ្នូររបស់មនុស្សមិនអាចកាត់ផ្តាច់បានទេ[6]។

### កថាខណ្ឌ ១. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព។ ប៉ុន្តែករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទៅតាមលក្ខខណ្ឌនៃបញ្ញត្តិច្បាប់ ទៅលើការប្រព្រឹត្តបទល្មើសដែលបានកើតឡើង[7]។ ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមទេ ទើបមានការឃុំខ្លួនបណ្តោះអាសន្នដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំឡើយ[៨]។ការឃុំខ្លួនបណ្តោះអាសន្នមានផលប្រយោជន៍ដូចជា៖[9]

[4] មាត្រា៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩

[5] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា២៥០ នៃនីតិវិធីព្រហ្មទណ្ឌ មាត្រា៦ នៃក្រមព្រហ្មទណ្ឌ

[6] មាត្រា៦ នៃវិធានបទដ្ឋានជាអប្បបរមារបស់អង្គការសហប្រជាជាតិស្តីពី វិធានការដាក់ឲ្យនៅក្រៅឃុំ

[7] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[8] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[9] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី។
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនជាប់ចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធីច្បាប់។
- ដើម្បីការពារសន្តិសុខជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាប់លាស់នូវមូលហេតុមួយ ឬច្រើនក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសម្រេចរបស់ខ្លួនក្នុងការឃុំខ្លួន[10]។

## **១.១. ទប់ស្កាត់ ឬបង្ការបទល្មើស**

ជនគ្រប់រូបកើតមកត្រូវមានសេរីភាព។ សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់ គឺសិទ្ធសំខាន់មួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌។ សច្ចធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន គឺជាចំនុចស្នូលនៃសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស[11]។ លើកលែងតែក្នុងកាលៈទេសៈពិសេស នៅពេលដែលពុំមានវិធានការជាក់លាក់ផ្សេងៗទៀត ជនម្នាក់អាចនឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន។ ស្របពេលដែលជូនតុលាការមានការចាំបាច់ត្រូវសម្រេចដាក់ជនម្នាក់ឲ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងភាពយុត្តិធម៌ឲ្យបានត្រឹមត្រូវ និងដើម្បីការពារជនរងគ្រោះ និងសាក្សី ការប្រើប្រាស់វិធានការឃុំខ្លួនបណ្តោះអាសន្ន ច្រើនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការសន្មតជាមុនថាគ្មានទោស ដរាបណាមានការសម្រេចផ្តន្ទាទោសដោយសាលាជម្រះក្តីឥតលម្អៀងនិងមានសមត្ថកិច្ចអនុវត្តត្រឹមត្រូវតាមច្បាប់។

កាលបើជនណាម្នាក់បានប្រព្រឹត្តអំពើល្មើសនឹងច្បាប់ហើយ ត្រូវបានគេចាប់ខ្លួន ឬឃុំខ្លួនដើម្បីឲ្យជននោះទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ប៉ុន្តែការឃុំខ្លួន គឺជានីតិវិធីងាយស្រួលបញ្ចប់បទល្មើសដើម្បីកុំឲ្យជននោះទៅប្រព្រឹត្តបទល្មើសថ្មី ឬបង្កើតចលាចលដល់សង្គម ហើយធ្វើការគាបសង្កត់លើសាក្សី ជនរងគ្រោះឬធ្វើការរួមសមគំនិតបំបាត់ភស្តុតាងឲ្យរួចផុតពីការទទួលទណ្ឌ

[10] ការអនុវត្តដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ លេខ ១២០ ក.យ.រប

[11] ការអនុវត្តដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ លេខ ១២០ ក.យ.រប

កម្ម [12] ។ ច្បាប់ជាសំនាញ់សម្រាប់ដាក់ទណ្ឌជនណាម្នាក់ដែលប្រព្រឹត្តល្មើសនិងច្បាប់ហាមឃាត់។ ហេតុនេះការឃុំខ្លួនត្រូវផ្អែកលើភស្តុតាង ដើម្បីដាក់បន្ទុកទៅលើជនជាប់ចោទឲ្យរៀងចាលឈប់ប្រព្រឹត្តបទល្មើសទៀត និងវិលត្រឡប់មករស់នៅក្នុងសង្គមវិញ។ ហេតុនេះភស្តុតាងសំដៅលើអ្វីខ្លះ ខ្ញុំសូមបើកការពន្យល់ដូចខាងក្រោមៈ

## ១.២. រក្សាការពារភស្តុតាង

ការឃុំខ្លួនលើជនដែលប្រព្រឹត្តបទល្មើស ត្រូវផ្អែកទៅលើភស្តុតាងដាក់បន្ទុកដែលមាននៅកន្លែងបទល្មើសជាក់ស្តែងស៊ីសង្វាក់គ្នា ដោយហេតុនៅពេលមានបទល្មើសកើតមានត្រូវបានបន្សល់ទុកស្លាកស្នាម ឬភស្តុតាងដែលជាលទ្ធផលនៃអំពើល្មើស ដែលច្បាប់ជាអ្នកកំណត់ទោស និងការទទួលខុសត្រូវកំហុសទាំងអស់ ហើយភស្តុតាងត្រូវរក្សាទុកដោយសេចក្តីសម្រេចរបស់តុលាការ និងព្រះរាជអាជ្ញា នៅកន្លែងដែលសមគួរ តែក្រោយពីផុតបញ្ចប់ការឃុំខ្លួន ភស្តុតាងត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ[13]។

សាក្សីក៏ជាបន្ទុកភស្តុតាងសំខាន់ក្នុងការដាក់បន្ទុកលើការឃុំខ្លួនជនជាប់ចោទផងដែរ ហើយសាក្សីត្រូវបានកោះហៅតាមដីកាកោះរយៈពេល១ខែមុនកាលបរិច្ឆេទសវនាការដើម្បីធានាថា នគរបាលយុត្តិធមិនិងអាជ្ញាសាលាមានពេលវេលាគ្រប់គ្រាន់ក្នុងការបំរើដីកា[14]មានចែងក្នុងមាត្រា២៩៧, ២៩៨,៣១៥,៣៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ លើកលែងតែមានបញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនតុលាការដោយសេរី។ តុលាការត្រូវថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ហើយតុលាការសម្រេចសេចក្តីសំអាងតែទៅលើភស្តុតាដែលមានក្នុងសំណុំរឿង ដែលគេយកមកបង្ហាញក្នុងពេលសវនាការប៉ុណ្ណោះ ប៉ុន្តែភស្តុតាងដែលសារភាពដល់តុលាការដោយសារទទួលក្រោមឥទ្ធិពលនៃអំណាចនរណាម្នាក់ ការបង្ខិតបង្ខំខាងរូបកាយ ខាងផ្លូវចិត្តក្តី និងរំលោភលើមាត្រាច្បាប់មិនចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពទេ មានចែងក្នុងមាត្រា ៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៨ នៃរដ្ឋធម្មនុញ និងមាត្រា២ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

តាមគោលការណ៍ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធមិ មានតម្លៃត្រឹមតែជាព័ត៌មាន ត្រូវទុកជាន្ទាល់"*ឯកសារដើម*" បានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿជាក់រហូតដល់មានភស្តុតាងផ្ទុយ កាលបើកំណត់ហេតុទាំងនោះធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធមិខ្លួនឯង ក្នុងករណីនេះចៅ

[12] សេចក្តីពន្យល់នៃមាត្រាទាំងឡាយនៃក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ទំព័រ៤៤-៤៥ ឆ្នាំ២០១៤

[13] មាត្រា១១៩ នៃក្រមនីវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[14] សន្និសីទ ស្តីពីការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ បន្ទាប់ពីអនុម័តបាន៥ឆ្នាំ ទំព័រ ២៥-២៦ ឆ្នាំ២០១២

ក្រមស៊ើបសួរត្រូវទុកខ្លឹមសាររបស់កំណត់ហេតុនេះថាជាសេចក្តីពិត និងត្រឹមត្រូវដរាបណាគ្មានភស្តុតាងអ្វីផ្ទុយមកបញ្ជាក់ទេ។ ភស្តុតាងផ្ទុយនេះអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ មាត្រា១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហើយរាល់ការឆែកឆេររកវត្ថុតាងរបស់នគរបាលយុត្តិធម៌បានតែក្នុងករណីបទល្មើសជាក់ស្តែង ដែលការឆែកឆេរធ្វើបានតែចន្លោះម៉ោង៦ព្រឹកដល់ម៉ោង៦ល្ងាច នៅចំពោះមុខសាក្សីពីរនាក់នៃកន្លែងកើតបទល្មើសជាក់ស្តែង លើកលែងកន្លែងបើកចំហជាសាធារណៈ (មាត្រា៩១,១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ការបង្ហាញភស្តុតាង គឺជាមធ្យោបាយ ឬជាបន្ទុករបស់ព្រះរាជអាជ្ញា អាចសំរេចធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់លើជនត្រូវចោទដែលបានប្រព្រឹត្តបទល្មើសនោះ ហើយចៅក្រមស៊ើបសួរសម្រេចអំពីការបញ្ជូន ឬមិនបញ្ជូនរឿងទៅជំនុំជម្រះ ដោយចៅក្រមជំនុំជម្រះត្រូវសម្រេចអំពីទណ្ឌកម្ម នៅពេលរកឃើញមានពិរុទ្ធភាពរបស់ជនត្រូវចោទ ក្នុងករណីរកទៅមិនឃើញថាគ្មានពិរុទ្ធភាព ចៅក្រមជំនុំជម្រះ អាចសម្រេចឲ្យរួចខ្លួនពីបទចោទប្រកាន់ និងចេញដីកាបង្គាប់ឲ្យដោះលែងភ្លាម បន្ទាប់ពីតំណាងអយ្យការមិនប្តឹងឧទ្ធរណ៍ភ្លាមទេ។ ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ អាចធ្វើបានដោយប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីញ៉ាំងឲ្យចៅក្រមជឿបាន ឧទាហរណ៍ ដោយការទទួលសារភាព របស់ជនល្មើស ដោយចម្លើយសាក្សីឆ្លើយ សមហេតុផល និងជាក់ច្បាស់ ដោយការពិនិត្យគ្រប់មុខសញ្ញា ដោយកោសល្យវិច័យ ឬដោយមធ្យោបាយត្រឹមត្រូវតាមច្បាប់ដទៃទៀត ដូចជាការទៅពិនិត្យកន្លែងកើតហេតុ។ ហើយជំនឿរបស់តុលាការទៅលើភស្តុតាងនោះគឺ អាចដាក់សួរដេញដោលនៅក្នុងសវនាការរវាងគូក្តី និងមេធាវី ដើម្បីសម្រេចចេញសាលក្រម[15]។

### ១.៣. ឆានានីតិវិធីបន្តនៃការឃុំខ្លួន

ក្រោយពីបានពិនិត្យកំណត់លើអង្គហេតុនៃការប្រព្រឹត្តបទល្មើសតុលាការមានសិទ្ធិសម្រេចបង្គាប់ឲ្យឃុំខ្លួន ឬមិនឃុំខ្លួនជនជាប់ចោទឲ្យនៅក្រៅឃុំតាមរយៈដីកាសម្រេចរបស់ចៅក្រមកាន់សំណុំរឿងនោះ(ចៅក្រមស៊ើបសួរ) តាមរយៈគំនិតខ្លួនផ្ទាល់ ឬសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ដោយមានសំអាងហេតុត្រឹមត្រូវ ហើយជូនដំណឹងដល់ព្រះរាជអាជ្ញា ឬជនត្រូវចោទ។ ដីកាបង្គាប់ឲ្យឃុំនោះត្រូវមានចុះអត្តសញ្ញាណជនត្រូវចោទ ប្រភេទនៃបទល្មើស ត្រូវចោទប្រកាន់ ព្រមទាំងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីការួមទាំងហត្ថលេខានិងបោះត្រាផង[16]។ បន្ទាប់ពីមានដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានភ្ជាប់ដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែមានដីកាបង្គាប់

[15] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ១២៧-១៣០ ឆ្នាំ២០០៩

[16] មាត្រា២២១ នៃក្រមនីតិវិធីតុលាការព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ឲ្យដោះលែងមានសេរីភាពវិញ។ ការឃុំខ្លួនលើជនល្មើសនេះងាយស្រួលឲ្យតុលាការស្វែងរកភស្តុតាងដាក់បន្ទុកឬដោះបន្ទុកលើជនជាប់ចោទឲ្យទទួលទោសទណ្ឌតាមសកម្មភាពនៃអំពើល្មើសគ្មានជនជាប់ចោទណាម្នាក់ ត្រូវទទួលទណ្ឌកម្មឬការប្រព្រឹត្តទាំងឡាយណាដែលឃោឃៅអមនុស្ស ធម៌ ឬនាំឲ្យបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំ និងធ្វើទារុណកម្មឡើយ។ ជនជាប់ឃុំម្នាក់ៗត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ។ អ្នកទោសទាំងឡាយមិនត្រូវបានគេចង ឬដាក់ឲ្យនៅឯកកោម្នាក់ឯង ទោះស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នក្តី ឬត្រូវបានកាត់ទោសរួចហើយក្តី។ ទោះក្នុងករណីណាក៏ដោយគ្រួសារអ្នកជាប់ឃុំ ឬគ្រួសារអ្នកទោសមិនត្រូវបានគេយាយី ដោយសារការប្រព្រឹត្តបទល្មើសរបស់ជននោះឡើយ[17]។

ការឃុំខ្លួនត្រូវគោរពតាមបទដ្ឋានអប្បបរិមានៃបទវិន័យសម្រាប់គ្រប់គ្រងអ្នកជាប់ឃុំ ព្រមទាំងត្រូវគោពតាមគោលការណ៍ជាមូលដ្ឋានសម្រាប់ការពារអ្នកទោស ដែលអង្គការសហប្រជាជាតិបានអនុម័ត។

ការឃុំខ្លួនជានីតិវិធីចុងក្រោយបំផុតប្រសិនបើចៅក្រមយល់ឃើញថា៖

- ខ្លាចជនសង្ស័យរត់គេចខ្លួនមិនចូលខ្លួននៅចំពោះមុខតុលាការវិញ។
- រាំងស្ទះដល់ការងារតុលាការ ប្រសិនបើជនសង្ស័យបំផ្លាញភស្តុតាង គំរាមសាក្សី សមគំនិតត្រូវរ៉ូវគ្នាជាមួយជនរងគ្រោះ។

ការឃុំខ្លួន គឺដើម្បីធ្វើដំណើរការនីតិវិធីលើបណ្តឹងឲ្យជនល្មើសដែលនៅក្នុងពន្ធនាគាររង់ចាំសម្រេចបើកសវនាការដោះលែងជនល្មើសឲ្យមានសេរីភាពវិញ។

## កថាខណ្ឌ ២. នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន

### ២.១. ការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ដីកាឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានប្រកាសដោយចៅក្រមស៊ើបសួរ៖

- ការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន
- ការឃុំខ្លួនដោយគំនិតផ្ទាល់ខ្លួនឯងបន្ទាប់ពីស្នើសុំយោបល់ពីព្រះរាជអាជ្ញា
- ការឃុំខ្លួនដោយការស្នើសុំរបស់ព្រះរាជអាជ្ញា
- ការឃុំខ្លួនក្នុងដំណាក់កាលចៅក្រមស៊ើបសួរ

#### ២.១.១. ការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន

ដីកាបង្គាប់ឲ្យឃុំ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលឃុំខ្លួនជនជាប់ចោទ ដែលមានតែចៅក្រមស៊ើបសួរទេអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន (យោងតាមមាត្រា២១៩-

[17] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ៥៥ ,៥៦ ឆ្នាំ២០០៦ និងមាត្រា២៥,៥៣ នៃច្បាប់ស្តីពីពន្ធនាគារ

២២០នៃក្រមនីតិវិធីព្រហ្មទណ្ឌ) លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសំរេចឃុំខ្លួនបណ្តោះអាសន្ន មានន័យថាចាំបាច់ត្រូវតែចេញដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ទើបចៅក្រមមានមូលដ្ឋានគតិយុត្តិដោយសំអាងហេតុ ដែលនាំឲ្យចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួន បណ្តោះអាសន្ន។ ប៉ុន្តែចៅក្រមស៊ើបសួរ មិនអាចដាក់ចេញដីកាបង្គាប់ឲ្យឃុំខ្លួនមុនដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ននោះទេ ដោយហេតុថាដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវបំពេញបន្ថែមលើដីកាសំរេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។

ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវភ្ជាប់ទៅជាមួយជនជាប់ឃុំតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាធរមានសមត្ថកិច្ចទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួលឃុំខ្លួនបុគ្គលណាមួយដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនប៉ុណ្ណោះ រហូតទាល់តែដល់មានការទទួលដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ (មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) មានន័យថាបុគ្គលណាដែលជាប់ឃុំដោយគ្មានសេចក្តីសំរេចពីតុលាការណាមួយ ដោយគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនទេនោះ ធ្វើឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន មិនអាចឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនបានឡើយ[18] ព្រោះប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនអាចប្រឈមមុខនិងការប្រព្រឹត្តបទល្មើសទាក់ទិននិងការបង្ខាំងមនុស្សដោយខុសច្បាប់ [19] ។ ដោយច្បាប់ធានារ៉ាប់រងមិនឲ្យមានការរំលោភបំពានលើរូបកាយបុគ្គលណាមួយឡើយ ហើយច្បាប់ត្រូវធានាការពារជីវិត កិត្តិយស កេរ្តិ៍ឈ្មោះ សេចក្តីថ្លៃថ្នូររបស់បុគ្គលគ្រប់រូប ប៉ុន្តែបើមានការចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនជនណាម្នាក់ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តតាមបញ្ញត្តិច្បាប់ចែងជាធរមាន ដែលច្បាប់ហាមឃាត់មិនឲ្យធ្វើឡើងចំពោះការបង្ខិតបង្ខំធ្វើបាបលើរូបកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទណ្ឌកម្មអនុវត្តលើជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ[20]។ ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោសដរាបណាតុលាការផ្តន្ទាទោសជាស្ថាពរ(ផ្អែកតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ)។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវមាននិទ្ទេសពិស្តារដូចតទៅ៖

- អត្តសញ្ញាណជនត្រូវចោទ។
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង (ដោយយោងតាមមាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

[18] មាត្រា១៧-១៩ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១
[19] មាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[20] មាត្រា២៥,៥៣ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម[21]។

### ២.១.២. ការឃុំខ្លួនដោយគំនិតផ្ទាល់ខ្លួនឯងបន្ទាប់ពីស្នើសុំយោបល់ពីព្រះរាជអាជ្ញា

ចៅក្រមស៊ើបសួរចេញដីកាសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នតាមគំនិតខ្លួនឯងផ្ទាល់ និងតាមសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជាអាជ្ញា ក្រោយពីជនជាប់ចោទបង្ហាញខ្លួនលើកដំបូងបន្ទាប់ពីចៅក្រមស៊ើបសួរ ធ្វើការកត់កំណត់ហេតុទាញហេតុផលលើជនត្រូវចោទនៃមូលវិចារគ្រប់ជ្រុងជ្រោយ ដែលមានលក្ខណៈធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ នៅក្រោយពេលចៅក្រមស៊ើបសួរទទួលបណ្តឹងតាមរយៈដីកាសន្និដ្ឋានស្ថាពរបញ្ជូនសំណុំរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា[22] ។ មានន័យថាចៅក្រមស៊ើបសួរត្រូវដោះលែង ឬឃុំខ្លួនបណ្តោះអាសន្ននៅពេលជនជាប់ចោទបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខតុលាការ ទោះបីជាមានការប្តឹងឧទ្ធរណ៍ពីជនជាប់ចោទ ឬជនត្រូវចោទក៏ដោយ ចៅក្រមស៊ើបសួរនៅតែឃុំខ្លួនដដែល ដោយហេតុថាព្រះរាជអាជ្ញាបានឯកភាពរួចហើយលើកលែងតែមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាលើសេចក្តីសម្រេចនេះ នាំឲ្យដីកានេះលែងមានអានុភាពអនុវត្តភ្លាម ប្រសិនជាមានសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍បង្គាប់ឲ្យដោះលែង។ បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវធ្វើក្នុងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកានេះ[23]។

ចៅក្រមស៊ើបសួរបិទការស៊ើបសួរចេញដីកាដំណោះស្រាយ បញ្ជូនជនជាប់ចោទទៅជម្រះ ឬលើកលែងចោទប្រកាន់នៅចំពោះមុខតុលាការ។ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថានពររបស់ព្រះរាជអាជ្ញាឡើយ។ ហើយចៅក្រមស៊ើបសួរអាចរក្សាទុកជនជាប់ចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលមានអានុភាពរយៈពេល៤ខែ ប្រសិនបើមិនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេល ៤ខែទេនោះ ត្រូវដោះលែងឲ្យនៅក្រៅឃុំដោយស្វ័យភាព ប៉ុន្តែក្រោយពីដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ឬសាលដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរហើយ បើមានលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ ហើយអាចឃុំខ្លួនជនជាប់ចោទវិញ តាមការផ្តើមគំនិតរបស់ព្រះរាជាអាជ្ញា តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអង្គហេតុថ្មីនោះឡើយ ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ

[21] មាត្រា២២២ កថាខណ្ឌ១ វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[22] មាត្រា២០៦នៃក្រមនីវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[23] មាត្រា២៧០នៃក្រមនីវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ប្រសិនបើអង្គហេតុនោះ ជាស្ថានទំងន់ទោសលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង[24]។

### ២.១.៣. ការឃុំខ្លួនដោយការស្នើសុំរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាមានសិទ្ធិសុំឲ្យចៅក្រមស៊ើបសួរឃុំខ្លួនជនប្រព្រឹត្តបទល្មើសជាបណ្តោះអាសន្ន តាមដីកាសន្និដ្ឋានស្តាពរបញ្ជូនរឿងឲ្យចៅក្រមស៊ើបសួរនៅគ្រប់ពេលវេលានៃការស៊ើបសួរ ដែលខ្លួនយល់ថាមានប្រយោជន៍ទៅលើការចោទប្រកាន់ ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋរបស់ព្រះរាជអាជ្ញាជាការចាំបាច់ខានមិនបានឡើយ ប៉ុន្តែក្នុងករណីបទមជ្ឈឹមអាចបើការស៊ើបសួរបានដូចការស៊ើបសួរបទឧក្រិដ្ឋ ហើយបញ្ជូនទៅជម្រះផ្ទាល់ភ្លាម ដែលព្រះរាជអាជ្ញាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង[25]។

ប្រសិនចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានស្តាពររបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងរយៈពេល១៥ថ្ងៃ ត្រូវបញ្ជាក់ពីអង្គហេតុ ហើយជូនពត៌មានទៅព្រះរាជអាជ្ញាក្នុងរយៈពេលយ៉ាងខ្លីបំផុត ប៉ុន្តែក្នុងករណីចៅក្រមស៊ើបសួរមិនសំរេចក្នុងរយៈពេល១៥ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមពាក្យសុំទៅឲ្យសភាស៊ើបសួរជំនួសចៅក្រមស៊ើបសួរ ប្រឆាំងលើបុគ្គលណាម្នាក់ ឬច្រើននាក់ ដោយមានចង្អុលបង្ហាញប្រាប់ឈ្មោះ ឬប្រឆាំងលើអញ្ញាតជន ដែលក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវបញ្ជាក់ពីអត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃរឿងក្តី ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ បង្ក្រាបបទល្មើស និងព្រមទាំងចង្អុលប្រាប់ពីតុលាការ ទីកន្លែង កាលបរិច្ឆេទ ម៉ោងពេលនៃសវនាការ[26]។

ព្រះរាជអាជ្ញាសុំឲ្យចៅក្រមស៊ើបសួរចោទប្រកាន់ ព្រមទាំងជាយថាហេតុឃុំខ្លួនជនសង្ស័យក្រោយពីបានពិនិត្យសំណុំរឿងពីនគរបាលយុត្តិធម៌រួច ធ្វើការរៀបចំដីកាសន្និដ្ឋានស្តាពរមួយទុកជាសេចក្តីផ្តើមចោទយោងតាមអង្គហេតុជាក់ស្តែង និងដែនកំណត់បទល្មើសស្របតាមបញ្ញាត្តិច្បាប់នីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣ វាក្យខណ្ឌទី២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២។

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹង និងមេធាវី ហើយ២ថ្ងៃក្រោយចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ក្នុងរយៈពេល១៥ថ្ងៃ ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួន និង ១ខែ ក្នុងករណី

[24] មាត្រា១២៧,២៤៧,២៤៩,២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[25] មាត្រា៤៤ និងមាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[26] មាត្រា៤៣-៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរ ក្នុងថិរវេលា ២៤ម៉ោង ដោយដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយ[27]។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ការស៊ើបសួរត្រូវបានបញ្ចប់ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលាក់អក្សរ និងមានសំអាងហេតុ បន្ទាប់មកព្រះរាជអាជ្ញាអាចប្តឹងទៅចៅក្រមស៊ើបសួរសំរេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬលើកលែងចោទប្រកាន់ មានចែងក្នុងមាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍បានកាលណាចៅក្រមស៊ើបសួរសម្រេចឲ្យដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះ ត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសំរាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាម។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់នោះ ជនត្រូវចោទដែលជាប់ឃុំ ត្រូវរក្សាទុកក្នុងពន្ធនាគាររហូតដល់សភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍[28]។

### **២.១.៤. ការឃុំខ្លួនក្នុងដំណាក់កាលចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរពត៌មានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅ របស់ជនត្រូវចោទដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួន ដូចជាជនត្រូវចោទជាអនីតិជន ជាស្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬជនត្រូវចោទចាស់ជរា។ល។ ក្នុងករណីបែបនេះបើអាចជៀសវាងបានមិនគួរគប្បីសម្រេចឃុំខ្លួនោះឡើយ[29]។

ជនសង្ស័យបន្ទាប់ពីចូលខ្លួនលើកដំបូងចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចថា ត្រូវឲ្យជនសង្ស័យឲ្យនៅក្រៅឃុំ ឬឃុំខ្លួនទុកជាបណ្តោះអាសន្ន ដោយគំនិតដោយផ្ទាល់ ឬក្រោយពីមានសេចក្តីសន្និដ្ឋានស្ថាពរបញ្ជូនសំណុំរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ព្រោះថាការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលត្រូវបានប្តឹងទៅចៅក្រមស៊ើបសួរ ដោយយោងតាមមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលណាម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ហើយការបើការស៊ើបសួរតាមដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿងឲ្យស៊ើប

---

[27] មាត្រា១៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[28] មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[29] សន្និសិទស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឆ្នាំ២០១២ ទំព័រ៥

ស្នួរដល់ចៅក្រមស៊ើបសួរ លុះត្រាតែមានសេចក្តីសង្ខេបនៃអង្គហេតុ ចង្អុលប្រាប់ឈ្មោះបទល្មើស បង្ហាញពីអត្ថបទច្បាប់ និងបង្ក្រាបបទល្មើស ឬឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ តាមការកំណត់ដោយមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាផង។ បើមិនគោរពតាមទម្រង់នេះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចាត់ទុកជាមោឃៈ ដែលជាហេតុនាំឲ្យគ្មានភស្តុតាងបញ្ជាក់ដល់ជនប្រព្រឹត្តបទល្មើសសំណុំរឿងត្រូវបានបញ្ចប់ (មានចែងក្នុងមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ការឃុំខ្លួនជនសង្ស័យ ឬចារី របស់ចៅក្រមស៊ើបសួរ គឺជាវិធានការចុងក្រោយបំផុតក្នុងការឃុំឃាំងជនល្មើសក្នុងមួយរយៈស៊ើបសួរភាគខ្លះ ឬទាំងស្រុង ទោះជាវិធានការនេះបានដកសិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងររបស់បុគ្គលក៏ដោយ តែវាជាការចាំបាច់អត់ឃុំមិនបាន ប្រសិនបើចៅក្រមយល់ឃើញថា៖

- ខ្លាចក្រែងជនសង្ស័យរត់គេចខ្លួន ដោយគ្មានអ្វីធានាបានថា ជនសង្ស័យប្រាកដជាមកបង្ហាញខ្លួនចំពោះមុខតុលាការវិញ ដែលបានដឹងថាខ្លួនត្រូវបានតុលាការចោទប្រកាន់ ឬក៏ធ្វើការគាបសង្កត់លើសាក្សី ដើម្បីរារាំងសំដែងឲ្យដឹងពីការពិតនោះ ឬគ្មានការងារធ្វើពិតប្រាកដ គ្មានគ្រួសារ គ្មានទីលំនៅមិនប្រាកដ ឬអាចរារាំងដល់ការចោទប្រកាន់ ការជំនុំជម្រះ ព្រមទាំងពិបាកក្នុងការអនុវត្តសាលក្រមទៀតផង ។

- ជាពិសេសមានលក្ខណៈងាយស្រួលដល់ការស៊ើបសួរ ស្វែងរកភស្តុតាងដាក់ ឬដោះបន្ទុកលើចារី ហើយងាយដំណើរការបញ្ចប់រឿងក្តី មានចែងក្នុងមត្រា១២៧ នៃក្រមនីតិធីព្រហ្មទណ្ឌ។

-ដោយមានសំណើសុំឲ្យធ្វើការឃុំខ្លួនជនត្រូវចោទឬជនជាប់ចោទតាមសំណើរបស់តំណាងអយ្យការអមតុលាការខេត្ត/ក្រុង ឬតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ជនរងគ្រោះ) ទៅចៅក្រមស៊ើបសួរ។

តាមបទពិសោធន៍និងការអនុវត្តជាក់ស្តែង ដែលអាចទទួលបានឃើញថា ការឃុំខ្លួនបណ្តោះអាសន្នត្រូវអនុវត្តដូចខាងក្រោម៖[30]

- ជនត្រូវចោទ ឬជនជាប់ចោទ គឺត្រូវឃុំខ្លួនបណ្តោះអាសន្ន

- ជនត្រូវចោទ ឬជនជាប់ចោទ ដែលបានប្រព្រឹត្តបទល្មើសជាបទឧក្រិដ្ឋ

- ជនត្រូវចោទ ឬជនជាប់ចោទ ដែលបានប្រព្រឹត្តបទមជ្ឈិម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ហើយមានសំអាងបញ្ជាក់ថាជននោះរត់គេចខ្លួន ឬបង្អាកដល់ដំណើរការស៊ើបសួរ ការជំនុំជម្រះពិបាកអនុវត្តសាលក្រម និងបន្តការប្រព្រឹត្តអំពើល្មើសទៀត។

តាមច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ចរិកនៃគ្រោះថ្នាក់ដល់សង្គមនៃការប្រព្រឹត្តបទល្មើស និងកំរិតនៃទោសដាក់ពន្ធនាគារដែលបានបញ្ញាត្តិក្នុងច្បាប់ព្រហ្មទណ្ឌ ពុំត្រូវបានលើកយកមកធ្វើ

[30] គន្ថីទី៤ ការស៊ើបសួរ មាតិកាទី១ ចៅក្រមស៊ើបសួរ ជំពូកទី៣ វិធានការនិរន្តរាយ ផ្នែកទី៥ ការឃុំខ្លួន និងផ្នែកទី៦ ដីកាបង្គាប់ឲ្យឃុំខ្លួន

ជាមូលដ្ឋានសំរាប់ការសម្រេចលើការឃុំខ្លួននោះទេ គឺជាក់ស្តែងតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថាៈ *មានតែចៅក្រមទេដែលជាអ្នកសម្រេចលើការឃុំខ្លួន ជនជាប់ចោទទុកក្នុងមន្ទីរឃុំឃាំង តាមសេចក្តីស្នើសុំរបស់ព្រះរាជអាជ្ញា ដែលបានបារម្ភខ្លាចក្រែង ជនត្រូវចោទរត់គេចខ្លួនដោយគ្មានការធានាបានថាជនជាប់ចោទប្រាកដជាត្រឡប់មកបង្ហាញខ្លួនចំពោះមុខតុលាការវិញ។*

ទោះបីជាការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងករណីខាងលើក៏ដោយ នោះចៅក្រមគប្បីពិចារណា ព្រមទាំងប្រើប្រាស់នូវវិធានការរាំងផ្សេងៗ ក្រៅពីការឃុំខ្លួនជាបណ្តោះអាសន្ន ចំពោះជនដែលត្រូវចោទ ឬជនជាប់ចោទ ដែលជានារីមានផ្ទៃពោះ ឬមានកូនបៅដោះ ក្រោមអាយុ១២ខែ នៅឡើយ ឬជាជនចាស់ជរា មានជម្ងឺជាទំងន់ដែលមានលំនៅច្បាស់លាស់ លើកលែងតែក្នុងករណីពិសេសចាំបាច់បំផុត ដូចជាអំពើល្មើសប្រព្រឹត្តយ៉ាងព្រៃផ្សៃ និងអមនុស្សធម៌។

ប៉ុន្តែក្នុងករណីមួយចំនួនច្បាប់ក៏មិនអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នបានដែរដូចជា

- ក្រោយពីបានធ្វើការស៊ើបសួរលើរឿងក្តីទៅឃើញថាជនដែលបានប្រព្រឹត្តអំពើល្មើស ជាបទល្មើសរដ្ឋប្បវេណី និងជាបទល្មើសផ្សេងក្រៅពីបទល្មើសព្រហ្មទណ្ឌ ឬមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់(ម.៤១ ក្រមព្រហ្មទណ្ឌ)។
- ជនល្មើសដែលមិនទទួលខុសត្រូវដោយមូលហេតុវិបល្លាស្មារតី (ម.៣១ក្រមព្រហ្មទណ្ឌ)។
- ជនដែលប្រព្រឹត្តអំពើល្មើសជាបទលហុ តែតុលាការផ្តន្ទាទោសជាប្រាក់ពិន័យវិញ
- ជនដែលបានអង្កេតចប់ទៅឃើញថា មិនបានប្រព្រឹត្តបទល្មើស
- ជនល្មើសជាអនីតិជន ដែលមានអាយុតិចជាង១៤ ឆ្នាំ (ម.២១២ នីតិវិធីក្រមព្រហ្មទណ្ឌ)។
- ជនល្មើសត្រូវបានអនុញ្ញាតដោយច្បាប់ ឫអាជ្ញាធរ (ម.៣២ នៃក្រមព្រហ្មទណ្ឌ)។
- ជនល្មើសត្រូវបានការការពារ និងសច្ចធារណ៍ស្របច្បាប់ (ម.៣៣-៣៤នៃក្រមព្រហ្មទណ្ឌ)។
- ជនល្មើសប្រព្រឹត្តក្នុងស្ថានភាពចាំបាច់ និងអានុភាពកំលាំងបង្ខំ(ម.៣៥-៣៦ក្រមព្រហ្មទណ្ឌ)
-ការមិនទទួលខុសត្រូវព្រហ្មទណ្ឌមិននាំឲ្យមានទណ្ឌកម្មណាមួយទេ(ម.៣៧ក្រមព្រហ្មទណ្ឌ)

## ២.២. សៀវភៅឃុំខ្លួនបណ្ដោះអាសន្ន

សៀវភៅឃុំខ្លួនត្រូវបានគ្រប់គ្រងដោយព្រះរាជអាជ្ញា។ សៀវភៅឃុំខ្លួនប្រើសំរាប់ចុះយកលេខថ្ងៃខែឆ្នាំ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ដីកាបង្គាប់ឲ្យឃុំខ្លួនបន្ត ដីកាសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងដីកាសម្រេចមិនឃុំរបស់ចៅក្រមស៊ើបសួរ ដោយក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរ ជាអ្នករៀបចំដីកាឃុំខ្លួនរួចសរសេរចូលទៅក្នុងសៀវភៅឃុំខ្លួន ដើម្បីយកលេខ ថ្ងៃខែឆ្នាំ ហើយរក្សាទុកក្នុងសំណុំរឿង និងសរសេរចុះក្នុងសៀវភៅទទួលបណ្តឹងព្រហ្មទណ្ឌ[31]។

[31] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ១៥៦-១៦០ ឆ្នាំ២០០៦

ដីកាឃុំខ្លួន ត្រូវសរសេរបំពេញចំនួនពីរច្បាប់ដូចៗគ្នា មួយច្បាប់ត្រូវបញ្ជូនទៅពន្ធនាគារជាមួយជនជាប់ចោទ តាមរយៈនគរបាលយុត្តិធម៌ ឬកងការពារពន្ធនាគារ ឬសមត្ថកិច្ចនាំជនល្មើសទៅមន្ទីរឃុំឃាំង និងមួយច្បាប់ទៀតត្រូវរក្សាទុកក្នុងសំណុំរឿងតំគល់ទុកនៅតុលាការរង់ចាំសេចក្តីសម្រេចដោះលែង ដោយដីកាដំណោះស្រាយពីតុលាការ។ តាមគោលការណ៍ក្រមនីតិវិធីព្រហ្មទណ្ឌគ្រប់រាល់ដីកាបញ្ជូនទាំងអស់ចំបាច់ត្រូវមានសរសេរបំពេញចំនួនពីដូចៗគ្នា ដោយមួយច្បាប់រក្សាទុកក្នុងសំណុំរឿង ហើយមួយច្បាប់ទៀតភ្ជាប់ជាមួយដីកាដែលបញ្ជូនចេញ។

ដីកាឃុំខ្លួនត្រូវធ្វើរៀបឡើងជាពីរច្បាប់ដូចៗគ្នាគឺដើមដីកានិងចុងដីកា ចំពោះដីកាដែលបញ្ជូនចេញត្រូវចុះហត្ថលេខាដោយជនដែលទទួលដីកា ហើយបង្វិលដើមដីកាមកតុលាការវិញ ដើម្បីទុកជាសក្ខីប័ណ្ណនៃសំណុំរឿង ហើយដាក់ក្នុងក្រូណូ ឬមាតិកាតាមតារាងលេខរៀងនៃលំដាប់[32]។

នៅមន្ទីរឃុំឃាំង ឬពន្ធនាគារមិនអាចទទួលពិរុទ្ធជន ឬអ្នកទោសបានទេ ប្រសិនបើគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនពីតុលាការបញ្ជូនមកជាមួយទេនោះ (មានចែងក្នុងមាត្រា១៧ នៃច្បាប់ពន្ធនាគារ)។

### ២.២.១. កំណត់ហេតុស្តីពីបញ្ជីជនជាប់ឃុំខ្លួនបណ្តោះអាសន្ន

គ្រប់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទាំងអស់ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទនៃការឃុំខ្លួន និងកាលបរិច្ឆេទនៃការដោះលែង ដែលបញ្ជីនេះត្រូវត្រួតពិនិត្យបានគ្រប់ពេលវេលា ត្រូវចុះទិដ្ឋាការដោយអយ្យការ។ គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ហើយភ្នាក់ងាររដ្ឋបាលពន្ធនាគារ ឬមណ្ឌលឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតអនុញ្ញាចេញពីអាជ្ញាធរតុលាការនោះឡើយ ប្រសិនបើមានការឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញពីអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធភាពពីបទបង្ខាំងមនុស្សដោយខុសច្បាប់ នៅពេលនោះគ្រប់ចៅក្រមទាំងអស់ ដែលទទួលបណ្តឹងស្តីការឃុំខ្លួន បុគ្គលណាម្នាក់ដោយខុសច្បាប់នោះ ត្រូវធ្វើការផ្ទៀងផ្ទាត់ជាការចាំបាច់ភ្លាម[33]។

### ២.២.២. ទំរង់ពិស្តារស្តីពីការឃុំខ្លួនបណ្តោះអាសន្ន

ដីកាឃុំខ្លួនចេញដោយចៅក្រម ដែលបញ្ជាក់ជាលាយលក្ខណ៍អក្សរ ត្រូវចុះនិទ្ទេសដូចជា៖

- លេខ ថ្ងៃ ខែ ឆ្នាំ ទទួលវត្ថុតាង
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- ឈ្មោះ និងសាវតាជាតិជនល្មើស
- បទល្មើស ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ប្រព្រឹត្តបទល្មើស និងអត្ថបទច្បាប់បង្ក្រាបបទល្មើស

[32] មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- វត្ថុតាង និងស្ថានភាពនៃវត្ថុតាង
- ឈ្មោះអ្នកទទួលវត្ថុតាង
- សេចក្តីសម្រេច
- សេចក្តីផ្សេងៗ

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រា មានចែងក្នុងមាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ២.៣. រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ

ជាគោលការណ៍ទូទៅការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ មិនឲ្យលើសពីរយៈពេល៦ខែបានទេ ហើយគ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តី ត្រូវតែបានទទួលការកាត់ក្តីយ៉ាងយូរ ៦ខែក្រោយពីការចាប់ខ្លួន[34]។

ចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនមិនឲ្យលើសពី១ ឆ្នាំបានទេ។ ប៉ុន្តែចៅក្រមស៊ើបសួរអាចពន្យាពេលឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ឆ្នាំ ដោយដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ហើយការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរនេះបានតែ២ដងគត់ ដោយយោងតាមមាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ការគិតថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះជនណាម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ថិរវេលានៃការឃុំខ្លួនត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបើមាន[35]។

### ២.៣.១. ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម

ការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ ក្នុងករណីបទឧក្រិដ្ឋចំពោះនីតិជន មិនត្រូវឲ្យលើសពីរយៈពេល ៦ខែឡើយ ប៉ុន្តែចៅក្រមអាចបន្តរយៈពេលនេះរហូតដល់ទៅ ៦ខែ ប្រសិនបើមានតម្រូវការចាំបាច់ក្នុងការស៊ើបសួរ។ ចៅក្រមត្រូវបញ្ជាក់អំពីហេតុផលនៃការពន្យាពេលនេះឲ្យបានច្បាស់លាស់[36]។

ប្រសិនបើការឃុំខ្លួនហួសរយៈពេលកំណត់ជនជាប់ចោទត្រូវតែបានដោះលែង បើទោះបីជាការស៊ើបសួរមិនទាន់ចប់សព្វគ្រប់ហើយក៏ដោយ។ យើងអាចបញ្ជាក់ឲ្យបានច្បាប់ថា នៅក្នុង

---

[33] មាត្រា៥០៥-៥០៩ នៃនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[34] មាត្រា២០៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២១.១នៃក្រមព្រហ្មទណ្ឌអន្តរកាល១៩៩២

[35] មាត្រា១៩៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៥១ នៃក្រមព្រហ្មទណ្ឌ

[36] មាត្រា២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

កាលៈទេសៈបែបនេះបណ្តឹងអាជ្ញាមិនអាចបន្តបានទេ ហើយត្រូវតែបានបញ្ចប់។ គ្រប់ជនជាប់ពិរុទ្ធ ទោះជាប់ឃុំក្តី ឬមិនជាប់ឃុំក្តីត្រូវតែបានទទួលការកាត់ក្តីយ៉ាងយូរបំផុត៦ខែក្រោយពីថ្ងៃចាប់ខ្លួន[37]។

ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ក្នុងករណីបទមជ្ឈិម ការឃុំខ្លួនមិនឲ្យលើស ៤ខែបានទេ។ នៅពេលផុតថិរវេលានៃការឃុំខ្លួន ចៅក្រមអាចពន្យាពេលឃុំខ្លួនបានតែម្តងគត់មិនឲ្យលើស២ដងទេ ដោយដីកានេះមានសំអាងហេតុច្បាប់លាស់ ថិរវេលានៃការឃុំខ្លួននេះមិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ[38]។

## ២.៣.២. ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ករណីបទឧក្រិដ្ឋ ឬបទមជ្ឈិម

អនីតិជនត្រូវបានពិចារណាលើអាយុរបស់គេ និងតម្រូវលើកស្ទួយការស្តារនីតិសម្បទាដោយធានាកិច្ចការពារក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវជំនុំជំរះឲ្យបានឆាប់រហ័សក្នុងសវនាការត្រឹមត្រូវនៅចំពោះមុខមេធាវី ជំនួយស្របច្បាប់ដទៃទៀត និងឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់គេ លុះត្រាតែទង្វើនោះត្រូវបានចាត់ទុកថា បម្រើឲ្យឧត្តមប្រយោជន៍របស់កុមារ ជាពិសេសត្រូវពិចារណាលើអាយុ ឬស្ថានភាពរបស់គេ ការឃុំខ្លួនបណ្តោះអាសន្ន គួរតែត្រូវជៀសវាងឲ្យអស់ពីលទ្ធភាពបំផុត។ រដ្ឋគួរតែចាត់វិធានការនានា ដើម្បីបង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជនដ៏សមស្របមួយដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដូចជាការសម្រុះសម្រួលរវាងជនល្មើស និងជនរងគ្រោះ ការប្រឹក្សាយោបល់ ឬដាក់ស្ថិតក្រោមកម្មវិធីអប់រំរបស់ជនល្មើសអនីតិជន[39]។

អនីតិជនអាយុតិចជាង ១៤ឆ្នាំមិនអាចឃុំខ្លួនបណ្តោះអាសន្នបានទេ ចៅក្រមស៊ើបសួរអាចសម្រេចឲ្យអនីតិជននេះឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាលត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំកែប្រែថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ[40]។ អនីតិជនដែលមានអាយុ១៤ដល់១៨ឆ្នាំមិនអាចជាប់ឃុំឃាំងបណ្តោះអាសន្នលើសពី១ខែឡើយ[41]។ ប៉ុន្តែការឃុំខ្លួនអនីតិជនក្រោម១៨ ឆ្នាំមិនត្រូវឃុំខ្លួនជាមួយនីតិជនបានឡើយ។

អនីតិជនដែលត្រូវឃុំខ្លួន មិនត្រូវទទួលរងទណ្ឌកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ ឬទង្វើណាមួយដែលនាំឲ្យខូចខាតដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ។ អនីតិជនដែលត្រូវស្ថិតនៅក្នុងការឃុំខ្លួនត្រូវទទួលបានការថែទាំប្រកបដោយមនុស្សធម៌ ហើយគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើតរបស់មនុស្ស[42]។

[37] សៀវភៅពិភាក្សាព្រហ្មទណ្ឌច្បាប់កម្ពុជា (និពន្ធដោយៈ ស្វួត ខូហៀល) ទំព័រ២០៤

[38] មាត្រា២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[39] សេចក្តីពន្យល់ទូទៅលេខ៣២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ ទំព័រ៥៨-៦០

[40] មាត្រា២១២ នៃនីតិវិធីក្រមព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[41] មាត្រា១៤.៥ វាក្យខណ្ឌ២ នៃក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២

[42] សេចក្តីណែនាំលេខៈ១ ក.យ.សណន/ ០៩ .០៦ .២០០៥ របស់ក្រសួងយុត្តិលការណ៍ធម៌ ស្តីពីគោការណ៍យុត្តិធម៌អនីតិជន

ការឃុំខ្លួនអនីតិជនទាក់ទងបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលមានអាយុ១៤ដល់១៨ឆ្នាំមាន៖

+ ការឃុំខ្លួនអនីតិជនមានអាយុចាប់ពី១៤ដល់១៦ ឆ្នាំមានពីករណី

- ក្នុងករណីបទឧក្រិដ្ឋការឃុំខ្លួនមិនឲ្យលើសពី៤ ខែបានទេ
- ក្នុងករណីបទមជ្ឈឹមការឃុំខ្លួនមិនឲ្យលើសពី២ ខែបានទេ

+ ការឃុំខ្លួនអនីតិជនមានអាយុចាប់ពី១៦ដល់១៨ ឆ្នាំមានពីករណី

- ក្នុងករណីបទឧក្រិដ្ឋការឃុំខ្លួនមិនឲ្យលើសពី៦ ខែបានទេ
- ក្នុងករណីបទមជ្ឈឹមការឃុំខ្លួនមិនឲ្យលើសពី៤ ខែបានទេ

### ២.៣.៣. ឧប្បត្តិហេតុនៃការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឲ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់ចម្លើយរបស់ជននេះ កាលណាជនត្រូវចោទមានមេធាវីអម មេធាវីត្រូវបង្ហាញមធ្យោបាយការពារកូនក្តីរបស់ខ្លួន ដើម្បីឲ្យរួចផុតពីការចោទប្រកាន់ពីបទល្មើស និងមានសេរីភាពត្រឡប់ទៅរស់នៅក្នុងសង្គមវិញ[43]។

ចៅក្រមស៊ើបសួរពន្យាពេលការឃុំខ្លួនបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុព្រោះថាបទល្មើសមួយអាចមិនទាន់មានធាតុផ្សំគ្រប់គ្រាន់ក្នុងការបិទការស៊ើបសួរទេ ហេតុនេះចៅក្រមបន្តការឃុំខ្លួនក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកលើជនជាប់ឃុំ ដោយចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិមាត្រា២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) ប៉ុន្តែក្នុងករណីហួសរយៈពេល៦ខែនៃការឃុំខ្លួន ឬហួសនៃការពន្យាពេលឃុំខ្លួន ទោះបីបានសម្រេចលទ្ធផល ឬមិនសម្រេចលទ្ធផលក្តី ចៅក្រមស៊ើបសួរមិនអាចឃុំខ្លួនបន្តទៀតបានទេ[44]។

ជាគោលការណ៍នៃក្រមនីតិវិធីព្រហ្មទណ្ឌ សច្ចធារណ៍នៃទោស គឺសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលការជំនុំជម្រះដោយមិនពន្យាលពេលយូរផ្អែកតាមច្បាប់ ប៉ុន្តែការជំនុំជម្រះជនត្រូវចោទត្រូវធ្វើឡើងក្នុងរយៈពេល ៦ខែ គិតចាប់តាំងពីពេលចាប់ខ្លួន មានន័យថាការឃុំខ្លួនជនជាប់ចោទ ឬជនត្រូវចោទបណ្តោះអាសន្នមិនលើសពី៦ខែឡើយ ប្រសិនបើលើអំឡុងពេល ៦ខែមន្រ្តីដែលឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទ លើសរយៈពេលកំណត់ដោយច្បាប់យ៉ាងណានោះ គឺរំលោភលើសិទ្ធិរបស់ជនជាប់ចោទ ហេតុនេះអាចត្រូវផ្តន្ទាទោសជននេះបាន ចំណែកឯជនជាប់ចោទត្រូវទទួលការដោះលែង ឬយ៉ាងហោចណាស់យើងនិយាយតវ៉ាឲ្យលើកលែងចោទប្រកាន់។ មូលដ្ឋានសំខាន់មួយនៃគោលការណ៍ទាំងនេះ គឺការសន្មតថាគ្មានទោស ប្រសិនបើជនជាប់ចោទត្រូវបាន

[43] មាត្រា២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[44] មាត្រា២០៨-២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

សន្មតថាគ្មានទោសរហូតដល់មានសាលក្រមស្ថាពរ ដូចនេះការពន្យាពេលដើម្បីការស៊ើបសួរនិង/ឬឃុំខ្លួនហួសកំណត់ដោយមិនបើកសវនាការ គឺជាការរំលោភបំពានមួយ ដែលមិនសមហេតុផល និងជាការរំលោភលើសិទ្ធិរបស់បុគ្គលផងដែរ[45]។

ការពន្យាលពេលក្នុងការនាំខ្លួនជនជាប់ចោទមកសវនាការ គឺរំលោភសិទ្ធិមនុស្សជាមូលដ្ឋានរបស់បុគ្គលដល់ដំណើរការសវនាការដោយយុត្តិធម៌ពីព្រោះវាអាចមានបុរេវិនិច្ឆ័យចំពោះសមត្ថភាពជនជាប់ចោទក្នុងការបង្ហាញនូវការការពារប្រកបដោយមានប្រសិទ្ធិភាព ក្នុងករណីនេះដែរធ្វើឲ្យមានសាក្សីសំខាន់ៗអាចត្រូវបានបាត់បង់ ឬស្លាប់ ភស្តុតាងអាចបាត់បង់ការចងចាំរបស់សាក្សីអំពីឧប្បទ្ទវហេតុមិនអាចគួរឲ្យជឿបាន ដោយរយៈពេលនៃការជំនុំជម្រះ អាចឲ្យការជំនុំជម្រះមិនអាចប្រកបដោយភាពយុត្តិធម៌បាន ដូចនេះច្បាប់របស់កម្ពុជាបានកំណត់ថាជនជាប់ចោទត្រូវជំនុំជម្រះក្នុងអំឡុងពេល៦ខែ បន្ទាប់ពីចាប់ខ្លួនយ៉ាងយូរ[46]។

កាលណាជនត្រូវចោទមានអាយុចាប់ពី១៨ ឆ្នាំឡើង ការឃុំខ្លួនបណ្ដោះអាសន្នបទឧក្រិដ្ឋ ត្រូវពន្យាពេលបាន ២ដង ក្នុងម្ដងបាន ៦ខែ ដោយឡែកការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទមជ្ឈឹមអាចពន្យាពេលបានម្ដងគត់ ដោយពន្យាពេលបាន២ខែ (មាត្រា២០៩-២០៨) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ថិរវេលានៃការឃុំខ្លួនចំពោះបទមជ្ឈឹម ដែលប្រព្រឹត្តដោយជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលកំណត់ដោយច្បាប់ឡើយ[47]។ ប៉ុន្តែចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបាន ២ដងគត់(មាត្រា២១០) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

តារាងខាងក្រោមបង្ហាញពីថិរវេលាអតិប្បបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន សំរាប់ប្រភេទទោសនីមួយៗនៃរឿងក្ដី[48]។

[45] សេចក្ដីពន្យល់នៃមាត្រាទាំងឡាយនៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនឹងការសម្រេចការឃុំខ្លួនបណ្ដោះអាសន្ន ឆ្នាំ២០១៤

[46] មាត្រា២០៨ នៃនីតិវិធីក្រមព្រហ្មទណ្ឌចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧ និងសិទ្ធិបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាទំព័រ២៣-២៥ ឆ្នាំ២០១២

[47] មាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧

[48] សេចក្ដីពន្យល់នៃមាត្រានៃទាំងឡាយនៃក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ទំព័រ៥៦-៥៨ ឆ្នាំ២០១៤

| ប្រភេទនៃបទល្មើស និងមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យាថិរវេលាឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ-មាត្រា២០៨ | ១៨ ឬនីតិជន | ៦ខែ | ៦ខែ+៦ខែ |
| បទមជ្ឈឹម-មាត្រា២០៩ | ១៨ ឬនីតិជន | ៤ខែ | ២ខែ-ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ-មាត្រា២១៣ | ១៤-១៦ ឆ្នាំ | ៤ខែ | មិនអាចពន្យាពេលឃុំខ្លួនបានទេ |
| បទមជ្ឈឹម-មាត្រា២១៤ | ១៤-១៦ ឆ្នាំ | ២ខែឬ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់អនីតិជន(ថិរវេលាមួយណាក៏បានដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យាពេលឃុំខ្លួនបានទេ |
| បទឧក្រិដ្ឋ-មាត្រា២១៣ | ១៦-១៨ ឆ្នាំ | ៦ខែ | មិនអាចពន្យាពេលឃុំខ្លួនបានទេ |
| បទមជ្ឈឹម-មាត្រា២១៤ | ១៦-១៨ ឆ្នាំ | ៤ខែឬ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់អនីតិជន(ថិរវេលាមួយណាក៏បានដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យាពេលឃុំខ្លួនបានទេ |

## ២.៤. សិទ្ធិមានមេធាវីសង្គ្រោះផ្នែកច្បាប់បន្ទាប់ពីឃុំខ្លួន

សិទ្ធិពឹងពាក់មេធាវីត្រូវបានធានាជនគ្រប់រូប ដែលជាប់ចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយហេតុថាជនត្រូវចោទទាំងអស់មិនមែនសេរីភាពជាមូលដ្ឋានផ្នែកច្បាប់ដូចមេធាវីឡើយ ទោះជនត្រូវចោទខ្លះជាអ្នកច្បាប់ក៏ដោយ ព្រោះនៅពេលមានការចោទប្រកាន់ខ្លួន ឬជននេះមិនមានសេរីភាពដូចមេធាវីដែលជាជនវិជ្ជាជីវៈក្នុងវិស័យច្បាប់ មានលក្ខណៈគ្រប់គ្រាន់ក្នុងការប្រើសិទ្ធិសេរីភាពពេញបរិបូរណ៍ទេ។ ម្យ៉ាងទៀតនៅពេលជនណាម្នាក់ត្រូវចោទប្រកាន់ខ្លួនត្រូវបានគេដកហូតនៅសិទ្ធិសេរីភាពមួយចំនួនដែលខ្លួនបានធ្វើសកម្មភាពឡើងនៅពេលប្រព្រឹត្តបទល្មើស ដូចនេះទើបគេផ្តល់សិទ្ធិឲ្យជនត្រូវចោទពឹងពាក់មេធាវី ទីប្រឹក្សាជនត្រូវចោទតាមលក្ខន្តិកៈមេធាវី[49]។

សិទ្ធិមានមេធាវីធានាថាជនជាប់ចោទមានឱកាសក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈពីអ្នកជំនាញខាងតស៊ូមតិ ដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ពន្យល់ពីសិទ្ធិណែនាំពីដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ខ្លួននៅក្នុងតុលាការ។ ជាសេចក្តីតម្រូវការសម្រាប់បុគ្គលម្នាក់ត្រូវទទួលបានមេធាវី ប្រសិនបើបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬក៏ជននោះជាអនីតិជន។ នៅខណៈដែលពុំមានការតម្រូវដោយច្បាប់ចំពោះការទទួលបានមេធាវី ប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ជននោះនៅតែមានជម្រើសមានមេធាវីបើខ្លួនត្រូវការ[50]។

ក្នុងការសម្រេចចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដែលបញ្ជាក់ពីៈ

- ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។
- ការពារខ្លួនដោយផ្ទាល់ខ្លួន ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន។
- ត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់។
- ត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ[51]។

ចំពោះគោលបំណងនៃការពារខ្លួននេះត្រូវអនុញ្ញាតឲ្យអ្នកទោស ដែលមិនទាន់បានទទួលការកាត់ទោសរកជំនួយផ្នែកតុលាការ ដូចជាអ្នកច្បាប់ ឬស្មាក្តីជាដើម ដើម្បីការពារខ្លួនគេ។ ហើយ

[49] សៀវភៅពិភាក្សាព្រហ្មទណ្ឌ ច្បាប់កម្ពុជា ទំព័រ ២៤៦-២៥៦

[50] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ឆ្នាំ២០១២-២០១៣ ទំព័រ៣៣-៣៦

[51] រដ្ឋធម្មនុញ្ញមាត្រា៣១ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤ កថាខណ្ឌ៣ ឆ្នាំ១៩៦៦

ត្រូវអនុញ្ញាតឲ្យទីប្រឹក្សាច្បាប់ចូលជួបអ្នកទោសទាំងនេះ ក្នុងគោលដៅរៀបចំការការពារខ្លួនសំរាប់ថ្ងៃកាត់សេចក្តីនៅមុខតុលាការ។ ទីប្រឹក្សាច្បាប់របស់អ្នកទោសម្នាក់ៗ អាចផ្តល់ឯកសារសំងាត់ផ្សេងៗឲ្យអ្នកទោសដែលគេការពារ។ ឯការសំភាសន៍រវាងទីប្រឹក្សា និងអ្នកទោស អាចប្រព្រឹត្តទៅបាននៅក្នុងមន្ទីរឃុំឃាំង ក្នុងស្ថានភាពដែលពួកតំរួតប្រចាំមន្ទីរអាចមើលឃើញ តែមិនអាចស្តាប់ឮនូវការពិភាក្សានេះទេ មានចែងក្នុងមាត្រា៩៣ នៃបទបញ្ញាតិជាបទដ្ឋានអប្បបរិមាសំរាប់ការគ្រប់គ្រងអ្នកទោស។

ជនជាប់ឃុំមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវី ដូចមានចែងក្នុងច្បាប់។ ជនជាប់ឃុំត្រូវទទួលបានការជូនដំណឹងភ្លាមអំពីសិទ្ធិត្រូវមានមេធាវី ពីអាជ្ញាធរមានសមត្ថកិច្ច បន្ទាប់ពីការចាប់ខ្លួន ហើយត្រូវឃុំខ្លួនក្នុងទីកន្លែងសមរម្យ។ ប្រសិនជនជាប់ឃុំមិនទាន់មានសិទ្ធិ ឬមិនអាចមានលទ្ធភាពរកមេធាវីដោយខ្លួនឯងបាន នោះជនជាប់ឃុំអាចទទួលមេធាវី ដែលចាត់តាំងដោយអាជ្ញាធរដ៏ទៃទៀត ដោយគ្មានការបង់ថ្លៃ ដើម្បីជាប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌។ ជនជាប់ឃុំឃាំងមានសិទ្ធិទំនាក់ទំនងជាមួយនឹងអ្នកតំណាងស្របច្បាប់របស់ខ្លួនបានគ្រប់ពេលវេលា ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយនឹងអ្នកតំណាងស្របច្បាប់របស់ខ្លួន ត្រូវស្ថិតនៅកន្លែងដែលមានការការពារ ប៉ុន្តែមិនអាចស្តាប់ឮបានឡើយ ពីមន្ត្រីអនុវត្តច្បាប់។ ការទំនាក់ទំនងរវាងជនជាប់ឃុំ និងអ្នកតំណាងស្របច្បាប់ មិនអាចទទួលយកជាភស្តុតាងសំរាប់ប្រឆាំងទៅលើជនជាប់ឃុំបានឡើយប្រសិនបើការពិភាក្សានោះ មិនពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសថ្មីណាមួយនោះទេ[52]។

### ២.៤.១. សិទ្ធិវិជ្ជាជីវៈរបស់មេធាវី

មេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបំរើវិស័យយុត្តិធម៌។ វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី មានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី មាត្រា១។

មេធាវីជាជំនួយផ្នែកច្បាប់ ដែលជាភាគីតែមួយគត់ក្នុងរឿងក្តីព្រហ្មទណ្ឌ មានវិជ្ជាជីវៈក្នុងវិស័យច្បាប់ច្បាស់លាស់ គឺដើម្បីការពារជនត្រូវចោទក្នុងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជាយោងតាមច្បាប់។

មេធាវីតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីច្បាប់ លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្ទុយពីនេះ ជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ និងសង្គមកិច្ច។ ក្នុងរឿងព្រហ្មទណ្ឌ មេធាវីការពារជនជាប់ចោទ ហើយមិនអាចតំណាងជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទប្បញ្ញត្តិពិសេសនៃច្បាប់។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីបាន[53]។

[52] គោលការណ៍អន្តរជាតិស្តីពីការការពារដល់គ្រប់ជនដែលទទួលការឃុំខ្លួន មាត្រា ១១,១៧.១៨

[53] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីមាត្រា២

កាលណាជនដែលត្រូវគេចោទប្រកាន់មានសិទ្ធិទទួលបានជំនួយពីមេធាវី នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើជនជាប់ចោទមិនមានភាពច្បាស់លាស់តាមច្បាប់ ឬមិនមានការយល់ដឹងអំពីភាពស្មុកស្មាញក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ ដែលត្រូវបានគេចោទប្រកាន់ ឬស្ថិតក្រោមការស៊ើបសួរត្រូវមានជំនួយតាមផ្លូវច្បាប់ភ្លាម។ ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់ អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ លើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខរបររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត។

### ២.៤.២. សិទ្ធិមានមេធាវីក្រោយការសម្រេចលើការឃុំខ្លួន

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ មានចែងក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ។

សិទ្ធិពឹងពាក់មេធាវីត្រូវបានធានាជូនជនគ្រប់រូប ដែលជាប់ចោទពីបទមជ្ឈិម ឬបទឧក្រិដ្ឋ[54]។ ទោះបីជាបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវទទួលការឃាត់ខ្លួនលើសរយៈពេល៤៨ម៉ោង ដោយគ្មានបានទទួលជំនួយមេធាវីឡើយ ហើយក៏គ្មានជនណាម្នាក់ជាប់ឃុំនៅលើទឹកដីកម្ពុជាលើសពី៤៨ម៉ោង ដោយគ្មានជំនួយទីប្រឹក្សាច្បាប់ពីមេធាវី ឬអ្នកតំណាងដែលច្បាប់បានអនុវត្តទេ បន្ទាប់ក្រោយពីឃុំខ្លួន២៤ម៉ោងកន្លងផុតទៅ មេធាវីអាចចូលជួបកូនក្តីរបស់ខ្លួនបានរយៈពេល៣០នាទី ដោយរក្សាការសំងាត់នៃការសន្ទនា ឬកត់ត្រានោះទេ[55]។ ហើយមេធាវីអាចបើកសំណុំរឿងក្តីតាំងពីដំបូង និងថតចំលងសំណុំរឿងទាំងអស់បាន។ ប៉ុន្តែមេធាវីមិនអាចឲ្យលិខិតថតចំលងនៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានឡើយ មានចែងក្នុងមាត្រា១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មេធាវីជាភ្នាក់ងារដ៏សំខាន់ក្នុងប្រព័ន្ធយុត្តិធម៌ ដែលមានគោលដៅចំបងការពារដេញដោលដោះបន្ទុកលើការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួននៅគ្រប់ដំណាក់កាលទាំងអស់ក្នុងរឿងក្តីព្រហ្មទណ្ឌ ចាប់តាំងពីពេលចាប់ឃាត់ខ្លួន ឬឃុំខ្លួនរហូតដល់ដំណាក់កាលបើកសវនាការជំនុំជម្រះនៃការបញ្ចប់រឿងក្តីជាស្ថាពរ[56]។

ចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញាត្រូវប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ហើយដើមបណ្តឹងក៏អាចត្រូវតំណាងដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់បានដែរតែត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលាក់អក្សរ តាំងពីជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង[57]។

---

54 មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

55 មាត្រា៥១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

56 មាត្រា៩៨,៣៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងមាត្រា៣១ នៃច្បាប់ស្តីពីពន្ធនាគារ

57 មាត្រា១៤៣ក.ខ៣,៣១៣-៣១៤,៣៣០៤ក.ខ៣,៤ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ១០ /០៧/២០០៧ និងមាត្រា២០ក.១ នៃច្បាប់ស្តីពីពន្ធនាគារ

កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅយ៉ាងតិចបំផុត ៥ថ្ងៃមុនការស៊ើបសួរ ហើយជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ក្នុងថិរវេលានេះមេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធីបាន ប៉ុន្តែប្រសិនបើមេធាវីដែលបានកោះហៅត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរក៏អាចសួរចំលើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវីបាន ដោយចុះនិទ្ទេសស្តីពីការអវត្តមាននេះក្នុងកំណត់ហេតុសួរចំលើយជនត្រូវចោទ បន្ទាប់ពីជនត្រូវចោទចុះហត្ថលេខាយល់ព្រម។ តែក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចសួរចំលើយជនត្រូវចោទ ដោយមិនចាំចាច់កោះហៅមេធាវីបានដែរ បណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុងនៃភស្តុតាង ដោយចុះក្នុងកំណត់ហេតុ[58]។

### ២.៤.៣. សិទ្ធិមានមេធាវីចំពោះអនីតិជនលើការឃុំខ្លួន

ចំពោះជនជាប់ចោទជាអនីតិជន ឬជនជាប់ចោទជាមនុស្សគ ថ្លង់ មនុស្សខ្វាក់ វិបត្តិស្មាតីត្រូវតែមានមេធាវីអមជានិច្ច ទោះជាគ្មានការជ្រើសរើសដោយជនជាប់ចោទក៏ដោយ មេធាវីត្រូវចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីអំពីលក្ខន្តិកៈមេធាវី អាជ្ញាធរមានសមត្ថកិច្ចត្រូវតែជូនពត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ចែងក្នុងមាត្រា១៤៣ កថាខណ្ឌ៥ មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនិងមាត្រា៧៦ នៃច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ។

កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗនូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត។ ហើយការដែលកុមារជាប់សង្ស័យ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសនិងច្បាប់ព្រហ្មទណ្ឌ យ៉ាងហោចណាស់ត្រូវទទួលបាននូវការធានាដូចតទៅ៖

- ផ្តល់ទីប្រឹក្សាខាងផ្លូវច្បាប់ ឬជំនួយសមស្របផ្សេងៗទៀត សម្រាប់ការរៀបចំ និងបង្ហាញនូវការការពារដល់កុមារ។
- ត្រូវទទួលការសាកសួរភ្លាមនៅចំពោះមុខទីប្រឹក្សាច្បាប់ ឬជំនួយសមស្របផ្សេងទៀតមាន

ក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ត្រូវការពារសិទ្ធិ និងសុវត្ថិភាព និងលើកស្ទួយសុខមាលភាពរាងកាយ និងសតិស្មារតីរបស់អនីតិជន។ ការដាក់គុកត្រូវប្រើជាមធ្យោបាយចុងក្រោយបង្អស់[59]។

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី

[58] មាត្រា១៤៥,១៥០,២៣៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧និងម.៧៧នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩២

[59] សេចក្តីណែនាំលេខ ០១ ក.យ.សណន ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៥ របស់ក្រសួងយុត្តធម៌ ស្តីពីគោលការណ៍យុត្តិធម៌អនីតិជន

១៨ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ[60]។ ដែលនៅក្នុងវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធាការឧបត្ថម្ភមានដូចជា៖[61]

១/ការប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងមានទំនុកចិត្ត។

២/ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣/ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤/ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥/ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ហើយក្រៅពីរក្សានៅក្នុងមន្ទីរអប់រំ មានបញ្ញាត្តិគ្រប់គ្រងជាច្រើនទៀត ដូចជាការថែទាំ ការតម្រែម្រង់ និងការពិនិត្យគ្រប់គ្រង ការផ្តល់មតិទូន្មាន ការសាកល្បង ការដាក់ឲ្យរស់នៅតាមគ្រួសារ កម្មវិធីអប់រំទូទៅ និងអប់រំវិជ្ជាជីវៈព្រមទាំងដំណោះស្រាយផ្សេងទៀតដែលអាចប្រើប្រាស់បានដើម្បីធានាថាកុមារត្រូវបានទទួលការថែទាំសមស្របជាមួយនឹងផាសុខភាពរបស់ខ្លួន។

## ផ្នែកទី២៖ នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដោយចៅក្រមជំនុំជម្រះ

ការឃុំខ្លួនមិនត្រូវបានអនុវត្តតាមតែអំណាចរបស់ចៅក្រមស៊ើបសួរនោះទេ ត្រូវឆ្លងកាត់ចៅក្រមជំនុំជម្រះជាដាច់ខាតក្នុងករណីបទឧក្រិដ្ឋ ចំពោះបទមជ្ឈឹមការដែលមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ល្មម អាចធ្វើការបញ្ជូននៅជម្រះភ្លាម ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់។ មានន័យថា គឺជាបញ្ហាដល់ជនជាប់ចោទឲ្យចូលខ្លួននៅតុលាការជាន់ដំបូង ដែលសម្រេចពីរឿងក្តីព្រហ្មទណ្ឌ។

### កថាខណ្ឌ១. ការសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន

មានតែចៅក្រមស៊ើបសួរប៉ុណ្ណោះទេមានសិទ្ធិសម្រេចឃុំខ្លួន ឬមិនឃុំខ្លួនតាមគំនិតផ្ទាល់ខ្លួន តាមយោបល់របស់ព្រះរាជអាជ្ញា។ ហេតុសម្រេចលើការឃុំខ្លួនមាននីតិវិធីដូចជា៖ នីតិវិធីមុនសវនាការ នីវិធីមុនអង្គសេចក្តី និងនីវិធីក្នុងអង្គសេចក្តី។

#### ១.១. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

ក្នុងករណីនេះ តុលាការជាន់ដំបូងទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលខ្លួនភ្លាម។ ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលការបង្ហាញខ្លួននេះត្រូវប្រព្រឹត្តនៅថ្ងៃនោះតែម្តង(មាត្រា៣០៤ និង៤៧)។

នៅពេលបង្ហាញខ្លួន តុលាការធ្វើចំណាត់ការដូចតទៅ៖

---

[60] មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- ពិនិត្យអត្តសញ្ញាណលើបុគ្គលដែលជាប់ចោទ

- ពិនិត្យមើលរបាយការណ៍សង្ខេបរឿងរបស់ជនជាប់ចោទ

- ប្រាប់ដល់ជនជាប់ចោទ អំពីការចោទប្រកាន់ និងរៀបចំការពារខ្លួន។ ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងនោះមិនអាចទាន់ជំនុំជម្រះបាន ត្រូវលើកទៅសវនាការក្រោយទៀត ក្នុងករណីនេះតុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នតាមសាលក្រមដោយមានសំអាងហេតុ និងចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដោយផ្អែកលើដីកាសម្រេចឲ្យឃុំខ្លួន។

ប្រសិនបើតុលាការយល់ឃើញថា នីតិវិធីពុំត្រឹមត្រូវតាមលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ក្នុងករណីនេះ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួនចំពោះចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តង។ បើពុំដូច្នេះទេជនជាប់ចោទត្រូវតែដោះលែងឲ្យមានសេរីភាពវិញដោយខ្លួនឯង(មាត្រា៣០៤)។

### ១.២. នីតិវិធីមុនអង្គសេចក្តី

កាលណាតុលាការទទួលបានសំណុំរឿងតាមដីកាសន្និដ្ឋានស្ថាពរបញ្ជូនរឿង ឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាហើយ ចៅក្រមស៊ើបសួរចាត់នីតិវិធីលើរឿងក្តីនោះ ដោយករណីបទឧក្រិដ្ឋមានភាពស្មុគស្មាញ ឬមានភាពជាក់ស្តែងចំពោះរឿងក្តីណាមួយ ធ្វើឲ្យចៅក្រមចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន តាមសាលក្រមដែលមានទម្រង់ច្បាប់ និងសំអាងហេតុ។សាលក្រមលើអង្គសេចក្តីនោះត្រូវប្រកាសក្នុងរយៈពេលមិនឲ្យលើសពី២សប្តាហ៍ គិតពីថ្ងៃនៃការចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខតុលាការ តែប្រសិនបើផុតរយៈពេល២សប្តាហ៍ហើយ ត្រូវដោះលែងឲ្យមានសេរីភាពវិញ[62]។

ការឃុំខ្លួនទៅលើជនសង្ស័យក្រោយពីបង្ហាញខ្លួនលើកដំបូងនេះ ដោយធ្វើការបើកអង្គសវនាការតូចមួយ ដើម្បីសម្រេចឃុំខ្លួន ទោះក្នុងករណីជាក់ស្តែងដែលមានសំអាងហេតុបញ្ជាក់គ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់លើជនល្មើសក៏ដោយ ព្រោះដើម្បីធានានីតិវិធីក្នុងការដំណើរការរឿងក្តីបានល្អ បន្ទាប់ចៅក្រមធ្វើសម្រេចឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការពេញអង្គ ក្រោយពីបញ្ចប់អង្គសវនាការស្តាប់ហេតុផលតូចមួយ ចៅក្រមចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនល្មើស ដោយយោងទៅលើដីកាសម្រេចឲ្យឃុំខ្លួនតាមសំអាងហេតុ ដីកាបង្គាប់ឲ្យចាប់ខ្លួនពីព្រះរាជអាជ្ញា ផ្អែកលើកំណត់ហេតុសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាមូលដ្ឋានឲ្យចៅក្រមចេញដីកាបង្គាប់ឃុំខ្លួនភ្លាមនៅថ្ងៃដែល

---

[61] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[62] មាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

គេបញ្ជូនជនជាប់ចោទ ឬជនសង្ស័យដល់តុលាការ។ ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវភ្ជាប់ទៅជាមួយជនត្រូវចោទ ប្រគល់ឲ្យទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ ឬតាមសេនាធិការ ឬឆ្មាំគុករបស់ប្រធានពន្ធនាគារ រក្សាទុកជនសង្ស័យរហូតរង់ចាំអង្គសវនាការ ក្រោយពីចៅក្រមស៊ើបសួរបិទសំណុំរឿងបញ្ជូនទៅជម្រះ[63]។

## ១.៣. នីតិវិធីក្នុងអង្គសេចក្តី

ក្រោយពីបានចេញដីកាបង្គាប់ឲ្យឃុំខ្លួនមិនឲ្យលើស ២ខែសប្តាហ៍មកចៅក្រមស៊ើបសួរនិងបន្តនីតិវិធី ជដែកវែកញែកសួរដេញដោលរកហេតុផលលើជនជាប់ឃុំ ឬសាក្សី ឬស្វែងរកភស្តុតាងដើម្បីបញ្ជាក់ពីបទល្មើសរបស់ជនរងគ្រោះអំពីសកម្មភាពបទល្មើសដែលចៅក្រមបានឃុំខ្លួន ទៅតាមសាលក្រម បន្ទាប់ពីបានបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខតុលាការ។ ជនជាប់ចោទត្រូវបានបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការក្នុងថ្ងៃនោះតែម្តង[64]។

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមានបន្ទុកគ្រាប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅជំនុំជម្រះ។ ក្នុងដីកាបញ្ជូនទៅជំនុំជម្រះ អាចជាអំពើទាំងអស់ ឬមួយផ្នែកនៃសំណុំរឿង មានន័យថាអំពើខ្លះធ្វើការលើកលែងចោទប្រកាន់ ហើយអំពើខ្លះទៀតជាកម្មវត្ថុនៃការចោទប្រកាន់។ នៅពេលនោះចៅក្រមស៊ើបសួរអាចរក្សាទុកជនជាប់ចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ប្រសិនបើជនជាប់ចោទនោះនៅឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាស្នើសុំឲ្យស៊ើបសួរបន្ថែមក្នុងរយៈពេល១៥ថ្ងៃ និង១ខែក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាអាចបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង[65]។

នៅក្នុងដំណាក់កាលជំនុំជម្រះចៅក្រមជំរះត្រូវបើកនីតិវិធីសួរដេញដោលចំពោះមុខ គប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង/ឬមេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះដើម្បីគាំទ្រ ឬប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬមិនឃុំខ្លួនបណ្តោះអាសន្ន[66]។ ប្រសិនបើសម្រេចថាឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នភ្លាម។ ការប្រើប្រាស់នីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រម

[63] មាត្រា៨៨,១៣៥,២៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[64] មាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[65] មាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[66] មាត្រា៣៩២,៣៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ស៊ើបសួរទទួលអំនះអំណាងបានគ្រប់ជ្រុងជ្រោយក្នុងការសម្រេចប្រកបដោយសម្លាភាព និងគណ-នេយ្យភាព[67]។

នៅពេលដែលតុលាការទទួលសំណុំរឿងព្រហ្មទណ្ឌ ពីតំណាងអយ្យការតាមនីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះដោយផ្ទាល់ និងពីចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរតាមដីកាបញ្ជូនរឿងទៅជម្រះ ប្រធានតុលាការចាត់តាំងចៅក្រមអាសនៈណាម្នាក់ដើម្បីទទួលបន្ទុកធ្វើការជំនុំជម្រះ ដែលចៅក្រមអាសនៈនេះអាចជាប្រធានតុលាការខ្លួនឯងផ្ទាល់ឬចៅក្រមអាសនៈម្នាក់ផ្សេងទៀតក្រៅពីចៅក្រមដែលធ្វើការស៊ើបសួរ សាលាដំបូងបើកការជំនុំជម្រះដោយមានចៅក្រម ១រូប ឬ៣ រូប ដែលមានតំណាងអយ្យការ ១រូប និង ក្រឡាបញ្ជី ១រូប។

មុននឹងបើកសវនាការចៅក្រមត្រូវជូនដំណឹងដល់ភាគីទាំងសងខាង សាក្សី អ្នកតំណាង និងមេធាវី មុនរយៈពេល១៥ថ្ងៃ ដើម្បីឲ្យភាគីដែលពាក់ព័ន្ធ ឬមេធាវី ត្រៀមឯកសារការពារក្ដី អំពីកាលបរិច្ឆេទសវនាការ ក្នុងរយៈពេលសាកសួរពិភាក្សាដេញដោលអំពីរឿងក្ដី ស្ដាប់សេចក្ដីសន្និដ្ឋាននានា (មេធាវី ឬសាក្សី) ដើម្បីស្វែងរកការពិត រួចសម្រេចចេញសាលក្រម។ ប៉ុន្តែរាល់ការបើកសវនាការជំនុំជម្រះធ្វើឡើងតាមកំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនភ្លាមដោយព្រះរាជអាជ្ញា និងដោយដីកាបញ្ជូនរឿងរបស់ចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរ ទៅតុលាការជំនុំជម្រះផ្ទាល់។ ប្រសិនបើជនជាប់ចោទកំពុងឃុំខ្លួន ចៅក្រមជម្រះ ឬព្រះរាជាអាជ្ញា ចេញដីកាកោះបញ្ជាទៅប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យនាំខ្លួនជនជាប់ចោទចេញពីមន្ទីរឃុំឃាំង ហើយប្រសិនបើជនជាប់ចោទមិនស្ថិតនៅក្នុងការឃុំទេ នោះចៅក្រមត្រូវចេញដីកាបង្គាប់ឲ្យនាំចូលខ្លួន តាមកាលកំណត់សវនាការ បន្ទាប់មកតុលាការបើកអង្គសវនាការស្ដាប់ការអះអាងរបស់គូភាគី។

ក្នុងករណីដែលតុលាការទទួលបណ្ដឹង តាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន។

ព្រះរាជាអាជ្ញាចាត់វិធានការចាំបាច់ដើម្បីឲ្យជនជាប់ចោទដែលត្រូវឃុំខ្លួន ត្រូវបាននាំទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ។ សេចក្ដីសម្រេចរក្សាទុកខ្លួនជនជាប់ចោទនៅក្នុងការឃុំបណ្ដោះអាសន្នត្រូវអស់អានុភាពរយៈពេល ៤ខែ។ ប្រសិនបើជនជាប់ចោទមិនត្រូវបានឲ្យចូលបង្ហាញខ្លួននៅមុខតុលាការទេនោះ ជនជាប់ចោទត្រូវតែបានដោះលែងឲ្យមានសេរីភាពឡើងវិញដោយឯកឯង។ ជនជាប់ចោទដែលចូលបង្ហាញខ្លួននៅពេលសវនាការក្នុងឋានៈជាជនជាប់ឃុំនោះ

[67] សន្និសីទស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឆ្នាំ២០១២ ទំព័រ ៥-៦

នៅតែជាប់ឃុំដដែល រហូតដល់មានសាលក្រមលើអង្គសេចក្តីលើកលែង ដែលតុលាការបង្គាប់ឲ្យដោះលែងមានសេរីភាពវិញ[68]។

តាមដីកានេះ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅមុខតុលាការ បន្ទាប់ពីប្រគល់ដីកាកោះហៅ៖

- ១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង។
- ២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ។
- ២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។
- ៣ខែ ប្រសនិបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួន នោះរយៈពេលមិនត្រូវបានគិតគូរទេ រវាងការប្រគល់ដីកាកោះ និងការចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ[69]។ ហើយក៏អាចលើកអង្គសវនាការពេលក្រោយបានដែរ ប្រសិនបើមិនមែនបន្ទុកគ្រប់គ្រាន់ដាក់ទោសលើជនល្មើស ចៅក្រមត្រូវចេញសាលក្រម ឬសាលដីកាលើអង្គសេចក្តីឃុំខ្លួនបណ្តោះអាសន្ន ឬដោះលែងឲ្យនៅក្រៅឃុំ ដោយផ្អែកតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## កថាខណ្ឌ២. ការប្តឹងឧទ្ធរណ៍លើសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន

ក្រោយពីសាលាឧទ្ធរណ៍ទទួលបានពាក្យបណ្តឹង ពីតុលាការជាន់ដំបូងក្នុងរឿងក្តីការឃុំខ្លួនបណ្តោះអាសន្ន សាលដីការបស់សភាស៊ើបសួរត្រូវចេញសេចក្តីសម្រេចនៅក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ មានន័យថាសភាស៊ើបសួរពិនិត្យសំណុំរឿងក្នុងរយៈពេលប្តឹងឧទ្ធរណ៍ បើផុតរយៈពេលនេះជនជាប់ចោទត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ឬសម្រេចឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែបើជនជាប់ចោទនៅក្រៅឃុំតាមអំណាចសាលក្រមរបស់សាលាដំបូង សភាស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនតាមសាលដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ហើយដីកានោះត្រូវមានសំអាងហេតុត្រឹមត្រូវ ដោយយោងតាមបទបញ្ញត្តិមានត្រា ២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រធានសភាស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួន។ ហើយសំណុំរឿងត្រូវបង្វិលជាបន្ទាន់ទៅកាន់ចៅក្រមស៊ើបសួរនៅសាលាដំបូងវិញ ក្រោយពីអនុវត្តដីការួច[70]។

ការឃុំខ្លួនតាមអំណាចសាលក្រម ត្រូវចេញដោយចៅក្រមក្រោយពីបានការបើកសវនាការសម្រេចលើកលែងចោទប្រកាន់ ឬរក្សាទុកជនជាប់ឃុំបណ្តោះអាសន្ន រហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការ ប្រសិនបើជននោះនៅជាប់ឃុំបណ្តោះអាសន្នទៅតាមកំណត់ច្បាប់។ ការសម្រេច

[68] មាត្រា៣០៥ ក៣,២៥៩ ក៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[69] មាត្រា៤៦៦ និង៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[70] មាត្រា៣៧៦ ក១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/៨/២០០៧

រក្សាទុកជនត្រូវចោទក្នុងការឃុំខ្លួនបណ្តោះអាសន្ន លែងមានអានុភាពរយៈពេល ៤ខែ ហើយបើក្នុងករណីជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេល ៤ខែទេនោះ ជនត្រូវចោទបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង[71]។

ចំណែកឯការឃុំខ្លួនតាមសាលដីកាត្រូវចេញដោយសភាស៊ើបសួរបន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ដោយខ្លួនផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬអ្នកមានប្រយោជន៍ ឬមេធាវី ឬតំណាងអយ្យការ នៅពេលដែលជនល្មើសត្រូវបានបិទការជំនុំជម្រះអង្គសវនាការនៅសាលាដំបូង ដែលសម្រេចឲ្យជនជាប់ចោទនៅក្រៅឃុំ ឬឃុំខ្លួន បន្ទាប់ពីមានសាលដីកាដោះលែង ឬជនត្រូវចោទដែលបានដោះលែងនៅក្រៅឃុំ ក្រោយពីបានបញ្ចប់សវនាការជំនុំជម្រះនៅសាលាដំបូង ក្នុងករណីមានការប្តឹងឧទ្ធរណ៍ចេញសេចក្តីសម្រេចធ្វើការចាប់ខ្លួនវិញ ដើម្បីធ្វើការកាត់សេចក្តីដោយចេញដីកាដំណោះស្រាយ[72]។

## ២.១. ជនដែលមានសិទ្ធិប្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ធ្វើដោយភាគីណាក៏ដោយគឺតាមគោលការណ៍ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីដែលចេញសាលក្រម។ អ្នកប្តឹងឧទ្ធរណ៍មិនចាំបាច់ឲ្យដំណឹងនៃការប្តឹងឧទ្ធរណ៍របស់ខ្លួននោះទៅភាគីផ្សេងទៀតទេ។ ក្រឡាបញ្ជីត្រូវចុះបណ្តឹងឧទ្ធរណ៍ក្នុងបញ្ជីមួយសម្រាប់ចុះពាក្យបណ្តឹង។ ក្រឡាបញ្ជី និងអ្នកប្តឹងត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបណ្តឹងដែលចុះក្នុងបញ្ជី។ អ្នកប្តឹងឧទ្ធរណ៍អាចជំនួសបានដោយអាជ្ញានុការីដែលមានលិខិតប្រគល់សិទ្ធិពិសេស ដោយផ្អែកតាមមាត្រា១៧៦ ក១វ.៨៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនិងមាត្រា២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

ជនដែលមាសិទ្ធិប្តឹងឧទ្ធរណ៍មាន៖[73]

- ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ
- អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ឬមេធាវីរបស់គេ
- ទណ្ឌិត ឬមេធាវីរបស់ទណ្ឌិត
- ដើមបណ្តឹងរដ្ឋប្បវេណី ឬភាគីពាក់ព័ន្ធ
- ព្រះរាជអាជ្ញា

បណ្តឹងឧទ្ធរណ៍អាចធ្វើតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតាបាន ប៉ុន្តែសំបុត្រត្រូវឲ្យក្រឡាបញ្ជីតុលាការចេញសាលក្រម មាត្រា៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

ពិរុទ្ធជនដែលជាប់ឃុំ អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ ពិរុទ្ធជននេះត្រូវបំពេញពាក្យប្តឹងឧទ្ធរណ៍ទៅតាមកាលបរិច្ឆេទ ហើយ

[71] មាត្រា២៤៩ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[72] មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[73] មាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/៨/២០០៧

ត្រូវចុះហត្ថលេខា។ បន្ទាប់មកប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវចុះបញ្ជីលើពាក្យប្តឹងឧទ្ធរណ៍នៅក្នុងសៀវភៅបញ្ជីពិសេស ហើយពិរុទ្ធជនត្រូវចុះហត្ថលេខានៅលើរឹមទំព័រនេះ ហើយប្រធានពន្ធនាគារ ឬមណ្ឌលត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍រយៈពេលខ្លីបំផុតទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យបណ្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីប្តឹងឧទ្ធរណ៍នៃតុលាការ[74]។

រយៈពេលរបស់ជនដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ធ្វើឡើង១ខែ កាលណាបើសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម និងចំពោះសាលក្រមចាត់ទុកចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ គិតពីពេលទទួលដំណឹងអំពីសាលាក្រម ទោះបីជាការឲ្យដំណឹងនេះធ្វើឡើងតាមវិធីណាក៏ដោយ។ ប៉ុន្តែការប្តឹងឧទ្ធរណ៍អាចបន្ថែមរយៈពេល ៧ថ្ងៃទៀតបាន ដោយសារបណ្តឹងឧប្បត្តិហេតុ ដែលផ្តើមគិតផុតរយៈពេលធម្មតា[75]។ ចំណែកឯការប្តឹងឧទ្ធរណ៍ក្នុងរឿងឃុំខ្លួនបណ្តោះអាសន្នចំពោះពិរុទ្ធជនវិញ មានរយៈពេល ៥ថ្ងៃ ដោយគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន មានចែងក្នុងមាត្រា៣៨៩ នៃក្រមនីវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

## ២.២. សិទ្ធិប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា

កាលណាជនជាប់ចោទ ត្រូវសម្រេចដោយចៅក្រមស៊ើបសួរដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន នៅពេលជនត្រូវចោទបានរក្សាទុកនៅក្នុងពន្ធនាគារ រហូតផុតបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា មានន័យថានៅពេលជនជាប់ចោទត្រូវបានកាត់សេចក្តីចេញសាលក្រមរួច តែព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនោះដោយមានមូលដ្ឋានសំអាងហេតុ (មាត្រា២៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧)។

ជាគោលការណ៍ការប្តឹងឧទ្ធរណ៍មានរយៈពេល១ខែ ក្រោយពីចេញសាលក្រមស្ថាពរពីតុលាការជាន់ដំបូង។ ចំពោះបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញារយៈពេល៥ថ្ងៃ គិតចាប់ពីពេលថ្ងៃជូនដំណឹងប្រកាសសាដីកា[76]។ តែក្នុងករណីរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍របស់ព្រះរាជាអាជ្ញាមានរយៈពេល៤៨ម៉ោង ផ្តើមគិតពីពេលដែលតុលាការសម្រេចលើការឃុំខ្លួន[77]។ ប្រសិនបើផុតរយៈពេលប្តឹងឧទ្ធរណ៍មិនអាចប្តឹងបានទេ។

## ២.៣. អំណាចរបស់សាលាឧទ្ធរណ៍

ការប្តឹងឧទ្ធរណ៍ ការអនុវត្តសាលាក្រមត្រូវបង្អង់សិន ក្នុងករណីដែលជនជាប់ចោទបានចូលបង្ហាញខ្លួននៅតុលាការជាន់ដំបូង ត្រូវនៅក្នុងពន្ធនាគារក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់

[74] មាត្រា៣៧៧ កថាខណ្ឌ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[75] មាត្រា៣៨២-៣៨៣ នៃក្រមនីតិវិធីព្រហ្ម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[76] មាត្រា២៧០និងមាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[77] មាត្រា៣៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច។ ប៉ុន្តែនៅតុលាការជាន់ដំបូងបានសម្រេចឲ្យរួចខ្លួន ឬបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាយល់ព្រមដោះលែងជនជាប់ចោទឲ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ (មាត្រា៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧)។

សាលាឧទ្ធរណ៍ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទជាថ្មី ហើយយកមកឃុំខ្លួនជនជាប់ចោទជាថ្មី ក្នុងករណីជនជាប់ចោទនៅក្រៅឃុំ និងយកមកឃុំខ្លួនបណ្តោះអាសន្នវិញបាន។ បន្ទាប់មកត្រូវបញ្ជូនជនត្រូវចោទដែលបានចាប់ខ្លួននោះមកមន្ទីរឃុំឃាំងក្នុងរយៈពេលដ៏ខ្លីបំផុត[78] ។

សាលាឧទ្ធរណ៍បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទ ក្នុងករណីសម្រេចដាក់ទោសពន្ធនាគារយ៉ាងតិច១ឆ្នាំ ដោយគ្មានការព្យួរទេ ហើយប្រសិនបើវិធានការសន្តិសុខតម្រូវនោះ សាលាឧទ្ធរណ៍នឹងសម្រេចតាមលក្ខណៈពិសេស មានសំអាងហេតុអាចចេញនៅពេលសវនាការ នូវដីកាបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន ឬឲ្យចាប់ខ្លួនជនដែលអវត្តមាន ឬដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទដែលអវត្តមាននិងមានអានុភាពអនុវត្តភ្លាម[79]។

ប្រសិនបើជនជាប់ចោទដែលត្រូវបានតុលាការផ្តន្ទាទោសនោះត្រូវចាប់ខ្លួន ជនជាប់ចោទនោះត្រូវបញ្ជូនខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់ព្រះរាជអាជ្ញា ឬរបស់ចៅក្រមពីមន្ទីរឃុំឃាំងខេត្ត/ក្រុងសាមី មកមន្ទីរឃុំឃាំងក្នុងរាជធានីភ្នំពេញ ឬជិតមណ្ឌលឃុំខ្លួនដែលជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍[80]។ រាល់ការផ្ទេរជនជាប់ឃុំពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងរយៈពេល៣ថ្ងៃយ៉ាងយូរ ទៅព្រះរាជអាជ្ញា ដែលមានសិទ្ធិដែនដីបញ្ជូន និងសិទ្ធិដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាកំពុងចាត់ការរឿងក្តី ទៅតាមនីតិវិធីច្បាប់ ហើយការផ្ទេរនេះត្រូវភ្ជាប់នូវជាមួយទ្រព្យសម្បត្តិ ដែលមានក្នុងសំណុំរឿង និងឯកសារពាក់ព័ន្ធនានារបស់ជនជាប់ឃុំទៅឲ្យមន្ទីរឃុំខ្លួន ឬពន្ធនាគារមានសមត្ថកិច្ច(មាត្រា៦២ នៃច្បាប់ពន្ធាគារ)។

សាលាឧទ្ធរណ៍នៅពេលទទួលការជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ដោយជនជាប់ចោទ ពុំអាចដាក់បន្ថែមទំងន់ទោសលើជនត្រូវចោទឡើយ ប៉ុន្តែអាចបន្ធូរបន្ថយទំងន់ទោសបាន ។

### ២.៤. ការឃុំខ្លួនជនជាប់ចោទក្នុងពេលជាប់បណ្តឹងឧទ្ធរណ៍

នៅពេលដែលជនជាប់ចោទចូលខ្លួនជាលើកដំបូង ប្រសិនបើចៅក្រមស៊ើបសួរសម្រេចដោះលែងជាជាប់ចោទឲ្យនៅក្រៅឃុំ ហើយព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនេះ នាំឲ្យជនជាប់

[78] មាត្រា៤០៧ កថាខណ្ឌ ៥ និងមាត្រា២៨៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[79] មាត្រា៣៩៩,៣៥៣,៤០៧ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្ម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[80] មាត្រា៣៨៩ នៃក្រមនីតិវិធីព្រហ្ម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងមាត្រា១៨១ នៃច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

ចោទជនជាប់ចោទស្ថិតនៅក្នុងឃុំដដែល[81]។

ប្រសិនបើភាគីផ្សេងទៀត ប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចដាក់ឲ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរ នោះជនជាប់ចោទត្រូវស្ថិតនៅក្រៅឃុំដដែលដោយរង់ចាំលទ្ធផលសាលាឧទ្ធរណ៍។

កាលណាសាលាឧទ្ធរណ៍បដិសេធសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះសាលាឧទ្ធរណ៍ត្រូវបង្គាប់ឲ្យដោះលែងជនជាប់ចោទនោះភ្លាម[82]។

កាលណាសាលាឧទ្ធរណ៍បដិសេធសេចក្តីសម្រេចអនុញ្ញាតឲ្យជនជាប់ចោទនៅក្រៅឃុំ របស់ចៅក្រមស៊ើបសួរ សាលាឧទ្ធរណ៍ត្រូវបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទមកឃុំជាបណ្តោះអាសន្ន។ សាលាឧទ្ធរណ៍ចេញដីកាចាប់ខ្លួន ដោយផ្អែកតាមមាត្រា២០៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

ប្រសិនបើព្រះរាជអាជ្ញា ប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ហើយជនជាប់ចោទស្ថិតក្នុងការឃុំជាប់ណ្តោះអាសន្ន នោះជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនដដែល។ ប្រសិនបើគ្មានការប្តឹងឧទ្ធរណ៍ព្រះរាជអាជ្ញា នោះជនជាប់ចោទត្រូវទទួលដោះលែង [83] ។ លើកលែងតែមានប្តឹងតវ៉ាពីព្រះរាជអាជ្ញាលើដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរនោះ ជនជាប់ចោទជាប់ឃុំឃាំង ត្រូវនៅជាប់ឃុំឃាំងដដែល។

ប្រសិនបើសាលាឧទ្ធរណ៍បដិសេធលើដីកាលើកលែងចោទប្រកាន់ ប្រធានសាលាឧទ្ធរណ៍អាចចេញដីការកចាប់ខ្លួនជនជាប់ចោទជាថ្មី ដោយយកមកឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទជាថ្មីបាន កាលណាជនជាប់ចោទនៅក្រៅឃុំ[84]។ ប៉ុន្តែបើតុលាការសម្រេចផ្តន្ទាទោស ហើយជនជប់ចោទកំពុងនៅជាប់ប្តឹងឧទ្ធរណ៍ ជនជាប់ចោទនោះត្រូវតែនៅជាប់ឃុំខ្លួនជាបណ្តោះអាសន្នដដែល។ម្យ៉ាងទៀតបើជនជាប់ចោទនៅក្រៅឃុំ ការប្តឹងឧទ្ធរណ៍ត្រូវផ្អាកការអនុវត្តសាលក្រមសិន មានន័យថា ជនជាប់ចោទត្រូវនៅក្រៅឃុំដដែល លើកលែងករណីដែលតុលាការសម្រេចឲ្យរួចខ្លួន ជនជាប់ចោទត្រូវដោះលែង បើគ្មានបណ្តឹងឧទ្ធរណ៍[85]។

នៅពេលដែលចៅក្រមសម្រេចដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន សេចក្តីសម្រេចនោះមានប្រសិទ្ធភាពអនុវត្តភ្លាម ទោះជាមានការប្តឹងតវ៉ាក៏ដោយ លើកលែងតែមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា។

---

[81] សៀវភៅក្បួននីតិវិធីព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ទំព័រ១៩៥-១៩៦

[82] មាត្រា៥០៥ នៃក្រមនីតិវិធីព្រហ្ម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[83] មាត្រា៩០ នៃច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីក្រមព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០១

[84] មាត្រា៩១ នៃច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីក្រមព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០១

# ជំពូក២ ការឃុំខ្លួនតាម
# ក្នុងដំណាក់កាលនៃការអនុវត្តទោស

## ផ្នែកទី១៖ សេចក្ដីសម្រេចលើការអនុវត្តទោស

### កថាខណ្ឌ១. ការអនុវត្តទោស

ទោស ចាប់ផ្ដើមអនុវត្តនៅពេលដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរលើកលែងតែមានសេចក្ដីសម្រេចឲ្យអនុវត្តទោសភ្លាម។ ប្រសិនបើតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារ ១ឆ្នាំយ៉ាងតិច ដោយគ្មានការព្យួរទេ តុលាការតាមសេចក្ដីសម្រេចពិសេស និងដោយមានសំអាងហេតុអាចចេញនៅក្នុងពេលសវនាការ បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន ដែលដីកានេះមានអានុភាពអនុវត្តភ្លាម (មាត្រា៣៥៣ នៃនីតិវិធីព្រហ្មទណ្ឌ) ។ ហើយអាជ្ញាធរទទួលបន្ទុកអនុវត្តទោសគឺអយ្យការ (មាត្រា៤៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) មិនត្រឹមតែប៉ុណ្ណោះព្រះរាជអាជ្ញា អាចសុំកងកម្លាំងសាធារណៈ ដើម្បីធានារ៉ាប់រងការអនុវត្តទោស (មាត្រា៤៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

#### ១.១. ពិរុទ្ធភាព និងសិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ

##### ក. ពិរុទ្ធភាព

តុលាការអាចប្រកាសពីពិរុទ្ធភាពនៃជនដែលប្រព្រឹត្តបទល្មើសបានគ្រប់ពេលវេលា ដែលអំពើនៃបទល្មើសនោះជា បទឧក្រិដ្ឋ មជ្ឈឹម និងបទលហុ ក្នុងករណីជនជាប់ចោទបានប្រព្រឹត្តអំពើដែលបានធ្វើការចោទប្រកាន់មកលើខ្លួន។ មានន័យថា បើពិនិត្យឃើញមានពិរុទ្ធភាពលើជនជាប់ចោទតុលាការប្រកាសផ្ដន្ទាទោសតាមបញ្ញាត្តិច្បាប់ជាធរមាន។ ប៉ុន្តែប្រសិនតុលាការយល់ ឃើញថាអំពើនោះមិនមែនជាបទល្មើសទេ ឬជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវរួចខ្លួន ពីការចោទប្រកាន់[86]។

##### ខ. សិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ

នៅក្នុងពេលអនុវត្តទោសពន្ធនាគារ អ្នកទោសគ្រប់រូបមានសិទ្ធិ៖

- សទ្ធិត្រូវបានគេថែក្នុងសភាពថ្លៃថ្នូរ និងមានតម្លៃជាមនុស្ស។
- សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម អំពើព្រៃផ្សៃ អមនុស្សធម៌លើទណ្ឌិត។
- សិទ្ធិទទួលការដឹងឮពីកំហុសរបស់ខ្លួន មុនពេលទទួលវិន័យ។
- សិទ្ធិទទួលម្ហូបអាហារ ទឹកស្អាតគ្រប់គ្រាន់ សំលៀកបំពាក់ស្របតាមអាកាសធាតុ
- សិទ្ធិទទួលការថែទាំ និងព្យាបានជំងឺផ្សេងៗ។ល។

[85] មាត្រា៣០៨ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[86] មាត្រា៣៥០ នៃក្រមនីតិវធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- សិទ្ធិជ្រើសរើសជំនឿ សាសនា សន្តិសុខ សណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ។
- សិទ្ធិជួបសួរសុខទុកពីគ្រួសារ មិត្តភក្តិ យ៉ាងហោចណាស់១ម៉ោង ក្នុង១សប្តាហ៍។
- សិទ្ធិផ្ញើលិខិត និងទទួលលិខិតផ្សេងៗ។
- សិទ្ធិជួបពិគ្រោះយោបល់ជាមួយមេធាវីក្នុងការសំងាត់។
- សិទ្ធិចូលរួមក្នុងកម្មវិធីអប់រំ រៀនសូត្រ កំសាន្ត និងវិជ្ជាជីវៈក្នុងពន្ធនាគារ។
- ម្យ៉ាងទៀតទណ្ឌិតអាចទទួលការងារមានកម្រៃបានតាមការណែនាំពីក្រសួងមហាផ្ទៃ

## ១.២. ការដាក់ជនជាប់ឃុំឲ្យត្រួតពិនិត្យដោយមន្ទីរឃុំឃាំង ឬពន្ធនាគារ

ពន្ធនាគារ គឺជាកន្លែងដែលបង្កើតឡើងស្របច្បាប់សម្រាប់ឃុំខ្លួនអ្នកទោសតាមសេចក្តីសម្រេចរបស់តុលាការ[87]។

សមត្ថកិច្ចណាដែលចាប់ខ្លួន ឬឃុំខ្លួនជនសង្ស័យ ឬឃុំខ្លួនបុគ្គលណាម្នាក់មុនពេលសវនាការបន្ទាប់ពីការកាត់ទោសរួចហើយ ត្រូវមានរក្សាទុកក្នុងបញ្ជីពន្ធនាគារមួយ ដែលត្រូវចុះហត្ថលេខាជារៀងខែ ដោយព្រះរាជអាជ្ញា និងចៅក្រមនៅទីរួមខេត្ត/ក្រុង ឬតំបន់នៃការឃុំឃាំងក្នុងគោលបំណងពិនិត្យមើល អំពីអាយុ ឈ្មោះ អាស័យដ្ឋាន កាលបរិច្ឆេទនៃការចាប់ខ្លួន មូលហេតុនៃការចាប់ខ្លួន ឬមូលហេតុនៃការចោទប្រកាន់ លើការឃុំខ្លួន សំរាប់ជនដែលកាត់ទោសរួច[88]។

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរអាចចេញចូលទៅត្រួតពិនិត្យជនជាប់ចោទក្នុងពន្ធនាគារបានគ្រប់ពេល ដើម្បីឲ្យការឃុំខ្លួនជនត្រូវចោទនោះ ទៅតាមកន្លែងសំគួរ ឬមិនសំគួរ ការបង្ខិតបង្ខំធ្វើបាបលើរូបរាងកាយ ប្រព្រឹត្តកម្មណាមួយដែលបន្ថែមទំងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង និងពិនិត្យរយៈពេលនៃការឃុំខ្លួនដល់រយៈពេលកំណត់។ ការចាប់ខ្លួន ឬការឃុំខ្លួនត្រូវគោរពតាមបទដ្ឋានអប្បបរមានៃបទវិន័យគ្រប់គ្រងអ្នកជាប់ឃុំ ព្រមទាំងគោរពតាមគោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោសដែលអនុម័តដោយរដ្ឋសភាព[89]។

គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬប្រព្រឹត្តអំពើទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬនាំឲ្យបាត់បង់តំលៃជាមនុស្ស ឬត្រូវគេវាយដំ និងធ្វើទារុណកម្មឡើយ។ ជនជាប់ឃុំម្នាក់ៗត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ ហើយអ្នកទោសទាំងឡាយមិនត្រូវបានគេចងឬដាក់ឲ្យនៅឯកកោម្នាក់ឯងទេ ទោះស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នក្តី ឬត្រូវកាត់ទោសរួចហើយក្តី។ អ្នកទោសអាចស្រី ឬបុរស ជនជាប់ឃុំមានអាយុ១៨ឆ្នាំ ជានីតិជន ពិរុទ្ធជន ទណ្ឌិត បទល្មើសធ្ងន់ ឬស្រាល និងអ្នកទោសផ្លូវចិត្ត ត្រូវដាក់ឃុំខ្លួនឲ្យនៅដាច់ដោយឡែកពីគ្នា[90]។

---

[87] បទបញ្ញាត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រង់អ្នកទោស អនុម័តដោយអង្គាសហប្រជាជាតិ ឆ្នាំ១៩៥៥

[88] មាត្រា២១-២២ នៃច្បាប់ស្តពីពន្ធនាគារ ឆ្នាំ២០១១

[89] សៀវភៅនីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៦ ទំព័រ៥៧-៥៨

[90] ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ១៩៩៨ ប្រការ៤ ផ្នែកទី២ និងទី៣ ឆ្នាំ១៩៩៨ និងមាត្រា២៦,៣៤,៣៨,៥៣ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

ការឃុំខ្លួន ឬការចាប់ខ្លួនត្រូវគោរពតាមបទដ្ឋានអប្បបរមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកជាប់ឃុំ ព្រមទាំងគោរពតាមគោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោស ដែលអង្គការសហប្រជាជាតិបានអនុម័ត ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់របស់អង្គការសហប្រជាជាតិ អាចយកមកអនុវត្តនៅកម្ពុជាបាន។

## កថាខណ្ឌ២. ការប្រកាសទោស

ការប្រកាសទោស គឺជានីតិវិធីមួយដែលច្បាប់រដ្ឋតម្រូវឲ្យដាក់ទណ្ឌកម្មលើបុគ្គល ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើសនឹងច្បាប់។ គ្មានទោសណាមួយធ្វើឡើងដោយមិនស្របនឹងស្ថានភាពនៃបទល្មើស និងជនល្មើសឡើយ។ ការសម្រេចផ្តន្ទាទោស តុលាការត្រូវពិចារណាអំពីស្ថានភាពរបស់ជនជាប់ចោទម្នាក់ៗ[91]។

ការប្រកាសទោស គឺសាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ដែលសំរេចទៅលើសំអាងហេតុនៃរឿងក្តីបញ្ជូនទៅជំរះរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនដែលសាលក្រមនីមួយៗត្រូវប្រកាសជាសារធាណៈលើកលែងតែការប៉ះពាល់ដល់សណ្តាប់ធ្នាប់សារណៈ និងផលប្រយោជន៍សង្គម ក្នុងការណីនេះតុលាការអាចបង្គាប់ឲ្យធ្វើការពិភាក្សាដេញដោលជាសំងាត់ តាមសាលក្រមដាច់ដោយឡែកពី សាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមអង្គសេចក្តី។ សេចក្តីសម្រេចនេះមិនអាចប្តឹងតវ៉ាបានឡើយ(មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ២.១. ការប្រកាសមូលទោស

គឺជានីតិវិធីមួយដែលតុលាការអាចប្រកាសទោសបានដោយផ្អែកទៅលើស្ថានទំងន់ទោស និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ចំពោះបទល្មើសដែលត្រូវតុលាការប្រកាសផ្តន្ទាទោសនូវ[92]៖

- ទោសដាក់ពន្ធនាគារ និងទោសពិន័យត្រួតគ្នា។
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

នេះលទ្ធផលមួយសំរាប់ធ្វើឯកត្តកម្មនៃទោស ព្រោះក្រោមលក្ខខណ្ឌតែមួយគត់ ដែលទោសបានបែងចែកដោយច្បាប់ តុលាការអាចជ្រើសរើសសម្រេចប្រកាសទោសតែមួយគត់ក្នុងចំ

[91] សៀវភៅក្បួននីតិវិធីព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៦ ទំព័រ១១៧

[92] មាត្រា៩៦,៩៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

នោមទោសដែលចែងដោយច្បាប់ ឬទោសទាំងពីរ។ ដូចគ្នាផងដែរនៅក្នុងដែនកំណត់នេះ តុលាការកំណត់ដោយខ្លួនឯង ពុំត្រឹមតែថិរវេលានៃទោសជាប់ពន្ធនាគារប៉ុណ្ណោះទេ ថែមទាំងចំនួនទឹកប្រាក់ពិន័យដែលត្រូវប្រកាសទៀតផង។តុលាការគ្រាន់តែជាប់កាតព្វកិច្ចគោរពច្បាប់ប៉ុណ្ណោះគឺអប្បបរមា និងអតិបរមា មានចែងដោយច្បាប់ លើកលែងតែមានការសម្រាលទោស[93] ។

## ២.២. ការប្រកាសទោសជំនួស

គឺជាទោសការងារសហគមន៍ ឬការស្តីបន្ទោសដែលត្រូវបានកំណត់ជាជំនួសមូលទោស មានន័យថា តុលាការដែលប្រកាសទោសជាការងារសហគមន៍ ឬការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានឡើយ។ ចំពោះទោសជំនួស ចៅក្រមមិនអាចប្រកាសត្រួតជាមួយនឹងទោសពន្ធនាគារ ឬទោសពិន័យបានឡើយ ហើយទោសជំនួសទាំងពីរ ក៏មិនអាចប្រកាសព្រមពេលជាមួយគ្នាកបានដែរ[94]។

កាលបើជនជាប់ចោទណាមួយដែលត្រូវអនុវត្តដាក់ពន្ធនាគារ អតិបរមាតិចជាង ឬស្មើ ៣ឆ្នាំ តុលាការប្រកាសទោសការងារសហគមន៍ ឬដែលត្រូវជាប់កាតព្វកិច្ចបំពេញការងារក្នុងថិរវេលាចន្លោះពី ៣០ម៉ោង ទៅ២០០ម៉ោង ដោយគ្មានកំរៃជាប្រយោជន៍សង្គមជាតិ ហើយទោសការងារសហគមន៍នេះអនុវត្តបានចំពោះតែរូបវន្តបុគ្គលទេ និងរដ្ឋជាអ្នកធ្វើឧបទេសកម្មដោយពេញច្បាប់[95]។

ការអនុវត្តទោសការងារសហគមន៍ ដែលត្រូវបំពេញមិនឲ្យលើសពី ១ឆ្នាំទេ មានបញ្ជាក់ក្នុងសាលាក្រម ឬសាលដីកា ដែលកំណត់ត្រូវពិនិត្យដោយព្រះរាជអាជ្ញា (មាត្រា១០១-១០៣ នៃក្រមព្រហ្មទណ្ឌ)។

## ២.៣. ការប្រកាសទោសបន្ថែម

កាលណាបទល្មើសមួយ ត្រូវបានផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមលើមូលទោស ដែលមានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដែលត្រូវចោទប្រកាន់ (មាត្រា៥៤,៩៩នៃក្រមព្រហ្មទណ្ឌ)។ តែក្នុងករណីជនជាប់ចោទ ទទួលទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោសតែមួយគត់ ឬទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ឆ្នាំតុលាការអាចសម្រេចជំនួសមូលទោស ដោយទោសបន្ថែមមួយ ឬច្រើន។ កាលបើតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន គឺមិនអាចប្រកាសដាក់ពន្ធនាគារ ឬទោសពិន័យបានទេ (មាត្រា១០០ នៃក្រមព្រហ្មទណ្ឌ)។

---

[93] មាត្រា៩៤,៩៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[94] មាត្រា៩៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

# ផ្នែកទី២៖ ការអនុវត្តទោសក្នុងពន្ធនាគារ

## កថាខណ្ឌ១. ការគិតថិរវេលានៃការអនុវត្តទោស

គឺជារយៈពេលមួយកំណត់ដោយច្បាប់អំពីរយៈពេលនៃការអនុវត្តទោស លើបុគ្គលណាម្នាក់ដែលបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយជាប្រយោជន៍ដល់ខ្លួនឲ្យរួចផុតពីការអនុវត្តទោស។ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរងបន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា[96]។ ប៉ុន្តែការប្រកាសទោសដោយសាលាជម្រះក្ដីនានា ត្រូវរលត់ទៅដោយសារការអនុវត្តទោសចប់សព្វគ្រប់។ ហើយការផ្ដន្ទាទោសនោះ នៅតែមានទុកស្លាកស្នាម និងមានភាពគតិយុត្តិជានិច្ច ដោយហេតុថាទណ្ឌកម្មនោះ ត្រូវបានកត់ត្រាទុកក្នុងបញ្ជីថ្កោលទោសនៅក្រសួងយុត្តិធម៌ (មាត្រា៥៤២ នៃក្រមនីតិធីព្រហ្មទណ្ឌ)។

### ១.១. មរណភាពរបស់ជនជាប់ចោទ

កាលបើជនជាប់ចោទទទួលមរណភាព នោះបណ្ដាលឲ្យទោសមិនអាចអនុវត្តបានទៀតទេ នាំឲ្យទោសដែលដាក់ពន្ធនាគារត្រូវរលត់ ឬត្រូវតែញ្ញប់ មានន័យថា ទោសត្រូវយកមកអនុវត្តចំពោះតែជនដែលប្រព្រឹត្តកំហុសផ្ទាល់ខ្លួនតែប៉ុណ្ណោះ (មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ម្យ៉ាទៀតទោសដែលត្រូវរលត់ គឺទោសពន្ធនាគារ ចំណែកទោសពិន័យ និងការរឹបអូសផ្សេងៗ នៅតែបន្តអនុវត្តដដែល ព្រោះនៅពេលដែលជនជាប់ចោទស្លាប់ទៅ បន្សល់នូវទ្រព្យសម្បត្តិធ្លាក់ទៅលើទាយាទរបស់ជនជាប់ចោទ ហេតុនេះទាយាទនោះនៅតែជាប់កាតព្វកិច្ចបង់ប្រាក់ពិន័យ និងប្រគល់វត្ថុរឹបអូសជានិច្ច។

### ១.២. អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺជាការរំលត់ទោសដែលពុំត្រូវបានដាក់ឲ្យអនុវត្តក្នុងរយៈពេលណាមួយជាកំណត់ ហើយត្រូវគិតចាប់ពីពេលដែលការផ្ដន្ទាទោសដោយតុលាការបានចូលជាស្ថាពរ។ ម្យ៉ាងទៀតវិធានការស្ដីពីអាជ្ញាយុកាលត្រូវបានបង្កើតឡើង ពីព្រោះកន្លងផុតទៅនៃពេលវេលាដ៏យូរអង្វែងពេក បានជម្រុញឲ្យលុបចោទនូវអានុភាពដែលបង្កនៃការរំខាននៃបទល្មើស ហើយក៏បានធ្វើឲ្យគេលែងមានការចងចាំអំពីការផ្ដន្ទាទោសតទៅទៀត និងពិសេសនោះគឺបង្ហាញពីការអសមត្ថភាពរបស់អាជ្ញាធររដ្ឋក្នុងការស្វែងរកទណ្ឌិត ដើម្បីនាំខ្លួនទៅអនុវត្តទោស[97]។

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ មានន័យថានៅពេលដែលសេចក្ដីសម្រេចតុលាការចូលជាស្ថាពរហើយ ទោះបីជាតាមរូបភាពជាសាលក្រម ឬសាល

[95] មាត្រា៧២-៧៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[96] មាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងមាត្រា៥១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[97]នីតិវិធីព្រហ្មទណ្ឌទូទៅសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ឆ្នាំ២០១២ទំព័រ៩៦៥និងនីព្រហ្មទណ្ឌទូទៅសាស្ត្រាចារ្យម៉ម ច័ន្ទវណៈទំព័រ១៩១-១៩២

ដីកាក៏ដោយ ទោសដែលត្រូវបានសម្រេចប្រកាសដោយតុលាការនោះ ត្រូវតែយកមកអនុវត្ត ក៏ប៉ុន្តែដោយសារតែអំឡុងពេលនៃការផ្តន្ទាទោស ដែលចូលជាស្ថាពរនោះ ជននេះអត់ត្រូវបានទទួលទណ្ឌកម្មសោះ មានន័យថាដំបូងគាត់គេចខ្លួនដើម្បីឲ្យរួចផុតពីអាជ្ញាយុកាលនៃបទល្មើស ប៉ុន្តែវាអត់ផុត ស្រាប់តែដល់ពេលដែលចៅក្រមសម្រេចឲ្យមានទោសរួចហើយ គាត់ក៏រត់ទៅពួនទៀត ដូច្នេះច្បាប់បានកំណត់រយៈពេល២០ឆ្នាំសម្រាប់បទឧក្រិដ្ឋ, ៥ឆ្នាំសម្រាប់បទមជ្ឈឹម និង១ឆ្នាំ សម្រាប់បទលហុ ទោសទាំងអស់នេះមិនត្រូវយកមកអនុវត្តបានទៀតទេ ពីព្រោះមាត្រា១៥២ បានចែងថានៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ។ ហើយថិរវេលានៃការចាប់ផ្តើមអនុវត្តទោសគិតពីសេចក្តីសម្រេចផ្តន្ទាទោសជាស្ថាពរនោះគឺ២០ឆ្នាំ ៥ឆ្នាំ ១ឆ្នាំ[98]។

ឧទាហរណ៍ ក បានរត់គេចខ្លួនផុតអាជ្ញាយុកាលណាមួយនៃទោស ក្នុងវិនាទីណាមួយក៏ដោយ ដែលជាហេតុនាំឲ្យ ក រួចផុតពីការទទួលទោសព្រហ្មទណ្ឌ។ ផ្ទុយទៅវិញក្នុងករណី ក បានរត់គេចខ្លួនបាន២ ឆ្នាំក្រោយពីតុលាការផ្តន្ទាទោសពីបទមជ្ឈឹម ដែលសាលក្រមបានចូលជាស្ថាពរ ស្រាប់តែក្រោយមកអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនបាន នាំឲ្យអាជ្ញាយុកាលនៃទោសត្រូវផ្អាកលែងរាប់បន្តទៀត ពោលគឺការរត់គេចខ្លួនរបស់ទណ្ឌិតអស់រយៈពេល២ ឆ្នាំខាងលើ ត្រូវទុកជាអសាបង់។ ប្រសិនបើជននេះបន្ទាប់ពីបានជាប់ពន្ធនាគារ ៣ឆ្នាំហើយ ស្រាប់តែរត់គេខ្លួនទៀត អញ្ចឹងនាំអាជ្ញាយុកាលនៃទោសត្រូវគិតរាប់ចាប់ពីថ្ងៃដែលទណ្ឌិតរត់គេចខ្លួន ដូច្នេះទណ្ឌិតត្រូវរត់គេចឲ្យហួសរយៈពេល ៥ឆ្នាំទៀត ទើបផុតអាជ្ញាយុកាលនៃទោសបាន។

ប៉ុន្តែទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតអាជ្ញាយុកាលបានទេ ទោះបីជាជននោះ ប្រព្រឹត្តក្នុងអំឡុងពេលប៉ុន្មានក៏ដោយ ក៏ត្រូវតែទទួលនូវការផ្តន្ទាទោសទៅតាមច្បាប់ដែរ នេះដោយសារឥទ្ធិពលនៃគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរយ៉ាងខ្លាំងមកដល់សង្គមជាតិ។ បើយោងតាមមាត្រា១៥៣ នៃក្រមព្រហ្មទណ្ឌ ចែងថាភាពមិនអាចផុតអាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន បានបញ្ជាក់យ៉ាងច្បាប់ថា ក្រៅពីបទល្មើសធំៗបីខាងលើ ក៏នូវមានច្បាប់ពិសេសស្តីពីការប្រឆាំងភេរវកម្ម ដែលតម្រូវកំណត់អំពីភាពមិនអាចផុតអាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងៗទៀតដែរ[99]។

### ១.៣. ការបន្ធូរបន្ថយទោស

ស្របតាមរដ្ឋធម្មនុញ្ញមាត្រា២៧ ព្រះមហាក្សត្រមានព្រះរាជសិទ្ធិ ដោយសេចក្តីសម្រេចលើព្រះរាជក្រិត្យ បន្ធូរបន្ថយទោស ។ ប្រធានពន្ធនាគារជាអ្នករៀបចំធ្វើបញ្ជី ទណ្ឌិតដែលត្រូវបន្ថយទោស ហើយដាក់បញ្ជីនោះជូនតុលាការតាមនីតិវិធីពន្ធនាគារ[100]។

[98] មាត្រា១៥៤,១៥៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[99] សៀវភៅ ស្តីពីទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យ កៅ សីហា ឆ្នាំ២០១៣ ទំព័រ២៥៨-២៦៣

[100] ប្រកា៥.២០.ខ នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ១៩៩៨ មាត្រា១៥៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

តាមការអនុវត្តជាក់ស្តែងការបន្ធូរបន្ថយទោស អាចធ្វើឡើងស្របតាមច្បាប់ ឬលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការបន្ថយទោស ឬកែប្រែទោស មានន័យថាកែប្រែពីទោសឧក្រិដ្ឋមកទោសមជ្ឈឹមវិញ ប្រាកដណាស់ការបន្ថយទោសមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទបញ្ញត្តិផ្សេងៗផ្ទុយពីនេះក្នុងព្រះរាជក្រិត្យពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោសនោះ។ នៅក្នុងការបន្ធូរបន្ថយទោស មានអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតំលៃអំពីការកែប្រែទណ្ឌិតក្នុងរយៈពេលជាប់ឃុំក្នុងពន្ធនាគារ ដែលធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស តាមរយៈអគ្គនាយកដ្ឋានពន្ធនាគារយ៉ាងយូរបំផុត៣០ ថ្ងៃមុនផុតកំណត់នៃពិធីបុណ្យនីមួយៗ ទៅក្រសួងមហាផ្ទៃក្រោយពីបានឯកភាពពីក្រសួងយុត្តិធម៌ បន្ទាប់មកដាក់សំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនឹងសម្រេច ហើយដាក់ថ្វាយព្រះមហាក្សត្រឲ្យបន្ធូរបន្ថយទោស ក្នុងរយៈពេល១០ថ្ងៃ ដែលប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំ បន្ទាប់ពីមានលិខិតសម្រេចពីតុលាការ ឲ្យទណ្ឌិតចូលទៅរស់នៅក្នុងសង្គមវិញ[101]។

លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស (មាត្រា១,៣ នៃអនុក្រឹត្យលេខ២៨ ស្តីពីលក្ខខណ្ឌបន្ធូរបន្ថយទោស)៖

- ទណ្ឌិតបានភ្ញាក់រលឹកខិតខំលត់ដំកែប្រែខ្លួនបានល្អ និងប្តេជ្ញាចិត្តខិតខំរៀនសូត្រអប់រំខ្លួនឲ្យក្លាយទៅជាពលរដ្ឋទុចរិត និងមានប្រយោជដល់សង្គម។
- យកចិត្តទុកដាក់បំពេញការងារយ៉ាងសកម្មទៀងទាត់ មានឥទ្ធិពលល្អ និងជាគំរូដល់ទណ្ឌិតដទៃទៀត។
- ទណ្ឌិតគោរពប្រតិបត្តិមានយ៉ាងហ្មត់ចត់តាមបញ្ជាផ្ទៃក្នុងពន្ធនាគារ។
- ទណ្ឌិតត្រូវបានអនុវត្តទោសដាក់ពន្ធនាគារក្នុងរយៈពេលមួយកំណត់ជាមុនសិន។
- ទណ្ឌិតត្រូវបានដាក់ទោសពន្ធនាគារអស់មួយជីវិត ត្រូវទទួលរងទោស៧ឆ្នាំជាមុនសិន ។
- ចំពោះទណ្ឌិតត្រូវដាក់ពន្ធនាគារ១-១០ឆ្នាំ អាចបន្ថយទោសចំនួន៦ខែ។
- ចំពោះទណ្ឌិតត្រូវដាក់ពន្ធនាគារ១០-១៥ឆ្នាំ អាចបន្ថយទោសចំនួន៩ខែ។
- ចំពោះទណ្ឌិតត្រូវដាក់ពន្ធនាគារ១៥-២០ឆ្នាំ អាចបន្ថយទោសចំនួន១២ខែ។
- ចំពោះទណ្ឌិតត្រូវដាក់ពន្ធនាគារអស់មួយជីវិត អាចបន្ថយទោសលើទី១ចំនួន២០ឆ្នាំ។

ដូចនេះទណ្ឌិតម្នាក់អាចទទួលការបន្ធូរបន្ថយទោសបានច្រើនដង លុះត្រាតែទណ្ឌិតបានទទួលរងការអនុវត្តទោសទាំងអស់បានពាក់កណ្តាលនៃទោស ដែលតុលាការបានកំណត់ជាមុន

[101] មាត្រា៧៩-៨០ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

សិន។ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទណ្ឌិតម្នាក់អាចទទួលការបន្ធូរបន្ថយទោសតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ[102]។

## ១.៤. ការលើកលែងទោសទូទៅ

ការលើកលែងទោសទូទៅ គឺជាវិធានការនីតិកម្មដែលមានគោលដៅលុបនូវចរិកលក្ខណៈជាបទល្មើសនៃអំពើមួយចំនួន ដែលការលើកលែងទោសទូទៅស្ថិតក្នុងអំណាចអង្គកានីតិបញ្ញត្តិដូចមានចែងក្នុងមាត្រា៩០ថ្មី វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញ បានលុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ ស្តីពីការលើកលែងទោសទូទៅ។ ទោសមិនអាចយកមកអនុវត្តទេ ហើយទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ចប់[103]។ ស្របតាមករណីនៃការលើកលែងទោសទូទៅរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២៧ ចែងថា ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោសផងដែរ ដូចជាក្នុងថ្ងៃបុណ្យចូលឆ្នាំ ចម្រើនព្រះជនព្រះមហាក្សត្រ។

កាលណាបើមានការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះបង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន[104]បានន័យថានៅពេលដែលជនម្នាក់បានប្រព្រឹត្តបទល្មើស ហើយត្រូវបានតុលាការផ្តន្ទាទោស តែទោសត្រូវបានព្យួរ។ លុះក្រោយមកជននេះបានប្រព្រឹត្តបទល្មើសថ្មីទៀត ទើបតុលាការប្រកាសផ្តន្ទាទោសសាជាថ្មីចំពោះបទល្មើសថ្មី ហើយថែមទាំងប្រកាសដកហូតទោសព្យួរពីមុនទៀតផង ដោយអនុវត្តទោសបូកបញ្ចូលគ្នាទាំងទោសព្យួរពីមុន និងទោសថ្មី។ ប៉ុន្តែជននោះក៏ត្រូវបានប្រកាសលើកលែងទោសជាទូទៅ ចំពោះបទល្មើសថ្មីនេះឬបទល្មើសដែលបានប្រព្រឹត្តក្រោយនេះ។ បើដូច្នេះមែនទោសដែលត្រូវបានផ្តន្ទាទោសពីលើកមុន ដែលត្រូវបានព្យួរនោះក៏អាចលើកលែងទោសទូទៅដែរ ពីព្រោះនេះហើយជាការបង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុនមក។ ប៉ុន្តែការលើកលែងទោសទូទៅមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ[105]។

## ១.៥. ថិរវេលានៃការអនុវត្តទោសបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយមានលក្ខខណ្ឌដូចគ្នានឹងការជាប់ពន្ធនាគារដែរ មានន័យថាទណ្ឌិតនឹងត្រូវចាប់ខ្លួនយកទៅឃុំឃាំងនៅក្នុងពន្ធនាគារ ដូចករណីនៃការអនុវត្តទោសដាក់ពន្ធនាគារតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការអញ្ចឹងដែរ។ ជាពិសេសការបង្ខំដល់រូបកាយមិនមែនជា

---

102 មាត្រា៤ កថាខណ្ឌទី១ មាត្រា៧ នៃអនុក្រឹត្យលេខ២៤ ចុះថ្ងៃទី២០ ខែមិថុនាឆ្នាំ១៩៨៨

103 មាត្រា១៤៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

104 មាត្រា១៥០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

105 មាត្រា១៥១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

មធ្យោបាយសម្រាប់ទូទាត់បំណុលទេ ហេតុដូច្នេះទោះបីជាក្នុងលក្ខខណ្ឌដែលទណ្ឌិតបានទទួលការបង្ខំដល់រូបកាយរួចហើយក៏ដោយ ក៏បំណុលនៅតែមានអត្ថិភាពជាដរាប។ ក៏ប៉ុន្តែទណ្ឌិតមិនអាចត្រូវទទួលរងការបង្ខំដល់រូបកាយ ចំពោះបំណុលដដែលនេះសាជាថ្មីម្តងទៀតបានទេ[106]។

តាមគោលការណ៍នៃការអនុវត្តទោសបង្ខំដល់រូបកាយមានថិរវេលាអនុលោមទៅតាមចំនួនទឹកប្រាក់ដែលត្រូវបង់ដូចខាងក្រោម៖

- ១០ ថ្ងៃកាលណាទឹកប្រាក់មិនបង់មានចំនួនមិនលើសពី ២៥០,០០០ រៀល។
- ២០ ថ្ងៃប្រសិនបើទឹកប្រាក់មានចំនួនពី ២៥០,០០១-៥០០,០០០ រៀល។
- ១ ខែប្រសិនបើទឹកប្រាក់មានចំនួនពី ៥០០,០០១-១,០០០,០០០ រៀល។
- ២ ខែប្រសិនបើទឹកប្រាក់មានចំនួនពី ១,០០០,០០១-២,៥០០,០០០ រៀល។
- ៣ ខែប្រសិនបើទឹកប្រាក់មានចំនួនពី២, ៥០០,០០១-៥,០០០,០០០ រៀល។
- ៦ ខែប្រសិនបើទឹកប្រាក់មានចំនួនពី ៥,០០០,០០១-១០,០០០,០០០ រៀល។
- ១ ឆ្នាំប្រសិនបើទឹកប្រាក់មានចំនួនពី ១០,០០០,០០១-២០,៥០០,០០០ រៀល។
- ១៨ ឆ្នាំប្រសិនបើទឹកប្រាក់មានចំនួនពី ២០,៥០០,០០១-៥០,០០០,០០០ រៀល។
- ២ ឆ្នាំប្រសិនបើទឹកប្រាក់មានចំនួនលើសពី ៥០,០០០,០០០ រៀល។

## កថាខណ្ឌ២. ឧបសគ្គនៃការអនុវត្តទោសឲ្យបានពេញលេញតាមសេចក្តីសម្រេចតុលាការ

ក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតាក់តែងឡើងដោយអង្គការនីតិបញ្ញត្តិមានកំណត់ទុកជាមុននូវករណីមួយចំនួន ដែលបង្កជាឧបសគ្គដល់ការអនុវត្តប្រកាសទោសដោយចៅក្រម ទោះបីជាមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់បញ្ជាក់លើជនល្មើសក៏ដោយ ក៏ចៅក្រមមិនអាចប្រកាសបានដែរ សបញ្ជាក់ឲ្យឃើញថាទាល់តែមានច្បាប់ចែងច្បាស់លាស់។

### ២.១. ការអនុគ្រោះទោស

អនុគ្រោះទោស គឺជាការបន្ធូរបន្ថយទោស ឬលើលែងទោសដែលអនុលោមតាមត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឲ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ បានន័យថាសេចក្តីសម្រេចមួយត្រូវចូលជាស្ថាពរសិន ហើយតុលាការសម្រេចអំពីទោស ដែលទោសនោះត្រូវយកទៅអនុវត្ត ប៉ុន្តែបើយោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ព្រះមហាក្សត្រខ្មែរទ្រង់អាចដាក់ការបន្ធូរបន្ថយទោសឬមួយក៏លើកលែងទោសបាន[107]។ ឧទាហរណ៍ ទោសពន្ធនាគាររយៈពេល១ឆ្នាំ ត្រូវបានព្រះមហាក្សត្របន្ធូរបន្ថយទោស៣ខែ ដូច្នេះទោសដែលមិនត្រូវយកមកអនុវត្ត

[106] សៀវភៅ នីតិវិធីព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ឆ្នាំ២០១២ទំព័រ៤៥៦ និងមាត្រា៥២២,៥៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌ ១០/០៨/០៧

[107] មាត្រា១៩៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

នោះគឺ៣ខែ ហើយសល់៧ខែទៀត គាត់ត្រូវអនុវត្ត ព្រោះនេះជាសេចក្តីសម្រេចរបស់តុលាការ។ ប៉ុន្តែបើមានករណីលើកលែងទោសទាំងអស់ ដូចនេះទោសនោះមិនអាចយកមកអនុវត្តបានទេ ទោះបីជាទោសពិន័យក៏ដោយ។

អនុគ្រោះទោសមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃព្រះរាជាក្រឹត្យដែលពាក់ព័ន្ធនឹងការអនុគ្រោះទោសនោះ មានន័យថានេះជាការលើកលែងប្រសិនបើមានច្បាប់ចែង ប៉ុន្តែបើសិនអត់មានច្បាប់ចែងទេនោះ គឺត្រូវអនុវត្តតាមព្រះរាជក្រឹត្យ ពីព្រោះនេះគឺជាសិទ្ធិរបស់ពលរដ្ឋ ដូច្នេះហើយបានជាមាត្រា១៩៨ ចែងថាទោះបីមានការលើកលែងទោស ឬបន្ធូរបន្ថយទោសក៏ដោយ ក៏អត់ប៉ះពាល់អ្វីដល់បញ្ហាផ្នែកខាងសំណងរដ្ឋប្បវេណីទេ ពីព្រោះវាគឺជាសិទ្ធិរបស់ជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានតុលាការសម្រេចទទួលស្គាល់ត្រឹមត្រូវហើយនោះ។

## ២.២. ការលោះលាទោស

តុលាការអាចប្រកាសការលោះលាទោស បានគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង នៅក្នុងបទបញ្ញាត្តិច្បាប់នៃក្រមព្រហ្មទណ្ឌនេះ ពេលខ្លះច្បាប់ចែងផ្តន្ទាទោសបទល្មើសមួយ ដាក់តែទោសពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ[108]។ ជាទូទៅកាលោះលាទោសត្រូវយកមកអនុវត្តសម្រាប់តែជនល្មើសដែលមានចែងដោយច្បាប់តែប៉ុណ្ណោះ។ ប៉ុន្តែសូមបញ្ជាក់ថាចាប់តាំងពីក្រមព្រហ្មទណ្ឌចូលជាធរមាន និងយកមកអនុវត្តបានហើយ ជាពិសេសបទប្បញ្ញាត្តិនៃគន្ថីទី១នេះ យើងឃើញថាក្រមព្រហ្មទណ្ឌបានចែងអំពីគោលការណ៍ទូទៅមួយដែលគ្រប់ដណ្តប់ទៅលើគ្រប់បទល្មើស និងទោសព្រហ្មទណ្ឌទាំងអស់ដែលទាក់ទងនឹងមូលទោសនេះ។ លើសពីនេះទៅទៀតក្រមព្រហ្មទណ្ឌ ក៏បានចែងអំពីរបបនៃការអនុវត្តទោសរបស់ចៅក្រមផងដែរ ហើយចៅក្រមមានសិទ្ធិអំណាចក្នុងការជ្រើសរើសកំណត់អំពីទោសដូចជា៖

- ចៅក្រមអាចប្រកាសទោសទាំងពីររួមបញ្ចូលជាមួយគ្នា មានន័យថាទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ផង។
- ចៅក្រមអាចប្រកាសទោសដែលជាជំរើសត្រឹមតែទោសដាក់ពន្ធនាគារទេ បានន័យថាអត់ប្រកាស់ទោសជាប្រាក់ទេ។
- ឯជំរើសចុងក្រោយនោះ គឺអនុញ្ញាតឲ្យចៅក្រមប្រកាសទោសត្រឹមតែពិន័យជាប្រាក់ស្មើនឹងមិនប្រកាសទោសជាប់គុកក៏បានដែរ។

[108] មាត្រា៩៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

## ២.៣. ការដោះលែងមានលក្ខខណ្ឌ

តាមគោលការណ៍អនុវត្តទោស ការដោះលែងមានលក្ខខណ្ឌ គឺជានីតិវិធីមួយដែលអនុញ្ញាតឲ្យមានការដោះលែងគ្រប់ទណ្ឌិតឲ្យចាកចេញពីពន្ធនាគារមួយ ឬច្រើន នៅមុនពេលដែលទណ្ឌិតត្រូវទទួលរងនូវការអនុវត្តទៅដាក់ពន្ធនាគារចប់សព្វគ្រប់ ដោយយោងតាមសេចក្តីសម្រេចរបស់តុលាការ[109]។

ជាដំបូងការដោះលែងមានលក្ខខណ្ឌអាចចាប់ផ្តើមផ្តល់ឲ្យទណ្ឌិតដែលកំពុងតែទទួលរងការអនុវត្តទោសរបស់ជនជាប់ចោទនៅក្នុងពន្ធនាគារ ត្រូវតែដាក់ពាក្យសុំឲ្យដោះលែងមានលក្ខខណ្ឌដែលត្រូវបំពេញដូចជា[110]៖

-ចំពោះទោសដែលត្រូវអនុវត្តទៅលើទណ្ឌិតដែលមានចំនួនពាក់កណ្តាលនៃទោសតិចជាង ឬស្មើ១ឆ្នាំ។

-ចំពោះទោសដែលមានចំនួនពីរភាគបីត្រូវអនុវត្តទៅលើទណ្ឌិត ក្នុងករណីផ្សេងទៀត។

-ចំពោះទោសដែលត្រូវអនុវត្តទៅលើទណ្ឌិតជាប់ពន្ធនាគារយ៉ាងតិចបំផុតចំនួន ២០ឆ្នាំ ក្នុងករណីដែលទណ្ឌិតត្រូវជាប់ពន្ធនាគារអស់មួយជីវិត។

ការដោះលែងដោយមានលក្ខខណ្ឌ អនុញ្ញាតដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួនជាអ្នកសម្រេចសេចក្តីលើពាក្យសុំរបស់ទណ្ឌិត ប៉ុន្តែមុននឹងធ្វើសេចក្តីសម្រេចនោះ ប្រធានតុលាការនេះ ត្រូវតែសុំយោបល់ពីគណៈកម្មការជាតិយ៉ាងខ្លីបំផុតពីក្រសួងយុត្តិដែលមានសមាសភាពដូចជា[111]៖

- សមាជិក២ រូប ដែលចាត់តាំងដោយក្រសួងយុត្តិធម៌ មាន១រូបជាប្រធានតុលាការជាគណៈកម្មការ។

- ប្រធានពន្ធនាគារ ឬតំណាង ដែលជាសមាជិក។

គណៈកម្មការប្រឹក្សាយោបល់នេះត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវផ្ញើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម ប៉ុន្តែប្រធានតុលាការជាន់ដំបូងមិនត្រូវជាប់កាតព្វកិច្ចជាប់ជំពាក់នឹងសេចក្តីសម្រេចរបស់គណៈកម្មការជាតិនោះទេ។ ប្រធានតុលាការត្រូវចេញដីកាដោយមានសំអាងហេតុបញ្ជាក់លើសេចក្តីសម្រេចនេះ ដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត ព្រមទាំងត្រូវកំណត់រយៈពេលសាកល្បង

[109] សៀវភៅ នីតិវិធីព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ឆ្នាំ២០១២ ទំព័រ៤៣៩ មាត្រា៥១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ១០/០៨/០៧

[110] មាត្រា៥១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[111] មាត្រា៥១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដែលមិនលើសពីថិរវេលានៃទោស ដែលមាននៅសល់មិនទាន់ទទួលរងអនុវត្តទោសនៅឡើយ ក្នុងករណីទណ្ឌិតបានបំពានលក្ខខណ្ឌដែលមានបញ្ជាក់ក្នុងដីកា ប្រធានតុលាការអាចប្ដឹងតវ៉ាទៅប្រធានសាលាឧទ្ធរណ៍ក្នុងរយៈពេល៥ថ្ងៃ តែទណ្ឌិតរក្សាទុកក្នុងពន្ធនាគារដដែលតាមរយៈព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើការដកហូតសេចក្ដីសម្រេចរបស់ខ្លួនវិញ ហើយផ្ដន្ទាទោសជាថ្មី ត្រូវគិតក្នុងថិរវេលានៃទោសដែលបានអនុវត្តទៅលើទោសនៅសេសសល់ ហើយសេចក្ដីសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍មិនអាចតវ៉ាបបានទៀតឡើយ[112]។

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមី អាចបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិតដែលដោះលែងនោះមកវិញបាន តែត្រូវជូនដំណឹងទៅប្រធានតុលាការជាន់ដំបូងភ្លាម ហើនៅក្នុងពេលដែលមានសេចក្ដីសម្រេចដកហូតការដោះលែងដោយមានលក្ខខណ្ឌ ទណ្ឌិតត្រូវអនុវត្តទោសរបស់ខ្លួនដែលនៅសេសសល់ ដោយគិតចាប់ពីពេលដែលទណ្ឌិតទទួលសេចក្ដីសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប៉ុន្តែប្រសិនទណ្ឌិតត្រូវបានព្រះរាជាអាជ្ញាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានឃុំខ្លួនរហូតទាល់តែមានសេចក្ដីសម្រេចដកហូតការដោះលែងដោយមានលក្ខខណ្ឌត្រូវយកមកគិតក្នុងថិរវេលា នៃទោសដែលអនុវត្តនៅសេសសល់។ ផ្ទុយទៅវិញប្រសិនបើការដោះលែងមានលក្ខខណ្ឌ មិនត្រូវដកហូតក្នុងពេលសាកល្បងទេ លុះដល់ផុតរយៈពេលសាកល្បង ការដោះលែងក្លាយជាស្ថាពរ ដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងនៅឡើយ[113]។

ឧទាហរណ៍តុលាការសម្រេចផ្ដន្ទាទោសលើទណ្ឌិតម្នាក់ឲ្យជាប់ពន្ធនាគារចំនួន៣ឆ្នាំ។ក្រោយពីទណ្ឌិតបានអនុវត្តទោសបានរួច២ឆ្នាំ ត្រូវបានតុលាការដោះលែងដោយមានលក្ខខណ្ឌ ហើយថែមទាំងអនុវត្តទោសសាកល្បងទៀត ដោយមិនឲ្យលើស១ឆ្នាំឡើយ តាមការពិតទណ្ឌិតមិនទាន់អនុវត្តទោសបានចប់សព្វគ្រប់នោះទេ ពោលគឺខ្វះ១ឆ្នាំ តែបើទណ្ឌិតទៅប្រព្រឹត្តបទល្មើសថ្មីទៀតដែលត្រូវបានតុលាការផ្ដន្ទាទោសបទល្មើសថ្មីនោះ១ឆ្នាំដូច្នេះទណ្ឌិតត្រូវអនុវត្តដែលនៅសេសសល់ ១ឆ្នាំ បូកនឹងទោសនៃបទល្មើសថ្មីទៀត សរុប២ឆ្នាំ។

## ២.៤. ការផ្អាកប្រកាសទោស

តុលាការអាចផ្អាកការអនុវត្តប្រកាសទោស ក្រោយពីបានប្រកាសថាជនជាប់ចោទមានពិរុទ្ធភាពគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដូចបានត្រូវបំពេញ៖

-ការចោទប្រកាន់ពីបទមជ្ឈឹម។

-ភាពច្របូកច្របល់នៃសណ្ដាប់ធ្នាប់សាធារណៈដែលបង្កដោយបទល្មើសបានបញ្ឈប់។

---

[112] មាត្រា៥១៥-៥១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[113] មាត្រា៥១៩-៥២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

-ជនជាប់ចោទបានបង្ហាញអំពីការធានានៅក្នុងការចូលទៅរស់នៅក្នុងសង្គមវិញ។

-ជនជាប់ចោទសុំរយៈពេល ដើម្បីជួសជុលការខូចខាត។

-ជនជាប់ចោទមានវត្តមាននៅពេលសវនាការ។

ការផ្អាកការប្រកាសទោសអាចបង្គាប់បាន លុះត្រាតែជនជាប់ចោទនៅក្នុងសវនាការ ដែលមានអានុភាពរយៈពេល១ឆ្នាំ ពោលគឺសេចក្តីសម្រេចពីទោសត្រូវធ្វើឡើងយ៉ាងច្រើនបំផុតត្រឹម១ឆ្នាំ ក្រោយពីមានសេចក្តីសម្រេចឲ្យផ្អាក ដោយតុលាការត្រូវកំណត់នៅក្នុងសាលក្រម ឬសាលដីកា ដែលមានកាលបរិច្ឆេទត្រូវសម្រេចពីទោស។ ប៉ុន្តែការផ្អាកប្រកាសទោសនៅពេលសវនាការរឿងត្រូវបង្អង់សិន គឺតុលាការត្រូវសម្រេចអំពីទោស បានន័យថាដោយសារតែមានមូលដ្ឋានដែលជាលក្ខណ្ឌនៃមាត្រា១២៤ និង១២៥ ទើបតុលាការបង្អង់រឿងទុកសិន លុះដល់ពេលមួយកំណត់ទើបតុលាការយករឿងដែលបង្អង់នោះមកសម្រេចអំពីទោសឡើងវិញ[114]។

## ២.៥. ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង មានអានុភាពដាក់ឲ្យទណ្ឌិតនៅក្នុងរយៈពេលសាកល្បង ឲ្យស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោពកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បងមុនអនុវត្តទោសព្យួរទោស ដែលមានរយៈពេលកំណត់ចាប់ពី ១ឆ្នាំដល់៣ឆ្នាំ។ លុះត្រាតែទោសព្យួរសាកល្បងការអនុវត្តទោសបានសម្រេចដាក់ពន្ធនាគាររយៈពេលពី៦ខែដល់៥ឆ្នាំ មានន័យថាបើទោសដាក់ពន្ធនាគារតិចជាង ៦ខែ ការព្យួរទោសសាកល្បងមិនអាចប្រកាសបានទេ[115]។

ការព្យួរទោសសាកល្បងនេះ អនុវត្តបានចំពោះតែរូបវន្តបុគ្គលប៉ុណ្ណោះទេ មិនអនុវត្តចំពោះនីតិបុគ្គលទេ ព្រោះទោសនេះទាក់ទងនឹងទោសពន្ធនាគារប៉ុណ្ណោះដោយមិនរាប់បញ្ចូលនូវទោសពិន័យឡើយ។ ដែលការព្យួរទោសសាកល្បង ឲ្យទណ្ឌិតស្ថិតវិធានពីរ គឺ៖

+ ការព្យួរទោសសាកល្បង ដែលឲ្យទណ្ឌិតត្រូវស្ថិតក្រោមវិធានការត្រួតពិនិត្យដូចជា៖[116]

- ត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា។
- ត្រូវទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាប្រគល់សិទ្ធិឲ្យ។
- ត្រូវប្រគល់ដល់ព្រះរាជអាជ្ញា នូវឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់ទៅរស់ក្នុងសង្គមវិញ។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាស័យដ្ឋាន និងផ្លាស់ប្តូរមុខរបរខ្លួន។
- ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនធ្វើដំណើរទៅបរទេស។

[114] មាត្រា១២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[115] មាត្រា១១៧-១១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[116] មាត្រា១១៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

+ ការការព្យួរទោសសាកល្បង ដែលឲ្យទណ្ឌិតត្រូវគោរពកាតព្វកិច្ចដូចជា[117]៖

- បំពេញសកម្មភាពវិជ្ជាជីវៈនិងទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- រស់នៅក្នុងកន្លែងណាមួយជាកំណត់ និងទទួលឲ្យពេទ្យពិនិត្យ ឬព្យាបាល។
- បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។
- ជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពធនធានរបស់ខ្លួន។
- មិនត្រូវសេពគបបនល្បែង និងសេពគ្រឿងស្រវឹងឡើយ។
- មិនត្រូវកាន់កាប់តាមខ្លួននូវអាវុធជាត់ផ្ទុះ។

ការព្យួរទោសសាកល្បង អាចត្រូវដកហូតដោយតុលាការ នៅក្នុងករណី៖

- ទណ្ឌិតមិនគោរពវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចក្នុងចិរវេលាសាកល្បង។
- ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈឹមជាថ្មីក្នុងចិរវេលាសាកល្បង។
- តុលាការអាចបង្គាប់ឲ្យដកហូតការព្យួរទោសសាលកល្បងនេះទាំងមូល ឬមួយផ្នែក ហើយយកមកអនុវត្តទាំងមូល ឬមួយផ្នែក។

## ២.៦. ការអនុវត្តទោសរបបពាក់កណ្តាលសេរីភាព

របបពាក់កណ្តាលសេរីភាព គឺជារបបនៃការអនុវត្តទោសដែលអនុញ្ញាតឲ្យទណ្ឌិតអាចចេញពីពន្ធនាគារទៅបំពេញសកម្មភាពវិជ្ជាជីវៈ ក្នុងរយៈពេលមានកំណត់ ដែលរបបពាក់កណ្តាលសេរីភាពនេះ ជាយន្តការមួយថ្មីដែលទាក់ទងជាមួយនឹងរបបទូទៅនៃការប្រកាសទោស ក្នុងគោលដៅកែសម្រួលទណ្ឌិត និងធានាថា អាចធ្វើសមាហរណកម្មទណ្ឌិតឲ្យចូលទៅរួមរស់នៅក្នុងសង្គមវិញបានន័យថានៅពេលដែលទណ្ឌិតអនុវត្តទោសក្តី នៅជាប់ពិរុទ្ធជនក្តី តែសង្គមមិនអាចកាត់ផ្តាច់ទំនាក់ទំនងគ្រួសារ ទំនាក់ទំនងវិជ្ជាជីវៈ ទំនាក់ទំនងការងារ និងទំនាក់ទំនងក្នុងការសិក្សានៅក្នុងសង្គមបានឡើយ[118]។ លក្ខខណ្ឌនៃការអនុវត្តរបបពាក់កណ្តាលសេរីភាពដូចជា៖

-តុលាការត្រូវសម្រេចប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ៦ខែ។

-តុលាកាត្រូវសម្រេចឲ្យអនុវត្តសក្រោមរបបពាក់កណ្តាលសេរីភាព ដើម្បីឲ្យទណ្ឌិតបំពេញសកម្មភាពវិជ្ជាជីវៈទទួលការសិក្សា ឬការបណ្តុះបណ្តាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថមដល់សេចក្តីត្រូវការរបស់គ្រួសារ។

របបពាក់កណ្តាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងចិរវេលានៃទោសដែលកំពុងអនុវត្តដែលតុលាការអនុញ្ញាតឲ្យទណ្ឌិតចាកចេញពីពន្ធនាគារក្នុងរយៈពេលមួយកំណត់ ដោយតុលាការ

[117] មាត្រា១២០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[118] មាត្រា១២៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

ចេញសេចក្តីសម្រេចឲ្យបានច្បាស់លាស់អំពីថ្ងៃ ឬម៉ោងដែលអនុញ្ញាតឲ្យទណ្ឌិតមានវត្តមានក្នុងពន្ធនាគារ[119]។

នៅគ្រប់ពេលវេលាទាំងអស់ តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្តាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្តាលសេរីភាព តាមពាក្យបណ្តឹងរបស់ព្រះរាជអាជ្ញា បានសេចក្តីថាតុលាការអាចបន្ថែម ឬបន្ថយរយៈពេលនៃរបបពាក់កណ្តាលសេរីភាព ឬមួយក៏ឈប់ប្រើប្រាស់នូវរបបពាក់កណ្តាលសេរីភាព ចំពោះរឿងក្តីមួយបានគ្រប់ពេលវេលា ប្រសិនបើមានការប្តឹងសុំពីថៅក្រមអយ្យការ។ ហើយតុលាការត្រូវជូនដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ មិនត្រឹមតែប៉ុណ្ណោះព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញនៅពេលផុតកំណត់រយៈពេលនៃពាក់កណ្តាលសេរីភាព ពីព្រោះការអនុវត្តរបបនេះ ត្រូវស្ថិតនៅក្រោមការតាមដានរបស់ព្រះរាជអាជ្ញា មានន័យថាបើតុលាការបានកំណត់ដល់ពេលចូលគុកវិញ ស្រាប់តែដល់ម៉ោងអត់ឃើញទៅដល់គុកទេ ហើយថែមទាំងគ្មានមូលហេតុសមស្រម នោះព្រះរាជអាជ្ញាចេញបញ្ជាឲ្យចាប់ខ្លួនទណ្ឌិតដែលគេចខ្លួន ដើម្បីយកមកអនុវត្តទោសដាក់គុកវិញ[120]។

## ២.៧. ការបែងចែកទោសប្រភាគ

ការបែងចែកទោសប្រភាគ គឺជាប្រភេទនៃស្ថានសម្រាលទោសមួយដែលតុលាការយល់ឃើញថាទោសដាក់ពន្ធនាគារតិចជាង ឬស្មើ១ឆ្នាំ ទោសនោះត្រូវបានអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។ វាមានបទល្មើសមួយចំនួន គឺអាស្រ័យទៅលើការសម្រេចដោយសាលក្រមតុលាការ បើតុលាការសម្រេចដាក់ពន្ធនាគារមិនលើសពី១ឆ្នាំទេ ទោសនោះអាចអនុវត្តក្រោមការបែងចែកទោសជាប្រភាគបាន[121]។ ទោសប្រភាគនីមួយៗមិនត្រូវតិចជាង១ខែទេ ចិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី២ខែទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស។ តុលាការត្រូវកំណត់ក្នុងសេចក្តីសម្រេចរស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ។

ឧទាហរណ៍ តុលាការសម្រេចផ្តន្ទាទោសទណ្ឌិតដាក់គុក១ឆ្នាំ ប៉ុន្តែដោយសារទណ្ឌិតមានជំងឺត្រូវព្យាបាលនៅមន្ទីរពេទ្យជារៀងរាល់ខែ ក្នុងករណីនេះតុលាការសម្រេចឲ្យទណ្ឌិតជាប់ពន្ធនាគារ១ឆ្នាំ ក្នុងករណីនេះដែរតុលាការបានអនុវត្តទោសជាប្រភាគដោយឲ្យជាប់ពន្ធនាគាររយៈពេល១ខែពេញ ហើយអនុញ្ញាតឲ្យនៅក្រៅពន្ធនាគាររយៈពេល១ខែ និងបន្តបន្ទាប់ឆ្លាស់គ្នាតាមខែនៃទោស

[119] មាត្រា១២៨-១២៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[120] មាត្រា១៣០-១៣១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[121] មាត្រា១៣២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

គុកក្នុងរយៈពេល១ឆ្នាំ ដោយហេតុនេះ ទណ្ឌិតត្រូវអនុវត្តទោសគុករយៈពេលដល់២ឆ្នាំ ទើបអនុវត្តទោសរួចចប់សព្វគ្រប់ជាស្ថាពរមានន័យថា១ក្នុងក្នុងគុក និង១ឆ្នាំនៅក្រៅគុក។

នៅគ្រប់ពេលវេលាទាំងអស់ តុលាការអាចរៀបចំបែបបទនៃការបែងចែងទៅជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមរយៈបណ្តឹងរបស់ព្រះរាជអាជ្ញា ដោយអនុវត្តតាមនីតិវិធីនៃក្រមព្រហ្មទណ្ឌ។ហេតុនេះបើសិនជាទណ្ឌិតដែលទទួលការបែងចែងទោសជាប្រភាគមិនវិលត្រឡប់មកពន្ធនាគារវិញទេ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនទណ្ឌិតម្តងទៀត(មាត្រា១៣៤-១៣៥នៃក្រមព្រហ្មទណ្ឌ)។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាផ្នែកទ្រឹស្ដី និងតាមរយៈស្រាវជ្រាវកន្លងមកស្ដីអំពីការឃុំខ្លួន យើងឃើញថាវិធានផ្សេងៗដែលត្រូវបានប្រើប្រាស់សំរាប់ទប់ស្កាត់ ឬរារាំងបទល្មើសគ្រប់ប្រភេទជាពិសេសបទល្មើសក្នុងរឿងព្រហ្មទណ្ឌកុំឲ្យកើតមានឡើងនោះ គឺជាប្រតិកម្មតាមផ្លូវតុលាការរបស់សង្គមតបទៅនឹងបុគ្គលណាម្នាក់ ឬជនណាមួយ តាំងពីការចាប់ផ្ដើម ក្នុងការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌរហូតដល់ដាក់ទណ្ឌកម្ម និងមាននីតិវិធីត្រូវបានដំណើរការដែលហៅថា រឿងព្រហ្មទណ្ឌដែលមានទំនាក់ទំនងជាមួយវិធានច្បាប់ដោយអនុវត្តតាមផ្លូវតុលាការ ដោយពុំអាចរំលងហួសពីសមត្ថកិច្ចរបស់ស្ថាប័នតុលាការបានឡើយ។ ដូច្នេះរាល់មានបទល្មើសកើតមានឡើង មន្ត្រីនគរបាលយុត្តិធម៌ឬអាជ្ញាធរមានសមត្ថកិច្ចដែលរដ្ឋផ្ដល់អំណាចឲ្យក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្នុងការបង្ក្រាបបទល្មើសចាប់ខ្លួន ឃុំខ្លួន ជនល្មើសជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ ហើយចាត់វិធានការស៊ើបសួរ បញ្ជូនរឿងឲ្យទៅចៅក្រមស៊ើបសួរបើកការស៊ើបសួរ ប្រមូលភស្តុតាងដាក់បន្ទុកលើជនល្មើស បន្ទាប់មកចៅក្រមស៊ើបសួរបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញាវិញ ដើម្បីឲ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងទៅប្រធានតុលាការ ដើម្បីចាត់តាំងចៅក្រមជំនុំជំរះ និងដោយឈានរហូតដល់ចេញអនុវត្តសាលក្រម ដើម្បីកំណត់ទោសទណ្ឌណាមួយ កត្តាទាំងនេះសបញ្ជាក់ឲ្យឃើញថាការអនុវត្តច្បាប់រវាងក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិនៅក្នុងស្ថាប័នតុលាការ។

បទល្មើសព្រហ្មទណ្ឌកើតមានឡើង តែងមាននាំមកនូវបណ្ដឹងអាជ្ញា និងបណ្ដឹងព្រហ្មទណ្ឌ។ បណ្ដឹងអាជ្ញាត្រូវធ្វើឡើងក្នុងនាមរដ្ឋ ក្នុងគោលបំណងដើម្បីផ្ដន្ទាទោសជនល្មើសទៅតាមបញ្ញាត្តិច្បាប់ និងដាក់ទណ្ឌកម្មចំពោះជនណាដែលប្រព្រឹត្តអំពើណាឲ្យខូចខាត ឬបំផ្លាញដល់សណ្ដាប់ធ្នាប់សាធារណៈ និងសង្គម ដើម្បីឲ្យជននោះរាងចាលលែងហ៊ានប្រព្រឹត្តបទល្មើសទៀត ជនដែលបំរុងប្រព្រឹត្តិខ្លាចរអាមិនហ៊ានធ្វើទៅទៀត។ ចំណែកឯបណ្ដឹងរដ្ឋប្បវេណី គឺជាបណ្ដឹងដែលជនរងគ្រោះទាមទារឲ្យជួសជុលការខូចខាត ដែលបណ្ដាលមកពីការប្រព្រឹត្តអំពើល្មើសក្នុងបទព្រហ្មទណ្ឌ។ ជាគោលការណ៍បណ្ដឹងនេះអាចទាមទារបាន លុះត្រាតែការខូចខាតមានពិតប្រាកដ មានទំនាក់ទំនងហេតុផល និងបច្ច័យរវាងបទល្មើសព្រហ្មទណ្ឌ ហើយវាជាលទ្ធផលនៃបទល្មើសក្នុងពេលបច្ចុប្បន្ន។

ហេតុនេះនៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង តែងតែដោះស្រាយដោយតុលាការព្រហ្មទណ្ឌ តាមច្បាប់ព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឬច្បាប់ពាក់ពន្ធផ្សេងៗទៀត។ ជាក់ស្ដែងនៅពេលតុលាការទទួលបណ្ដឹងរួចពីជនរងគ្រោះ មេធាវី ឬពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាផ្ដើមចោទប្រកាន់លើជនល្មើស រួចបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរបន្ត ហើយព្រះរាជ

អាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរឃុំខ្លួនជនល្មើសបាន ដើម្បីងាយស្រួលអនុវត្តនីតិវិធីទោស ប៉ុន្តែចៅក្រមស៊ើបសួរអាចឃុំខ្លួនតាមគំនិតខ្លួនឯងផ្ទាល់ ឬតាមយោបល់របស់ព្រះរាជអាជ្ញា ដោយមានសំអាងហេតុ ការសំរេចរក្សាទុកជនត្រូវចោទក្នុងការឃុំខ្លួនបណ្តោះអាសន្ន លែងមានអានុភាពរយៈពេល៤ខែ ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួនក្នុងរយៈពេល៤ខែទេ នោះត្រូវដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។ចៅក្រមអាចបន្តរយៈពេលឃុំខ្លួនបាន៦ខែបានប្រសិនបើបទល្មើសមានភាពស្មុគស្មាញក្នុងការស៊ើបសួរ។ យើងសង្កេតឃើញថាការឃុំខ្លួនត្រូវមានមូលហេតុសំអាង ដើម្បីបង្ការកុំឲ្យជនល្មើសប្រព្រឹត្តបទល្មើសថ្មី មានការគំរាមកំហែងដល់ជនរងគ្រោះងាយស្រួលក្នុងការអនុវត្តនីតិវិធីច្បាប់ ខ្លាចជនល្មើសរត់គេចខ្លួនបាត់ មានការត្រូវរ៉ូវគ្នាជាមួយជនរងគ្រោះ ឬភាគីដែលពាក់ព័ន្ធ និងធ្វើឲ្យមានអត្ថិភាពដល់សង្គមជាតិ មិនត្រឹមតែប៉ុណ្ណោះការឃុំខ្លួនផ្អែកទៅលើកម្មវត្ថុនៃការប្រព្រឹត្តបទល្មើសដោយបុគ្គលណាមួយ ដែលច្បាប់បញ្ញត្តិទុកជាបទល្មើសនៅជាធរមាន។

ការឃុំខ្លួនចាំបាច់ត្រូវមានដីកាបង្គាប់ឲ្យឃុំខ្លួនដល់ប្រធានមន្ទីរឃុំឃាំង ឬមណ្ឌលឃុំឃាំងនៅតាមបណ្តាខេត្តឬ/ក្រុងនីមួយៗ ដោយភ្ជាប់ទៅជាមួយជនជាប់ចោទ តាមរយៈសេនាធិការប្រធានពន្ធនាគារ ឆ្មាំគុក ឬមន្ត្រីមានសមត្ថកិច្ច ដែលដីកាបង្គាប់ឲ្យឃុំខ្លួននេះយោងទៅលើសេចក្តីសម្រេចបង្គាប់ឲ្យឃុំខ្លួនរបស់ចៅក្រមកាន់សំណុំរឿង(ស៊ើបសួរ)។ ហើយការឃុំខ្លួនត្រូវអនុវត្តទៅអនីតិជននិងនីតិជន ដែលបានប្រព្រឹត្តបទល្មើសតាមរយៈកាលនៃការឃុំខ្លួនរបស់ចៅក្រមនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។វិធានការនៃការឃុំខ្លួនត្រូវដាក់ឃុំខ្លួនជនជាប់ចោទឲ្យនៅដាច់ដោយឡែកពីគ្នា ទៅតាមច្បាប់ស្តីពី ការគ្រប់គ្រងពន្ធនាគារ ព្រោះបុគ្គលគ្រប់រូបមិនត្រូវដកហូតនៅសេរីភាពណាមួយឡើយ ត្រូវមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ទោះបីជាជនណាមួយជាប់ទោសពីបទល្មើសអ្វីក៏ដោយ មិនត្រូវមានការកាត់ផ្តាច់សេរីភាពរបស់គេបានទាំងអស់ជាដាច់ខាតណាមួយពីសង្គមឡើយ។ នៅពេលអនុវត្តទោសចប់បុគ្គលនោះត្រូវវិលមករស់នៅក្នុងសង្គមវិញដូចដើម។ ហេតុនេះការឃុំខ្លួន គឺជាវិធានការមួយអនុវត្តច្បាប់ឲ្យមានភាពយុត្តិធម៌ទៅលើជនល្មើស ក្នុងរយៈកាលណាមួយជាកំណត់តែប៉ុណ្ណោះ ក្នុងករណីដែលដល់ពេលកំណត់ឲ្យរួចពីការឃុំខ្លួន ចៅក្រមមិនទាន់ដោះលែង ត្រូវចាត់ទុកថា ការបង្ខាំងមនុស្សដោយខុសច្បាប់ ត្រូវទទួលទោសតាមច្បាប់។ យើងដឹងហើយថា ប្រសិនបើគ្មានច្បាប់ចាប់បង្ខំឃុំខ្លួនជនល្មើសនោះទេ វាហាក់បីដូចជាអយុត្តិធម៌ក្នុងការប្រព្រឹត្តបទល្មើស ព្រោះជនល្មើសមិនខ្លាចនៅតែប្រព្រឹត្តតទៅទៀត ធ្វើឲ្យមានអត្ថិភាពដល់សណ្តាប់ធ្នាប់សាធារណៈមិនមានច្បាប់ទំលាប់ ដែលបានចែងទុកជាធរមាន ដោយប្រទេសយើងយកគោលការណ៍គោរពច្បាប់ជាធំនោះ។

ហេតុដូចនេះសង្គមយើងបច្ចុប្បន្នកើតមានបទល្មើសគ្រប់ប្រភេទ គ្រប់រូបភាពស្ទើរតែរាល់ថ្ងៃ ហើយការទប់ស្កាត់ ឬការរារាំងបទល្មើស ពុំទាន់មានលក្ខណៈបច្ចេកទេសនៅឡើយទេ។ ដើម្បីចូលរួមក្នុងការកសាងសង្គមជាតិឲ្យបានរីកចម្រើនឆាប់រហ័ស ប្រជាពលរដ្ឋគ្រប់រូបត្រូវមានស្មារតីភ្ញាក់រលឹកខ្ពស់ក្នុងការចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ស្ថាប័នមានសមត្ថកិច្ច ត្រូវគិតគូរលើកទឹកចិត្តដល់ស្នាដៃក្នុងការទប់ស្កាត់ រារាំងបទល្មើសក្នុងសង្គម ចាត់វិធានការតឹងរឹង ចំពោះអ្នករំលោភបំពានច្បាប់ និងផ្តល់ប្រាក់បៀវត្សដល់មន្ត្រីរាជការឲ្យបានសមស្របតាមជីវភាពសង្គម ជាពិសេសពង្រឹងវិស័យប្រព័ន្ធយុត្តិធម៌ឲ្យបានរឹងមាំ ឲ្យប្រជាពលមានជំនឿជឿជាក់លើស្ថាប័នអនុវត្តច្បាប់ និងលុបបំបាត់អំពើពុករលួយក្នុងសង្គម ព្រមទាំងចាត់វិធានការតឹងរឹងចំពោះជនដែលប្រព្រឹត្តអំពើពុករលួយគ្រប់ជាន់ថ្នាក់ និងគ្រប់រូបភាព។

ខ្ញុំសង្ឃឹមថានៅពេលអនាគតដ៏ខ្លីខាងមុខនេះ ដែលប្រទេសយើងកំពុងទន្ទឹងរង់ចាំសមាហរនកម្មអាស៊ានជិតមកដល់ ប្រទេសកម្ពុជាយើងនឹងមានការរីកចម្រើនកែប្រែមុខមាត់ថ្មីៗឆាប់រហ័សឆ្ពោះទៅរកការរីកចំរើនលើគ្រប់វិស័យ និងឈានទៅរកនីតិរដ្ឋ ដូចប្រទេសរីកចម្រើនផ្សេងៗនៅលើពិភពលោកយើងនេះពិតប្រាកដជាមិនខានឡើយ។

# អនុសាសន៍

ដើម្បីឲ្យអត្ថបទសារណាស្ដីពីការឃុំខ្លួននេះ ស្របទៅតាមការអនុវត្តជាក់ស្ដែង និងប្រកបដោយមានខ្លឹមសារជាមួយគតិច្បាប់នោះ ដាច់ខាតត្រូវអនុវត្តតាមនីតិវិធីច្បាប់ត្រឹមត្រូវ ដោយអនុវត្តទៅលើតែបុគ្គលប្រព្រឹត្តបទល្មើសប៉ុណ្ណោះ។ រាល់ការឃុំខ្លួនត្រូវធ្វើឡើងដោយអំណាចតុលាការ ឬស្ថាប័នអនុវត្តច្បាប់ដែលត្រូវបានប្រើប្រាស់អំណាចក្នុងទំហំច្បាប់កំណត់ពីការឃុំខ្លួន ចំពោះបុគ្គល ណាមួយនោះ ត្រូវប្រាប់ពីមូលហេតុច្បាស់លាស់ មានបញ្ជាក់ភស្តុងដាក់បន្ទុកគ្រប់គ្រាន់ ចែងក្នុងច្បាប់ជាធរមាន គោរពតាមច្បាប់ស្ដីពីសិទ្ធិមនុស្ស ឬកតិកាសញ្ញាអនុសញ្ញាអន្តរជាតិពាក់ព័ន្ធផ្សេងៗ ព្រោះថាការឃុំខ្លួ ន គឺត្រូវដកហូសេរីភាពមនុស្ស ធ្វើការបំបិទសិទ្ធិមិនឲ្យធ្វើអ្វីតាមតែអំពើចិត្តដែលវាធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សេចក្ដីថ្លៃថ្នូររបស់បុគ្គលដែលបានឃុំខ្លួន ដោយខុសច្បាប់ ហើយធ្វើឲ្យបុគ្គលនោះទទួលហានីភ័យជាច្រើនយ៉ាងពីមជ្ឈដ្ឋានជុំវិញសង្គម មានការអាប់អួរ ក្នុងជីវិតរស់នៅរបស់គេជាមិនខានឡើយ។

ម្យ៉ាងទៀតការឃុំខ្លួន អនុវត្តដោយតុលាការ និងស្ថាប័នអនុវត្តច្បាប់ ដើម្បីការពារជនរងគ្រោះដែលត្រូវគេបំពានសិទ្ធិ ព្រមទាំងផ្ដន្ទាទោសជនល្មើសផងដែរ។ លើសពីនេះទៅទៀតការឃុំខ្លួន គឺជានីតិវិធីរបស់តុលាការ ដែលមានតួនាទី និងភារកិច្ចបំរើឲ្យប្រយោជណ៍ដល់ប្រជាពលរដ្ឋនៅក្នុងលំហូរប្រព័ន្ធយុត្តិធមិកម្ពុជា ដើម្បីការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាព ស្ថេរភាពដល់ជនរងគ្រោះ និងជនល្មើសគ្រប់ៗរូប ដោយសារថាជនល្មើសមានសិទ្ធិ និងមានអ្វីៗដូចគ្នានឹងជនរងគ្រោះទាំងអស់ដែរ ប៉ុន្តែខុសគ្នាត្រង់ជនល្មើសត្រូវបានបំបិទសេរីភាព ក្នុងមួយរយៈពេលដែលតុលាការអនុវត្តទោសទៅលើជនល្មើសដែលធ្វើសកម្មភាពខុសច្បាប់ ហួសទំហំនៃសិទ្ធិ ប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។ ហេតុនេះច្បាប់ជាអ្នកបង្ខំឲ្យជនល្មើសទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដែលបង្កឡើងក្នុងពេលប្រព្រឹត្តបទល្មើស។ នៅពេលជនណាម្នាក់ត្រូវបានតុលាការឃុំខ្លួន ត្រូវកំណត់ឲ្យបានច្បាប់លាស់នៃរយៈពេលឃុំខ្លួន និងរយៈពេលត្រូវដោះលែង ដើម្បីឲ្យជនជាប់ឃុំខ្លួនវិលត្រឡប់ទៅរស់ក្នុងសង្គមវិញ។

ជាចុងបញ្ចប់ ការឃុំខ្លួន ត្រូវអនុវត្តតាមនីតិវិធីច្បាប់ចែងជាធរមាន "បើគ្មានច្បាប់ចែងបទប្បញ្ញត្តិជាបទល្មើសទេ គឺមិនមែនទោសឡើយ" ។ ហើយការឃុំខ្លួន មានតែចៅក្រម និងព្រះរាជអាជ្ញាទេ មានសិទ្ធិឃុំខ្លួនជនល្មើសបាន ដែលកំណត់ដោយច្បាប់ដែលតំណាងឲ្យអំណាចរបស់រដ្ឋ ប្រគល់សិទ្ធិឲ្យប្រើប្រាស់អំណាច សមត្ថភាពក្នុងការស្វែងរកសច្ចាភាព សច្ចធមិ គុណធមិ ព្រហ្មវិហារធមិជូនប្រជាពលរដ្ឋ។

# ឯកសារយោង

១. អត្ថបទច្បាប់

- ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ និង វិសោធនកម្ម នៃរដ្ឋធម្មនុញ្ញបន្តបន្ទាប់ទៀត។
- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ និងវិសោធនកម្មនៃក្រមនីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់
- ច្បាប់នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩២និងវិសោធនកម្មនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- វិសោធនកម្មមាត្រា២៤៧,៣៦៣,៣៧២,៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣
- ក្រមព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ កញ្ញា ឆ្នាំ១៩៩២
- ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១
- បទបញ្ញាតិជាបទដ្ឋានអប្បបរិមាសំរាប់ការគ្រប់គ្រងអ្នកទោស ឆ្នាំ១៩៩៥
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ២០១២

២. អត្ថបទសន្ធិសញ្ញា និងអនុសញ្ញាពាក់ព័ន្ធច្បាប់អន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១០/១២/១៩៤៨
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៩៦៦
- សេចក្តីពន្យល់ទូទៅលេខ៣២ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧
- វិធានបទដ្ឋានជាអប្បបរិមារបស់អង្គការសហប្រជាជាតិ ស្តីពី វិធានការដាក់ឲ្យនៅក្រៅឃុំ
- វិធានរបស់អង្គការសហប្រជាជាតិ សំរាប់ការពារ អនីតិជនដែលត្រូវបានដកហូតសេរីភាព អនុម័តដោយសេចក្តីសំរេចលេខៈ ៤៥/១១៣ ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៩០ នៃមហាសន្និបាត

៣. អនុក្រឹត្យ និងប្រកាស

- អនុក្រឹត្យលេខ ១៧ អនក្រ ស្តីពី តួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មណ្ឌលគ្រប់គ្រងយុវទោសករ ភ្នំពេញ ចុះថ្ងៃទី១៩ ឆ្នាំ១៩៩៤
- ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ លេខ២១៧ ប្រ.ក

៤. សារាចរ និងសេចក្តីណែនាំ

- សារាចរ ស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខៈ ០១ ក.យ.សរ/១៤
- សារាចរ ស្តីពី ការគ្រប់គ្រង និងត្រួតពិនិត្យពន្ធនាគារស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា លេខ០០១
- សេចក្តីណែនាំលេខៈ០១ ក.យ.សណន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៥ ស្តីពី គោលការណ៍យុត្តិធម៌អនីតិជន
- ការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន លេខ១២០ ក.យ.រប/១៤

- សេចក្តីណែនាំអំពីការអនុវត្តន៍ទាក់ទងនឹងការការពារជនរងគ្រោះ លេខ០៣ ក.យ.សណន/២០០៥
- សេចក្តីណែនាំអំពីគោលការណ៍យុត្តិធម៌អនីតិជន លេខ០១ ក.យ.សណន/០៥

៥. អត្ថបទសៀវភៅមេរៀន និងសិក្ខាសាលា

- ពិភាក្សាព្រហ្មទណ្ឌកម្ពុជា របស់លោក ស្វូត ខូហៀល
- សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ថ្ងៃ០១/០២/ ២០០៦
- សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ របស់ក្រសួងយុត្តិធម៌ ថ្ងៃ៣០/០៨/ ១៩៩៩
- នីតិវិធីព្រហ្មទណ្ឌទូទៅ លោក សុខ រឿន ឆ្នាំ២០១០-២០១២
- មេរៀននីតិវិធីព្រហ្មទណ្ឌទូទៅ លោក រុន ពន្ធណារិទ្ធិ ឆ្នាំ២០១២-២០១៣
- សៀវភៅ ស្តីពីទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យ កៅ សីហា ឆ្នាំ២០១៣
- សៀវភៅដំណើរការក្តីនៅក្នុងតុលការកម្ពុជា របស់អង្គការមូលនិធិអាស៊ី ឆ្នាំ១៩៩៨ ផ្ទះលេខ៥៩
- សិទ្ធិទទួលបានការជំនុំជំរះដោយយុត្តិធម៌នៅកម្ពុជា ឆ្នាំ២០១២-២០១៤
- សេចក្តីពន្យល់នៃមាត្រាទាំងឡាយនៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនិងការឃុំខ្លួន
- គោលការណ៍ និងគោលការណ៍ណែនាំអង្គការសហប្រជាតិ ស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្នាំ២០១៣
- សន្និសិទ ស្តីពី ការអនុវត្តក្រមនីវិធីព្រហ្មទណ្ឌ នៅថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០១២
- សិក្ខាសាលាស្តីពីការលើកកំពស់កិច្ចសហការរវាង ស្ថាប័នតុលាការ អយ្យការ និងពន្ធនាគារនិងកិច្ចការពារសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី៥-៧ ខែមិថុនា ឆ្នាំ២០១២

៦. អត្ថបទច្បាប់ទូទៅ

- វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត ដែលជាការរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧
- វចនានុក្រមច្បាប់ របស់លោក ហ៊ីងធីឫទ្ធិ បោះពុម្ពលើកទី២ ឆ្នាំ២០១០
- សន្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
- សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១